ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

# ព្រឹត្តិបត្រ

# ក្រុមប្រឹក្សាជាតិភាសាខ្មែរ

BULLETIN DU CONSEIL NATIONAL DE LA LANGUE KHMERE

BULLETIN OF THE NATIONAL COUNCIL OF KHMER LANGUAGE

លេខ១០ ឆ្នាំ២០១៩

Vol.10, 2019

**បោះពុម្ពលើកទី១** ចំនួន៤ ៥០០ច្បាប់
នៅរោងពុម្ព ជី.អ៊ី.ធី.ប៊ីហ្សនេស
ផ្ទះលេខ២៣២០ ផ្លូវ៤៥ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)

| | | |
|---|---|---|
| អាសយដ្ឋាន | : | មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ |
| ទូរសព្ទដៃ | : | ០១២ ៨៦៣ ៩២០, ០១២ ៥៨៩ ៥៤៩, ០៩២ ៨៩២ ៣៤៣ |
| អ៊ីមែល | : | ncklofrac@gmail.com |
| វេបសាយ | : | www.nckl.gov.kh |

# មាតិកា

**ចំណងជើង** **ទំព័រ**


- គណៈគ្រប់គ្រងនិងក្រុមការងារ....................i
- បុព្វកថា....................iii
- អារម្ភកថា....................v

I- កម្រងច្បាប់ទាក់ទងនឹងក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.)....................១

- ព្រះរាជក្រឹត្យលេខ នស/រកត/១១១៧/១០១៣ ត្រាស់បង្គាប់តែងតាំង និងផ្តល់ឋានៈប្រធាន និង អនុប្រធាន ក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា....................៣
- អនុក្រឹត្យលេខ ១២៥៦ អនក្រ-តត ស្តីពីការតែងតាំងមន្ត្រីរាជការនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ....................៥
- ព្រះរាជក្រឹត្យលេខ នស/រកត/០៣១៨/២៩៦ ត្រាស់បង្គាប់តែងតាំង និងផ្តល់ឋានៈអនុប្រធាន ក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា....................៨
- អនុក្រឹត្យលេខ ៩៩៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីក្រុមប្រឹក្សាជាតិភាសាខ្មែរ....................១០
- ព្រះរាជក្រឹត្យលេខ នស/រកត/០២១៩/២៨២ ត្រាស់បង្គាប់តែងតាំង និងផ្តល់ឋានៈអនុប្រធាន ក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា....................១២

II- សមិទ្ធផលនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ....................១៥

១- បច្ចេកសព្ទស្នើដោយគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច....................១៧

២- បច្ចេកសព្ទស្នើដោយគណៈកម្មការទស្សនវិជ្ជា....................៣៤

៣- បច្ចេកសព្ទស្នើដោយគណៈកម្មការសុខាភិបាល....................៦៤

៤- សិក្ខាសាលាស្តីពី «បញ្ហាយុគលពិន្ទុប្រើក្នុងពាក្យកម្ចីភាសាបាលី-សំស្ក្រឹត»....................៨០

# គណៈគ្រប់គ្រង

- ប្រធាន......................................... : ឯកឧត្តមបណ្ឌិត **ហ៊ាន សុខុម**
- **អនុប្រធាន**..................................... : ឯកឧត្តមបណ្ឌិត **សន ពៅ**
- **អនុប្រធាន**.................................... : ឯកឧត្តមបណ្ឌិត **ស៊ុំ ឈុំឡុង**
- **អនុប្រធាន**..................................... : ឯកឧត្តមបណ្ឌិត **ប៊ី សុខគង់**

## <u>ក្រុមអ្នករៀបចំ</u>

- ប្រធានលេខាធិការដ្ឋាន.................... : លោក **លាង សុភាព**
- អនុប្រធានលេខាធិការដ្ឋាន............... : លោកស្រី **ហង់ លក្ខិណា**
- អនុប្រធានលេខាធិការដ្ឋាន.............. : លោក **យឹម វិច្ឆិកា**
- អនុប្រធានលេខាធិការដ្ឋាន.............. : លោក **គុយ រិន**
- មន្ត្រីលេខាធិការដ្ឋាន........................ : លោក **ជួន សោរិទ្ធី**
- មន្ត្រីជាប់កិច្ចសន្យា.......................... : លោក **អ៊ុយ វិចិត្រ**

# បុព្វកថា

ដើម្បីផ្សព្វផ្សាយលទ្ធផលការងាររបស់ខ្លួន ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) បានប្រើប្រាស់មធ្យោបាយជាច្រើន ដូចជាការបោះពុម្ពផ្សាយព្រឹត្តិបត្រ សទ្ទានុក្រម និងសៀវភៅផ្សេងៗ។ ក្រៅពីនេះ អង្គភាពនេះក៏បានបង្កើតវេបសាយ បណ្ដាញព័ត៌មានសង្គម ព្រមទាំងចូលរួមវេទិកាពិភាក្សា ផ្ដល់សម្ភាសន៍ជាបន្តបន្ទាប់ដល់វិទ្យុនិងទូរទស្សន៍នានា និងតែងតែរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាច្រើនផងដែរ។

ការផ្សព្វផ្សាយតាមរយៈព្រឹត្តិបត្រនៅតែត្រូវបានចាត់ទុកជាមធ្យោបាយចាំបាច់ក្នុងការផ្សព្វផ្សាយព័ត៌មាន និងបច្ចេកសព្ទនៅជំហានទី១ សម្រាប់ឱ្យសាធារណជនផ្ដល់យោបល់ស្ថាបនាលើចំណុចខ្វះខាតដើម្បីឱ្យក្រុមប្រឹក្សាជាតិភាសាខ្មែរពិនិត្យឡើងវិញមុននឹងសម្រេចបោះពុម្ពផ្សាយជាសទ្ទានុក្រម។

ក្នុងព្រឹត្តិបត្រលេខ១០នេះ ក្រៅពីកម្រងច្បាប់ពាក់ព័ន្ធមួយចំនួន ក៏មានចុះផ្សាយបច្ចេកសព្ទដែលក្រុមប្រឹក្សាជាតិភាសាខ្មែរបានអនុម័តហើយ ក្នុងនោះមានបច្ចេកសព្ទវិទ្យាសាស្ត្រសេដ្ឋកិច្ច បច្ចេកសព្ទទស្សនវិជ្ជា និងបច្ចេកសព្ទវេជ្ជសាស្ត្រ ដែលសុទ្ធតែបានឆ្លងការពិភាក្សាល្អិតល្អន់ក្នុងចំណោមសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ និងគណៈកម្មការជំនាញ ដែលជាការរួមចំណែកយ៉ាងធំធេងក្នុងការអភិវឌ្ឍនិងស្វែងរកការឯកភាពជូនភាសាខ្មែរ។

នៅទីបញ្ចប់ ខ្ញុំសូមកោតសរសើរ ក.ជ.ភ.ខ. ដែលបានសម្រេចនូវលទ្ធផលដ៏ល្អតាំងពីដើមរៀងមក និងសូមជូនពរឱ្យក្រុមប្រឹក្សាជាតិភាសាខ្មែរ បានសម្រេចនូវបេសកកម្មស្វែងរកឯកភាពជូនភាសាខ្មែរ នាពេលដ៏ខ្លីខាងមុខ។

ថ្ងៃចន្ទ ៦កើតខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

បណ្ឌិតសភាចារ្យ **សុខ ទូច**

# អារម្ភកថា

ព្រឹត្តិបត្រលេខ១០នេះមានចុះផ្សាយបច្ចេកសព្ទស្នើដោយគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច គណៈកម្មការទស្សនវិជ្ជា និងគណៈកម្មការសុខាភិបាល ដែលក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.)បានប្រជុំពិភាក្សា និងអនុម័ត។

ក្រុមប្រឹក្សាជាតិភាសាខ្មែរសូមថ្លែងអំណរគុណទុកជាមុនចំពោះសាធារណជនដែលជួយផ្ដល់យោបល់ស្ថាបនាទាក់ទងនឹងបច្ចេកសព្ទទាំងនេះដើម្បីឱ្យយើងអាចពិនិត្យកែលម្អបន្ថែម មុននឹងសម្រេចបោះពុម្ពជាសទ្ទានុក្រម។

ម្យ៉ាងទៀត យើងមិនអាចលើកឡើងតែបញ្ហាបច្ចេកទេសសុទ្ធសាធដោយមិននិយាយពីបញ្ហាហិរញ្ញវត្ថុនោះទេ ព្រោះថា ក.ជ.ភ.ខ.អាចដំណើរការមកដល់បច្ចុប្បន្ននេះ គឺដោយសារមានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាដែលមានឆន្ទៈចង់ឱ្យភាសាជាតិមានការរីកចម្រើននិងឯកភាព។

ក្នុងនាមក្រុមប្រឹក្សាជាតិភាសាខ្មែរទាំងមូល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសម្ដេចបណ្ឌិតសភាចារ្យ អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែឧបត្ថម្ភគាំទ្រដ៏ខ្ពង់ខ្ពស់ដល់ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជា ទាំងស្មារតីនិងសម្ភារៈ។

ថ្ងៃចន្ទ ៧រោច ខែកត្ដិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិត **ហ៊ាន សុខុម**

# I- កម្រងច្បាប់ទាក់ទងនឹង ក្រុមប្រឹក្សាជាតិភាសាខ្មែរ( ក.ជ.ភ.ខ. )

# ព្រះរាជក្រឹត្យ

នស/រកត/១១១៧/ ៧០១៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត ០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤(ថ្មី) មាត្រា១០(ថ្មី) មាត្រា១១(ថ្មី) មាត្រា១២(ថ្មី) និងមាត្រា២០(ថ្មី) នៃព្រះរាជក្រឹត្យលេខនស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦៤១ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការដាក់ក្រុមប្រឹក្សាជាតិភាសាខ្មែរឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ទ្រង់ត្រាស់បង្គាប់

**មាត្រា១**: តែងតាំង និងផ្តល់ឋានៈ ប្រធាន និងអនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា ២រូប :

១- ឯកឧត្តមបណ្ឌិត **ហ៊ាន សុខុម** ជាប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

២- ឯកឧត្តមបណ្ឌិត **សន ពៅ** ជាអនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ មានឋានៈស្មើ **អគ្គនាយក**។

**មាត្រា២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*នស/រកត/១១១៧/១០២៦*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧*

លេខ: ១០៣១ ស.ណ

**សំណៅចែងមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១២៥៦ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ

ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤(ថ្មី) មាត្រា១០(ថ្មី) មាត្រា១១ (ថ្មី) មាត្រា១២(ថ្មី) និងមាត្រា២០(ថ្មី) នៃព្រះរាជក្រឹត្យលេខនស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦៤១ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការផ្ទេរក្រុមប្រឹក្សាជាតិភាសាខ្មែរឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់របនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- តាមសំណើរបស់ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

**សម្រេច**

**មាត្រា១.-**

តែងតាំងមន្ត្រីរាជការនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ចំនួន០៤រូប ៖

| | |
|---|---|
| ១- លោក **លាង សុភាព** | ជាប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ មានឋានៈស្មើ **អគ្គនាយករង** |
| ២- លោកស្រី **ហាត់ លក្ខិណា** | ជាអនុប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** |
| ៣- លោក **សេ អឿន** | ជាអនុប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** |
| ៤- លោក **ឃឹម ទិដ្ឋិកា** | ជាអនុប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។ |

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១៧*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

៣/៣

រាជបណ្ឌិត្យសភាកម្ពុជា
ចូល លេខ ៣៣០/១៨ មេសក
មកដល់ថ្ងៃទី ២២-០៣-១៨
ម៉ោង ០៥:០០

ក្រុមប្រឹក្សាជាតិភាសាខ្មែរ

នស/រកត/០៣១៨/២៩៦

# ព្រះរាជក្រឹត្យ

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា៨ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៨(ថ្មី) មាត្រា១០(ថ្មី) មាត្រា១១(ថ្មី) មាត្រា១២(ថ្មី) និងមាត្រា២០(ថ្មី) នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា៨ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦៤១ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្ដីពីការផ្ទេរក្រុមប្រឹក្សាជាតិភាសាខ្មែរ ឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១/២

# ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តមបណ្ឌិត **ស៊ុំ ឈុំឡុង** ជាអនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ មានឋានៈស្មើ អគ្គនាយក។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៨

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

នស.១៨០៣.៣០១

លេខ: ៣៣៤ ស.ណ

**សំណៅចម្លងតាមច្បាប់ដើម ដើម្បីជាការចែកផ្សាយ**

ថ្ងៃពុធ ៥កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

២/៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩៩៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤(ថ្មី) មាត្រា១០(ថ្មី) មាត្រា១១(ថ្មី) មាត្រា១២(ថ្មី) និងមាត្រា២០(ថ្មី) នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦៤១ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការផ្ទេរក្រុមប្រឹក្សាជាតិភាសាខ្មែរ ឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃរាជបណ្ឌិត្យសភាកម្ពុជា

១/២

- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១** : តែងតាំងមន្ត្រីរាជការនៃរាជបណ្ឌិត្យសភាកម្ពុជា ចំនួន ០៧រូប :

១. លោកបណ្ឌិត **ផុន កសិកា** ជាអនុប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ មានឋានៈស្មើ អគ្គនាយករង

២. លោកស្រីបណ្ឌិត **ជា ចណ្ណី** ជាប្រធានផ្នែកធម្មសាស្ត្រ និងចរិយាសាស្ត្រ នៃវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៣. លោក **សូ ម៉ុណ្ណារ៉ាត់** ជាប្រធានផ្នែកប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រនយោបាយ នៃវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៤. លោក **យឹម អាយុវឌ្ឍនៈទិដ្ឋា** ជាប្រធានផ្នែកគណិតវិទ្យានិងស្ថិតិ នៃវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៥. លោក **ហឿន សុធារស់** ជាប្រធានផ្នែកបុរាណវិទ្យា នៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៦. លោក **កែវ លីណែត** ជាប្រធានផ្នែកខេមរនីយកម្ម វចនានុក្រម និងបកប្រែ នៃវិទ្យាស្ថានភាសាជាតិ មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៧. លោក **នុយ រិន** ជាអនុប្រធានលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ មានឋានៈស្មើ ប្រធាននាយកដ្ឋាន។

**មាត្រា២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧ កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
ចូល មកដល់ថ្ងៃ ៨.៤.៣.១៩ ម៉ោង ១០:០០ លេខ ៣១/១៩ កជភខ

# ព្រះរាជក្រឹត្យ

នស/រកត/០២១៩/២៥២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

រាជបណ្ឌិត្យសភាកម្ពុជា
ចូល លេខ ២៥០/១៩ អសសក មកដល់ថ្ងៃទី ៤ មីនា ១៩ ម៉ោង ០៩:០៩

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៤៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤(ថ្មី) មាត្រា១០(ថ្មី) មាត្រា១១(ថ្មី) មាត្រា១២(ថ្មី) និងមាត្រា២០(ថ្មី) នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦៤១ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការផ្ទេរក្រុមប្រឹក្សាជាតិភាសាខ្មែរ ឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

## ប្រកាសបង្គាប់

**មាត្រា១** : តែងតាំង និងផ្តល់ឋានៈ ឯកឧត្តមបណ្ឌិត **ចឺ សុខឆេង** ជាអនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ អគ្គនាយក។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

៣៧ . ១៩០២ . ២០១៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៩*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី



កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# II- សមិទ្ធផល
# នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

# ១- បច្ចេកសព្ទស្នើដោយគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច

| | |
|---|---|
| **១- កម្ចី**<br>អ. loan<br>បារ. emprunt ( m. ) | ប្រាក់ឬទំនិញដែលបានខ្ចីហើយត្រូវទូទាត់សងវិញតាមលក្ខខណ្ឌនៃកិច្ចសន្យា។ |
| **២- កម្មសិទ្ធិ**<br>អ. property rights/ ownership<br>បារ. propriété ( f. ) | សិទ្ធិពេញលេញជាម្ចាស់លើទ្រព្យ។ សិទ្ធិនេះរួមបញ្ចូលទាំងសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែងលើទ្រព្យ។ |
| **៣- កម្មសិទ្ធិករ**<br>អ. owner<br>បារ. propriétaire ( n. ) | រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានសិទ្ធិពេញលេញជាម្ចាស់កម្មសិទ្ធិលើទ្រព្យ។ |
| **៤- កម្រៃជើងសា**<br>អ. commission<br>បារ. commission ( f. ) | ភាគរយនៃថ្លៃទំនិញឬអត្ថប្រយោជន៍( ទំនិញ របស់ ប្រាក់...) ដែលភ្នាក់ងារទិញលក់ឬភ្នាក់ងារដទៃទៀតត្រូវបានទទួលក្នុងទំនាក់ទំនងការងារនោះ។ |
| **៥- ការជួល**<br>អ. rent<br>បារ. location ( f. ) | កិច្ចព្រមព្រៀងជួលរវាងកម្មសិទ្ធិករនិងអ្នកជួលតាមលក្ខខណ្ឌដែលបានកំណត់។ |
| **៦-ការិយាល័យតំណាងធនាគារបរទេស**<br>អ. foreign bank representative office<br>បារ. bureau représentant de banque étrangère | ទីភ្នាក់ងារតំណាងរបស់ធនាគារបរទេសមានមុខងារស្រាវជ្រាវទីផ្សារ ទាក់ទងអតិថិជន ទាក់ទាញវិនិយោគិន និងមិនធ្វើប្រតិបត្តិការធនាគារដោយផ្ទាល់។ |
| **៧- ការិយាល័យឥណទាន**<br>អ. credit bureau<br>បារ. bureau de crédit | ក្រុមហ៊ុនផ្តល់ព័ត៌មានហិរញ្ញវត្ថុ ឧបករណ៍វិភាគទិន្នន័យ និង របាយការណ៍ឥណទានទៅដល់គ្រឹះស្ថានហិរញ្ញវត្ថុ។ |
| **៨- កិច្ចទីផ្សារ/ម៉ាឃិធីង**<br>អ. marketing<br>បារ. marketing ( m. ) | សំណុំនៃសកម្មភាពបុគ្គល ស្ថាប័ន ឬ ក្រុមហ៊ុននានា ក្នុងការបង្កើតតម្លៃ ការផ្សព្វផ្សាយ ការជំរុញ ការដោះដូរ និងការផ្តល់នូវអ្វីដែលមានប្រយោជន៍ដល់អតិថិជន ដៃគូ និងសង្គមទាំងមូល។ |

| | |
|---|---|
| **៩- កិច្ចទីផ្សារការី/ការីម៉ាឃិធីង**<br>អ. marketer<br>បារ. marketeur (m.) | អ្នករៀបចំនិងអនុវត្តយុទ្ធនាការកិច្ចទីផ្សារ។ |
| **១០- កិច្ចទីផ្សារចម្រុះ/ ម៉ាឃិធីងចម្រុះ**<br>អ. marketing mix<br>បារ. marketing mix | មធ្យោបាយកិច្ចទីផ្សារ ឬ ម៉ាឃិធីងទាំងឡាយដែលសហគ្រាសប្រើប្រាស់ដើម្បីសម្រេចនូវការលក់ផលិតផលរបស់ខ្លួននៅទីផ្សារគោលដៅ។ ជាតុនៃកិច្ចទីផ្សារចម្រុះ ឬម៉ាឃិធីងចម្រុះ ជាទូទៅមានបួនគឺ ផលិតផល (Product) ថ្លៃ (Price) ទីកន្លែង(Place) និងការជំរុញផ្សព្វផ្សាយ(Promotion) ដែលហៅថា Pបួន "Four Ps"។ |
| **១១-កិច្ចទីផ្សារចល័ត/ ម៉ាឃិធីងចល័ត**<br>អ. mobile marketing<br>បារ. marketing mobile | សំណុំសកម្មភាពកិច្ចទីផ្សារដើម្បីផ្សព្វផ្សាយអំពីផលិតផលដល់អតិថិជនតាមរយៈឧបករណ៍ចល័តរបស់អ្នកទទួល។ |
| **១២- កិច្ចទីផ្សារឌីជីថល/ ឌីជីថលម៉ាឃិធីង**<br>អ. digital marketing<br>បារ. marketing numérique | សំណុំសកម្មភាពកិច្ចទីផ្សារដើម្បីផ្សព្វផ្សាយអំពីផលិតផលដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ |
| **១៣- កុំម៉ូឌីធី**<br>អ. commodities | វត្ថុធាតុដើមឬផលិតផលកសិកម្មបឋមដែលអាចទិញឬលក់នៅលើទីផ្សារ។ |
| **១៤- កូនបំណុល**<br>អ. debtor<br>បារ. débiteur (m.) | បុគ្គលដែលត្រូវសងបំណុល។ |
| **១៥- ក្រុមហ៊ុនពាណិជ្ជកម្មបរទេស**<br>អ. foreign commercial company<br>បារ. société commerciale étrangère | ក្រុមហ៊ុនដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសណាមួយ ហើយបានបោះទីតាំងធ្វើពាណិជ្ជកិច្ចនៅក្រៅប្រទេសនោះ។ |

| | |
|---|---|
| **១៦-ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ**<br>អ. financial leasing company<br>បារ. société de bail financier | នីតិបុគ្គលដែលផ្តល់ជូនអតិថិជននូវការប្រើប្រាស់និងអាស្រ័យផលពីចលនវត្ថុណាមួយដោយយកថ្លៃឈ្នួល។ |
| **១៧- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**<br>អ. public limited company (PLC)<br>បារ. société anonyme (S.A) | ក្រុមហ៊ុនមូលធនមួយប្រភេទបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ ដឹកនាំនិងគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ដែលក្នុងនោះមានសមាសភាពជាអភិបាលយ៉ាងតិច៣រូប។ ក្រុមហ៊ុនប្រភេទនេះមានសិទ្ធិបោះចេញនូវមូលបត្រសម្រាប់លក់ជាសាធារណៈ។ ម្ចាស់ភាគហ៊ុនម្នាក់ៗទទួលខុសត្រូវចំពោះបំណុលក្រុមហ៊ុនត្រឹមតែចំនួនភាគហ៊ុនដែលខ្លួនមានក្នុងក្រុមហ៊ុនប៉ុណ្ណោះ។ |
| **១៨- ក្រុមហ៊ុនមូលធន**<br>អ. limited company | ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតបង្កើតដោយលក្ខន្តិកៈ និង ជានីតិបុគ្គលដាច់ដោយឡែកពីម្ចាស់ភាគហ៊ុន ហើយម្ចាស់ភាគហ៊ុនទទួលខុសត្រូវត្រឹមចំនួនភាគហ៊ុនដែលខ្លួនបានទិញ។ ក្រុមហ៊ុននេះគ្រប់គ្រងនិងដឹកនាំដោយក្រុមប្រឹក្សាភិបាល។ |
| **១៩- ក្រុមហ៊ុនសហកម្មសិទ្ធិ**<br>អ. partnership<br>បារ. société de personnes | ក្រុមហ៊ុនទទួលខុសត្រូវគ្មានកម្រិតបង្កើតឡើងដោយកិច្ចសន្យា ដែលមានបុគ្គល២នាក់ឡើងទៅ និងជានីតិបុគ្គលដែលមិនដាច់ដោយឡែកពីម្ចាស់។ ក្រុមហ៊ុននេះគ្រប់គ្រងដោយសហកម្មសិទ្ធិករទូទៅទាំងអស់។ |
| **២០- ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ**<br>អ. general partnership<br>បារ. société en nom collectif (SNC) | ក្រុមហ៊ុនសហកម្មសិទ្ធិមួយប្រភេទដែលកើតឡើងពីកិច្ចសន្យារវាងបុគ្គល២ ឬច្រើននាក់ ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬ សកម្មភាពរបស់បុគ្គលទាំងនោះ ដើម្បីប្រកបពាណិជ្ជកិច្ចរួមក្នុងគោលបំណងរកប្រាក់ចំណេញ ហើយសមាជិកទាំងអស់ជាសហកម្មសិទ្ធិករទូទៅ។ |
| **២១-ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត**<br>អ. limited partnership<br>បារ. société en commandite | ក្រុមហ៊ុនសហកម្មសិទ្ធិមួយប្រភេទដែលកើតឡើងពីកិច្ចសន្យារវាងសហកម្មសិទ្ធិករទូទៅម្នាក់ឬច្រើននាក់ដែលមានបុគ្គលម្នាក់ត្រូវបានអនុញ្ញាតឱ្យគ្រប់គ្រងនិងមានកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនជាមួយសហកម្មសិទ្ធិករមានកម្រិតម្នាក់ឬច្រើននាក់ទៀត ដែលមានកាតព្វកិច្ចបង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិនោះ។ |

| | |
|---|---|
| ២២-ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត(ឯ.ក)<br>អ. private limited company ( Co., Ltd )<br>បារ. société à responsabilité limitée ( SARL ) | ក្រុមហ៊ុនមូលធនមួយប្រភេទ ដែលបង្កើតឡើងនិងចុះបញ្ជីតាមច្បាប់ មានសមាជិកភាគហ៊ុនចាប់ពី២នាក់រហូតដល់៣០នាក់ ហើយសមាជិកម្នាក់ៗទទួលខុសត្រូវចំពោះបំណុលក្រុមហ៊ុនត្រឹមតែចំនួនភាគហ៊ុនដែលខ្លួនបានដាក់ដើមទុនក្នុងក្រុមហ៊ុនប៉ុណ្ណោះ និងមិនអាចលក់ភាគហ៊ុនជាសាធារណៈបាន។ |
| ២៣- ខ្ចី<br>អ. borrow<br>បារ. emprunter ( v. ) | យករបស់របរ ឬ ប្រាក់ពីគេមកប្រើប្រាស់ ហើយសងទៅវិញ។ |
| ២៤- គណនេយ្យ<br>អ. accounting<br>បារ. comptabilité ( f. ) | ការកត់ត្រាជាប្រព័ន្ធនិងគ្រប់ជ្រុងជ្រោយអំពីប្រតិបត្តិការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អង្គភាព ឬ ស្ថាប័នណាមួយ។ |
| ២៥- គណនេយ្យករ<br>អ. accountant<br>បារ. comptable ( n. ) | បុគ្គលដែលមានគុណវុឌ្ឍិក្នុងការកត់ត្រានិងការរក្សាបញ្ជីចំណូល ចំណាយ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សវនកម្មនិងវិភាគគណនី និងការផ្តល់យោបល់លើបញ្ញត្តិពន្ធនានានិងឱកាសវិនិយោគ។ |
| ២៦- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ<br>អ. microfinance institution<br>បារ. institution de microfinance | គ្រឹះស្ថានហិរញ្ញវត្ថុឬស្ថាប័នហិរញ្ញវត្ថុឯកជនមានឯកទេសក្នុងការផ្តល់ប្រាក់កម្ចីខ្នាតតូចសម្រាប់ក្រុម ឬ បុគ្គលមានចំណូលទាប និងសហគ្រាសធុនតូច ហើយមានដើមទុនអប្បបរមាតម្កល់នៅធនាគារជាតិតិចជាងប្រាក់តម្កល់របស់ធនាគារពាណិជ្ជ។ |
| ២៧- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ<br>អ. microfinance deposit taking institution | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលការអនុញ្ញាតពីធនាគារកណ្តាលឱ្យផ្តល់សេវាទទួលប្រាក់បញ្ញើ។ |
| ២៨- គ្រឹះស្ថានហិរញ្ញវត្ថុ/ស្ថាប័នហិរញ្ញវត្ថុ<br>អ. financial institutions<br>បារ. institution financière/ établissement financier | ស្ថាប័នសាធារណៈ ឬ ឯកជនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីផ្តល់សេវាហិរញ្ញវត្ថុដល់អតិថិជនដូចជា សេវាប្រាក់កម្ចី សេវាប្រាក់បញ្ញើ សេវាជួញដូរ មូលបត្រ សេវាធានារ៉ាប់រង សេវារបបសន្តិសុខសង្គម សេវាវិនិយោគជាដើម។ |

| | |
|---|---|
| ២៩- គ្រឹះស្ថានឥណទានជនបទ<br>អ. rural credit institution | គ្រឹះស្ថានហិរញ្ញវត្ថុមានឯកទេសក្នុងការផ្តល់ប្រាក់កម្ចីខ្នាតតូចនៅជនបទ ហើយមានដើមទុនអប្បបរមាតម្កល់នៅធនាគារជាតិតិចជាងប្រាក់តម្កល់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ |
| ៣០- ចងការ<br>អ. borrow/lend ( at interest )<br>បារ. emprunter/prêter ( avec intérêt ) | ឱ្យខ្ចីប្រាក់ឬខ្ចីប្រាក់ដោយមានការប្រាក់ទៅតាមការព្រមព្រៀងគ្នារវាងអ្នកឱ្យខ្ចីនិងអ្នកខ្ចី។ |
| ៣១- ច្រកបែងចែក<br>អ. distribution channel<br>បារ. chaîne de distribution/ canal de distribution | ផ្លូវដែលទំនិញនិងសេវាត្រូវបានចែកចាយដោយគិតចាប់ពីក្រោយការផលិតរហូតដល់ការប្រើប្រាស់។ |
| ៣២- តំណាងផ្នែកលក់<br>អ. sale representative<br>បារ. représentant des ventes/représentant commercial | អ្នកទាក់ទងអតិថិជន ដែលមានសមត្ថភាពយល់នូវអ្វីដែលអ្នកទិញចង់បាន ពន្យល់នីតិវិធីនៃការទិញ និង ធានាដល់ដំណើរការលក់ឱ្យបានរលូន។ |
| ៣៣- ថ្លៃ<br>អ. price<br>បារ. prix ( m. ) | ចំនួនប្រាក់នៃតម្លៃទំនិញឬសេវាចេញមកពីការដោះដូរ។ |
| ៣៤- ថ្លៃកម្រិត<br>អ. fixed price<br>បារ. prix fixe | ថ្លៃទំនិញឬសេវាដែលមិនអាចតថ្លៃបាន។ |
| ៣៥- ថ្លៃដើម<br>អ. cost<br>បារ. coût ( m. )/prix de revient | ចំនួនប្រាក់ចំណាយដើម្បីផលិតជាផលិតផល ឬសេវា ដូចជាចំណាយទៅលើវត្ថុធាតុដើម មូលធន កម្លាំងពលកម្ម និងសហគ្រិនភាព។ |
| ៣៦- ថ្លៃទីផ្សារ<br>អ. market price<br>បារ. prix de marché | ថ្លៃទិញឬលក់ជាទូទៅនៃទំនិញឬសេវានៅលើទីផ្សារ។ |

| | |
|---|---|
| ៣៧- ថ្លៃលក់<br>អ. selling price<br>បារ. prix de vente | ថ្លៃទំនិញឬសេវាដែលដាក់លក់នៅលើទីផ្សារ។ |
| ៣៨- ថ្លៃលក់ផ្ដាច់<br>អ. sale price<br>បារ. prix soldé | ថ្លៃទំនិញឬសេវាដែលលក់ដោយមានការបញ្ចុះថ្លៃរួច។ |
| ៣៩- ទ្រព្យ<br>អ. wealth<br>បារ. richesse ( f. ) | តម្លៃទ្រព្យសកម្មដែលមានក្រោយពីដកចេញនូវបំណុលដែលជំពាក់គេ។ |
| ៤០- ទ្រព្យសកម្ម<br>អ. assets<br>បារ. actifs ( m. pl. ) | ប្រាក់និងអ្វីៗផ្សេងទៀតដែលជាកម្មសិទ្ធិរបស់រូបវន្តបុគ្គលឬនីតិបុគ្គលហើយដែលអាចទូទាត់បំណុល ប្រើប្រាស់ ទទួលអត្ថប្រយោជន៍ និងបង្កើនប្រាក់ចំណូលបាន។ |
| ៤១- ទ្រព្យសកម្មចរន្ត<br>អ. current assets<br>បារ. actifs à court terme/ actifs courants | ទ្រព្យសកម្មដែលអាចបំប្លែងជាប្រាក់បានក្នុងរយៈពេលមួយខួបផលិតកម្ម ឬក្នុងរយៈពេលមិនលើសពីមួយឆ្នាំ។ |
| ៤២- ទ្រព្យសកម្មរូបី<br>អ. tangible assets<br>បារ. actifs corporels/actif tangible | ទ្រព្យសកម្មដែលមានរូប រួមមានទ្រព្យសកម្មចរន្តនិងទ្រព្យសកម្មអចល័ត។ |
| ៤៣- ទ្រព្យសកម្មអចល័ត<br>អ. fixed assets<br>បារ. immobilisations/ actifs immobilisés | ទ្រព្យសកម្មដែលអាចបំប្លែងជាប្រាក់បានក្នុងរយៈពេលច្រើនខួបផលិតកម្ម ឬ ក្នុងរយៈពេលលើសពីមួយឆ្នាំ។ |
| ៤៤- ទ្រព្យសកម្មអរូបី<br>អ. intangible assets<br>បារ. actif incorporel/actif intangible | ទ្រព្យសកម្មដែលមិនមានរូប ដូចជា កម្មសិទ្ធិបញ្ញា ប្រកាសនីយបត្រតក្កកម្ម ពាណិជ្ជសញ្ញា សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលវិធីសាស្ត្រធុរកិច្ច ជាដើម។ |

| | |
|---|---|
| **៤៥- ធនាគារ**<br>អ. bank<br>បារ. banque ( f. ) | គ្រឹះស្ថានហិរញ្ញវត្ថុដែលមាននីតិសម្បទាពិសេសក្នុងការរើសយកប្រតិបត្តិការដូចខាងក្រោមនេះជាមុខរបរ៖<br>- ការផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណជនដោយមានកម្រៃរាប់បញ្ចូលទាំងឥណទាន ភតិសន្យា និងការសន្យាតាមហត្ថលេខា។<br>- ការទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន ប្រព្រឹត្តិកម្ម និងការដាក់ឱ្យអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុឬជារូបិយបណ្ណ។ |
| **៤៦- ធនាគារកណ្តាល**<br>អ. central bank<br>បារ. banque centrale | ធនាគារសាធារណៈដែលមានសមត្ថកិច្ចផ្តាច់មុខលើ ៖<br>- ការកំណត់គោលនយោបាយរូបិយវត្ថុនិងការគ្រប់គ្រងចំនួនឥណទានសរុប<br>- ការគ្រប់គ្រងនិងការត្រួតពិនិត្យគ្រឹះស្ថានហិរញ្ញវត្ថុតាមរយៈការចេញប្រកាស បទបញ្ជា និងសេចក្តីណែនាំផ្សេងៗ។ |
| **៤៧- ធនាគារពាណិជ្ជ**<br>អ. commercial bank<br>បារ. banque commerciale | ធនាគារឯកជនដែលទទួលបានអាជ្ញាបណ្ណពីធនាគារកណ្តាលដើម្បីធ្វើប្រតិបត្តិការស្វែងរកប្រាក់ចំណេញ។ |
| **៤៨- ធនាគារឯកទេស**<br>អ. specialized bank<br>បារ. banque spécialisée | ធនាគារដែលអនុវត្តតែប្រតិបត្តិការមួយតាមជំនាញជាក់លាក់ក្នុងចំណោមប្រតិបត្តិការទាំងបីរបស់ធនាគារ។ |
| **៤៩- នាយកផ្នែកលក់**<br>អ. sale director<br>បារ. directeur de vente | អ្នកគ្រប់គ្រងម្នាក់ក្នុងចំណោមអ្នកគ្រប់គ្រងទាំងឡាយដែលទទួលបន្ទុករៀបចំយុទ្ធសាស្ត្រលក់និងទទួលខុសត្រូវចំពោះដំណើរការលក់ក្នុងអង្គភាពអាជីវកម្ម។ |
| **៥០- បញ្ចាំ**<br>អ. pawn<br>បារ. mettre en gage | ដាក់ទ្រព្យជាថ្នូរសម្រាប់ធានាយកប្រាក់កម្ចី។ |
| **៥១- បដិផរណា**<br>អ. disinflation<br>បារ. désinflation ( f. ) | ការធ្លាក់ចុះនៃអត្រាអតិផរណា។ |

| | |
|---|---|
| **៥២- បណ្ណធនាគារ**<br>អ. bank draft<br>បារ. traite bancaire/lettre de change bancaire | ឧបករណ៍ទូទាត់មួយប្រភេទ ដែលធនាគារពាណិជ្ជចេញឱ្យអតិថិជនដើម្បីឱ្យអ្នកកាន់បណ្ណនោះអាចដកប្រាក់ក្នុងចំនួនជាក់លាក់មួយពីគណនីរបស់ធនាគារនោះ ដែលមាននៅធនាគារអន្តរការី ឬ ធនាគារផ្សេងនៅឯក្រៅប្រទេស។ ជាទូទៅ បណ្ណធនាគារត្រូវបានគេប្រើជាឧបករណ៍សុវត្ថិភាពមួយដើម្បីទូទាត់ប្រាក់នៅក្រៅប្រទេស។ |
| **៥៣- បណ្ណបង់ប្រាក់មុន/ កាតបង់ប្រាក់មុន**<br>អ. prepaid card<br>បារ. carte prépayée | បណ្ណមួយប្រភេទដែលគេប្រើសម្រាប់ទូទាត់ថ្លៃទំនិញឬសេវាជាក់លាក់ជំនួសការទូទាត់ជាប្រាក់ ក្រោយពីគេបញ្ចូលប្រាក់ជាមុនក្នុងគណនី។ |
| **៥៤- បណ្ណឥណទាន**<br>អ. credit card<br>បារ. carte de crédit | បណ្ណប្រើសម្រាប់ទូទាត់ថ្លៃទំនិញ ឬ សេវាតាមចំនួនប្រាក់ដែលធនាគារបានកំណត់ហើយទូទាត់ឱ្យទៅធនាគារវិញនៅពេលក្រោយ។ |
| **៥៥- បណ្ណឥណពន្ធ**<br>អ. debit card<br>បារ. carte de débit | បណ្ណប្រើសម្រាប់ទូទាត់ថ្លៃទំនិញឬសេវាតាមចំនួនប្រាក់ដែលមាននៅក្នុងគណនីរបស់ម្ចាស់បណ្ណ។ |
| **៥៦- បណ្ណអេធីអឹម/ កាតអេធីអឹម**<br>អ. ATM card<br>បារ. carte GAB | បណ្ណដែលអតិថិជនប្រើជាមួយម៉ាស៊ីនអេធីអឹម/ម៉ាស៊ីនប្រតិបត្តិការធនាគារស្វ័យប្រវត្តសម្រាប់ធ្វើប្រតិបត្តិការជាមួយធនាគារតាមប្រព័ន្ធអេឡិចត្រូនិក។ |
| **៥៧- បណ្តាក់** | ផ្តល់ប្រាក់ឬទំនិញនិងទទួលប្រាក់ឬទំនិញ ដែលក្រោយមកអ្នកទទួលប្រាក់ឬទំនិញនោះត្រូវសងតាមចំនួននិងពេលកំណត់តាមការព្រមព្រៀង។ |
| **៥៨- បុល**<br>បារ. prêter/emprunter à usure | ផ្តល់ប្រាក់ឬផ្តល់ទំនិញនិងទទួលប្រាក់ ឬទំនិញក្រៅប្រព័ន្ធដែលក្រោយមកកូនបំណុលនោះត្រូវសងប្រាក់ ឬទំនិញនោះមួយជាពីរតាមពេលកំណត់ និងតាមការព្រមព្រៀង។ |
| **៥៩- បេឡាធិការ**<br>អ. cashier<br>បារ. caissier ( m. ) | អ្នកទទួលខុសត្រូវប្រតិបត្តិការទទួលប្រាក់និងបញ្ចេញប្រាក់នៅក្នុងស្ថាប័នរដ្ឋក្រុមហ៊ុនឯកជនជាដើម។ |

| | |
|---|---|
| **៦០- ប្រតិបត្តិករផ្នែកលក់**<br>អ. sale executive<br>បារ. responsable de vente/<br>cadre commercial/<br>cadre de vente | បុគ្គលិកគន្លឹះសម្រាប់ការទាក់ទងរវាងអង្គភាពអាជីវកម្មនិងអតិថិជនដើម្បីឆ្លើយតបសំណួរនិងសំណូមពរ បង្ហាញផលិតផលថ្មីៗ តាំងពិពណ៌និងផ្ដួចផ្ដើមគំនិតថ្មីក្នុងការលក់ផលិតផល។ |
| **៦១- ប្រធានក្រុមផ្នែកលក់**<br>អ. sale team leader<br>បារ. chef d'équipe de vente | អ្នកដឹកនាំក្រុមអ្នកលក់ ដែលទទួលភារកិច្ចផ្ទាល់ពីប្រធានផ្នែកលក់ដើម្បីធ្វើឱ្យសម្រេចបានគោលដៅការលក់ប្រចាំថ្ងៃនិងទទួលបានការពេញចិត្តពីអតិថិជន។ |
| **៦២- ប្រធានផ្នែកលក់**<br>អ. head of sales<br>បារ. chef de vente | អ្នកទទួលខុសត្រូវផ្នែកមួយនៃការលក់ ហើយស្ថិតនៅក្រោមអ្នកគ្រប់គ្រងផ្នែកលក់។ |
| **៦៣- ប្រវាស់** | ចូលហ៊ុនរកស៊ី ដោយភាគីម្ខាងមានរបស់ទ្រព្យ ភាគីម្ខាងទៀតមានកម្លាំងពលកម្មនិងមធ្យោបាយផ្សេងៗទទួលអនុវត្តការងារហើយបែងចែកផលប្រយោជន៍តាមការព្រមព្រៀង។ |
| **៦៤- ប្រាក់**<br>អ. cash<br>បារ. monnaie ( f. ) | រូបិយវត្ថុមានទម្រង់រូបវន្តជាក្រដាសនិងកាស។ |
| **៦៥- បំណុល**<br>អ. debt<br>បារ. dette ( f. ) | ប្រាក់ ទំនិញ សេវា ឬកាតព្វកិច្ចសរុបដែលអ្នកជំពាក់ត្រូវសងតាមលក្ខខណ្ឌនៃកិច្ចសន្យា។ |
| **៦៦- ផលិតផល**<br>អ. product<br>បារ. produit ( m. ) | ទំនិញឬសេវាដែលបានបង្កើតឡើង ដើម្បីបំពេញតម្រូវការអតិថិជនដោយអាចរួមបញ្ចូលទាំងព័ត៌មានអំពីធាតុផ្សំ អត្ថប្រយោជន៍ លក្ខណៈពិសេស របៀបប្រើប្រាស់។ល។ |
| **៦៧- ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.)**<br>អ. gross domestic product ( GDP )<br>បារ. produit intérieur brut ( PIB ) | តម្លៃសរុបនៃទំនិញ និងសេវាដែលបានផលិតដោយប្រជាជនក្នុងប្រទេសណាមួយក្នុងរយៈពេលមួយឆ្នាំ ដោយមិនរាប់បញ្ចូលតម្លៃនៃប្រាក់ចំណូលបានពីបរទេសទេ។ |

| | |
|---|---|
| **៦៨- ផលិតផលជាតិសរុប (ផ.ជ.ស.)**<br>អ. gross national product (GNP)<br>បារ. produit national brut (PNB) | តម្លៃសរុបនៃទំនិញនិងសេវាដែលបានផលិតដោយប្រជាជននៃប្រទេសណាមួយក្នុងរយៈពេលមួយឆ្នាំ។ |
| **៦៩- ផែនការអាជីវកម្ម/ ផែនការធុរកិច្ច**<br>អ. business plan<br>បារ. projet commercial | ឯកសារជាលាយលក្ខណ៍អក្សរពិពណ៌នាអំពីជំហានចាំបាច់ទាំងអស់ ដើម្បីចាប់ផ្តើម និង ប្រតិបត្តិការអាជីវកម្មឱ្យបានជោគជ័យ។ ចំណុចសំខាន់ៗនៃផែនការអាជីវកម្មមានដូចជា គោលបំណង គោលដៅ សកម្មភាព ធនធានមនុស្ស ថវិកាដែលត្រូវចំណាយជាដើម។ |
| **៧០- ពន្ធ**<br>អ. tax<br>បារ. impôt (m.) | ប្រាក់ដែលនីតិបុគ្គលឬរូបវន្តបុគ្គលជាប់កាតព្វកិច្ចត្រូវបង់ជូនរដ្ឋតាមការកំណត់ សម្រាប់ចំណាយសាធារណៈ។ |
| **៧១- ពន្ធគយ**<br>អ. custom duty<br>បារ. droits de douane | ពន្ធយកលើទំនិញនាំចេញ នាំចូល ឬ ឆ្លងកាត់ប្រទេសណាមួយ។ |
| **៧២- ពន្ធដារ**<br>អ. taxation<br>បារ. imposition (f.)/ impôts (m.) | ១- ប្រព័ន្ធនៃការប្រមូលពន្ធរបស់រដ្ឋាភិបាលពីអ្នកជាប់ពន្ធ សម្រាប់ចំណាយសាធារណៈ។<br>២- ពន្ធគ្រប់ប្រភេទ។ |
| **៧៣- ពន្ធប្រយោល/ ពន្ធមិនចំពោះ**<br>អ. indirect tax<br>បារ. impôt indirect | ពន្ធលើទំនិញនិង/ឬសេវាដែលអ្នកប្រើប្រាស់ចុងក្រោយបង់ជូនរដ្ឋតាមរយៈអ្នកផ្គត់ផ្គង់។ |
| **៧៤- ពន្ធផ្ទាល់/ពន្ធចំពោះ**<br>អ. direct tax<br>បារ. impôt direct | ពន្ធលើប្រាក់ចំណូល ចលនទ្រព្យ អចលនទ្រព្យ...ដែលអ្នកជាប់ពន្ធត្រូវបង់ដោយផ្ទាល់ជូនរដ្ឋ។ |

| | |
|---|---|
| **៧៥- ពន្ធលើឈ្នួលផ្ទះនិងដី**<br>អ. tax on property rental<br>បារ. impôt sur le loyer | ពន្ធប្រមូលពីកម្មសិទ្ធិករឬសិទ្ធិវន្តរបស់កម្មសិទ្ធិករដែលកំណត់លើការជួលផ្ទះ អគារ រោងចក្រ រោងជាង ឃ្លាំង ព្រមទាំងដីធ្លីដែលគ្មានសំណង់ ជាដើម គិតជាភាគរយនៃប្រាក់ឈ្នួលដុល។ |
| **៧៦- ពន្ធលើប្រាក់ចំណូល**<br>អ. income tax<br>បារ. impôt sur le revenu | នៅកម្ពុជា ពន្ធដែលត្រូវបានកំណត់លើអ្នកជាប់ពន្ធនិវាសនជនចំពោះប្រាក់ចំណូល ប្រភពក្នុងប្រទេស និង ប្រាក់ចំណូលប្រភពបរទេស ប៉ុន្តែចំពោះអនិវាសនជន ពន្ធលើប្រាក់ចំណូល កំណត់តែលើប្រាក់ចំណូល ប្រភពក្នុងប្រទេសប៉ុណ្ណោះ។ |
| **៧៧- ភតិកៈ**<br>អ. lessee<br>បារ. locataire (m.)/<br>preneur à bail | ភាគីម្ខាងនៃភតិសន្យាដែលសន្យាថានឹងបង់ថ្លៃឈ្នួលដើម្បីជាថ្នូរនឹងការទទួលបាននូវសិទ្ធិប្រើប្រាស់និងអាស្រ័យផលពីចលនវត្ថុណាមួយរបស់ភតិបតី។ |
| **៧៨- ភតិបតី**<br>អ. lessor<br>បារ. bailleur (m.) | ភាគីម្ខាងនៃភតិសន្យាដែលសន្យាថាឱ្យភតិកៈប្រើនិងអាស្រ័យផលពីវត្ថុណាមួយដោយយកថ្លៃឈ្នួល។ |
| **៧៩- ភតិសន្យា**<br>អ. lease<br>បារ. bail (m.) | ១- កិច្ចសន្យាដែលភាគីម្ខាងជួលវត្ថុណាមួយឱ្យភាគីម្ខាងទៀត ដើម្បីប្រើប្រាស់និងអាស្រ័យផល ដោយយកថ្លៃឈ្នួលតាមលក្ខខណ្ឌដែលបានកំណត់។<br>២- ប្រតិបត្តិការដែលភតិបតីចុះកិច្ចព្រមព្រៀងជាមួយភតិកៈ ក្នុងនោះភតិកៈត្រូវបានផ្តល់សិទ្ធិឱ្យកាន់កាប់និងប្រើប្រាស់ចលនវត្ថុក្នុងរយៈពេលមួយដោយការបង់ថ្លៃឈ្នួលតាមគ្រាឬតាមតម្លៃសមមូល។ ភតិសន្យាត្រូវរួមបញ្ចូលទាំងភតិសន្យាបន្តផងដែរ។ (ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុមាត្រា៤) |
| **៨០- ភតិសន្យាបន្ត**<br>អ. sublease<br>បារ. sous-bail (m.) | កិច្ចសន្យាដែលភតិកៈដំបូងបានជួលទ្រព្យសកម្មពីភតិបតី រួចហើយជួលបន្តឱ្យភតិកៈមួយទៀត ដោយក្នុងនោះភតិសន្យាដំបូងនៅមានសុពលភាពដដែល។ |
| **៨១- ភតិសន្យាហិរញ្ញវត្ថុ**<br>អ. finance lease<br>បារ. prêt financier/<br>bail financier | ភតិសន្យាដែលភតិកៈបញ្ជាក់ច្បាស់លាស់នូវចលនវត្ថុនិងជ្រើសរើសអ្នកផ្គត់ផ្គង់ដោយខ្លួនឯងហើយភតិបតីទិញចលនវត្ថុតាមកិច្ចព្រមព្រៀងដើម្បីជួលឱ្យភតិកៈ។ |

| | |
|---|---|
| **៨២- ម៉ាក្រូម៉ាឃិធីង/ ម៉ាក្រូកិច្ចទីផ្សារ**<br>អ. macromarketing/ macro-marketing/ macromarketing<br>បារ. macromarketing ( m. )/ macro-marketing( m. ) | សំណុំសកម្មភាពនិងដំណើរការកិច្ចទីផ្សារនៃទំនិញ ឬសេវាក្នុងកម្រិតប្រទេស ឬសង្គមជាតិដោយមានការទទួលខុសត្រូវសង្គម។ |
| **៨៣- ម៉ាក្រូសេដ្ឋកិច្ច**<br>អ. macroeconomics<br>បារ. macroéconomie ( f. ) | ផ្នែកមួយនៃវិទ្យាសាស្ត្រសេដ្ឋកិច្ចសិក្សាអំពីប្រព័ន្ធសេដ្ឋកិច្ចជាតិទាំងមូលដែលផ្ដោតទៅលើចំណូលជាតិ កំណើនសេដ្ឋកិច្ច និកម្មភាព អតិផរណា ជាដើម។ |
| **៨៤- ម៉ាស៊ីនទទួលប្រាក់បញ្ញើ**<br>អ. cash deposit machine ( CDM )<br>បារ. machine de dépôt en espèces | ម៉ាស៊ីនអេឡិចត្រូនិកស្វ័យប្រវត្តដែលអនុញ្ញាតឱ្យអតិថិជនដាក់ប្រាក់បញ្ញើចូលក្នុងគណនីបានគ្រប់ពេលវេលាដោយការប្រើប្រាស់បណ្ណអេធីអឹម ( កាតអេធីអឹម )និងលេខសម្ងាត់ផ្ទាល់ខ្លួន។ |
| **៨៥- ម៉ាស៊ីនអេធីអឹម/ ម៉ាស៊ីនប្រតិបត្តិការធនាគារស្វ័យប្រវត្ត**<br>អ. automatic teller machine ( ATM )<br>បារ. guichet automatique bancaire ( GAB ) | ម៉ាស៊ីនអេឡិចត្រូនិកស្វ័យប្រវត្តដែលអតិថិជនអាចធ្វើប្រតិបត្តិការដកប្រាក់ ដាក់ប្រាក់ ផ្ទេរប្រាក់ ទូទាត់។ល។ បានគ្រប់ពេលវេលាដោយការប្រើប្រាស់បណ្ណអេធីអឹម( កាតអេធីអឹម )និងលេខសម្ងាត់ផ្ទាល់ខ្លួន។ |
| **៨៦- មីក្រូម៉ាឃិធីង**<br>អ. micromarketing/ micro marketing<br>បារ. micromarketing/ micro marketing | សំណុំសកម្មភាពនិងដំណើរការកិច្ចទីផ្សាររបស់សហគ្រាសណាមួយអំពីផលិតផល ឬសេវារបស់ខ្លួនឆ្ពោះទៅក្រុមអតិថិជនជាក់លាក់។ |
| **៨៧- មីក្រូសហគ្រាស**<br>អ. micro enterprise<br>បារ. micro-entreprise | សហគ្រាសដែលមានទុនសមមូលសរុបតិចជាង២០០លានរៀល ឬមានបុគ្គលិកពេញម៉ោងតិចជាង១០នាក់ ឬមានផលរបរប្រចាំឆ្នាំតិចជាង២៥០លានរៀល។ តួលេខនេះប្រើក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម ដែលមានអត្រាប្ដូរប្រាក់១ដុល្លារ ស្មើនឹង៤ ០០០រៀល។ |

| | |
|---|---|
| **៨៨- មីក្រូសេដ្ឋកិច្ច**<br>អ. microeconomics<br>បារ. microéconomie (f.) | ផ្នែកមួយនៃវិទ្យាសាស្ត្រសេដ្ឋកិច្ចសិក្សាអំពីឥរិយាបថរបស់បុគ្គល ក្រុមហ៊ុន ឬស្ថាប័នដែលពាក់ព័ន្ធទៅនឹងជម្រើសនិងការសម្រេចចិត្តក្នុងការឆ្លើយតបនឹងថ្លៃទំនិញនិងតម្រូវការក្នុងទីផ្សារ។ |
| **៨៩- មូលធននិយម**<br>អ. capitalism<br>បារ. capitalisme (m.) | ប្រព័ន្ធសេដ្ឋកិច្ចមួយដែលនៅក្នុងនោះមធ្យោបាយផលិតកម្មជាកម្មសិទ្ធិរបស់ម្ចាស់ទុនឯកជនដែលធ្វើប្រតិបត្តិការដើម្បីស្វែងរកប្រាក់ចំណេញ។ |
| **៩០- មូលប្បទានបត្រ/សែក**<br>អ. cheque<br>បារ. chèque (m.) | បណ្ណបោះពុម្ពដោយគ្រឹះស្ថានហិរញ្ញវត្ថុណាមួយដែលនៅពេលម្ចាស់គណនីចុះហត្ថលេខាលើបណ្ណនោះ គ្រឹះស្ថានហិរញ្ញវត្ថុសាមីត្រូវទូទាត់ប្រាក់ឱ្យអ្នកត្រូវទទួលទៅតាមលក្ខខណ្ឌ។ |
| **៩១- ម្ចាស់បំណុល**<br>អ. debtee<br>បារ. créancier (m.) | បុគ្គលដែលគេត្រូវសងបំណុល។ |
| **៩២- រតនាគារជាតិ**<br>អ. national treasury<br>បារ. trésor national | ស្ថាប័នជាតិទទួលបន្ទុកជាបេឡាធិការនិងគណនេយ្យករសាធារណៈ។ |
| **៩៣- លុយរាប់** | ប្រាក់ដែលជាទូទៅអ្នកខ្ចីត្រូវសងជាចំណែកៗស្មើរៀងរាល់ថ្ងៃ ទាំងដើម ទាំងការទៅម្ចាស់លុយតាមការព្រមព្រៀង។ |
| **៩៤- វិច្ឆិន្នភាព**<br>អ. severability<br>បារ. divisibilité (f.)/<br>séparabilité (f.) | ភាពនៃការអាចអនុវត្តបាននៃគម្រោងវិនិយោគ ទោះបីជាប្រការណាមួយនៃកិច្ចព្រមព្រៀងវិនិយោគនោះ មិនអាចអនុវត្តបានក៏ដោយ។ |
| **៩៥- សហគ្រាស**<br>អ. enterprise<br>បារ. entreprise (f.) | អង្គភាព ឬគ្រឹះស្ថានដែលមានគោលដៅស្វែងរកប្រាក់ចំណេញ រួមមានសហគ្រាសសាធារណៈ និង សហគ្រាសឯកជន រួមទាំងគ្រឹះស្ថានហិរញ្ញវត្ថុ និង សហគ្រាសធុនតូចនិងមធ្យមព្រមទាំងមីក្រូសហគ្រាសផងដែរ។ |

| | |
|---|---|
| **៩៦- សហគ្រាសធុនតូច**<br>អ. small enterprise<br>បារ. petite entreprise | សហគ្រាសដែលមានទុនសមមូលចន្លោះពី២០០លានរៀលទៅក្រោម ២៥០ លានរៀល ឬមានបុគ្គលិកពេញម៉ោងចន្លោះពី១១ដល់៥០នាក់ ឬមានផល របរប្រចាំឆ្នាំចាប់ពី២៥០លានរៀលដល់៧០០លានរៀល។ តួលេខនេះប្រើក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម ដែលមានអត្រាប្តូរប្រាក់១ដុល្លារ ស្មើនឹង ៤ ០០០រៀល។ |
| **៩៧- សហគ្រាសធុនធំ**<br>អ. large enterprise<br>បារ. grande entreprise | សហគ្រាសដែលមានទុនសមមូលចាប់ពី២ ០០០លានរៀលឡើងទៅ ឬមានបុគ្គលិកពេញម៉ោងលើសពី១០០នាក់ឬមានផលរបរប្រចាំឆ្នាំលើសពី ២ ០០០លានរៀល។ តួលេខនេះប្រើក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម ដែលមានអត្រាប្តូរប្រាក់ ១ដុល្លារ ស្មើនឹង៤ ០០០រៀល។ |
| **៩៨- សហគ្រាសធុនមធ្យម**<br>អ. medium enterprise<br>បារ. moyenne entreprise | សហគ្រាសដែលមានទុនសមមូលចន្លោះពី ២៥០លានរៀលទៅក្រោម ២ ០០០លានរៀល ឬ មានបុគ្គលិកពេញម៉ោងចន្លោះពី៥១ដល់១០០នាក់ ឬមានផលរបរប្រចាំឆ្នាំ ចាប់ពី៧០០លានរៀលដល់២ ០០០លានរៀល។ តួលេខនេះប្រើក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម ដែលមានអត្រាប្តូរប្រាក់ ១ដុល្លារ ស្មើនឹង៤ ០០០រៀល។ |
| **៩៩- សហគ្រាសសាធារណៈ**<br>អ. public enterprise<br>បារ. entreprise publique | សហគ្រាសមានដើមទុនទាំងអស់ឬភាគច្រើនជារបស់រដ្ឋមានទម្រង់ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនចម្រុះ ដែលក្នុងនោះរដ្ឋកាន់កាប់លើសពី៥០%នៃដើមទុនក្រុមហ៊ុនឬសិទ្ធិបោះឆ្នោត។ |
| **១០០- សហគ្រាសឯកជន**<br>អ. private enterprise<br>បារ. entreprise privée | អង្គភាពអាជីវកម្មមិនមែនជាកម្មសិទ្ធិរបស់រដ្ឋ ដែលបង្កើតឡើងដើម្បីស្វែងរកប្រាក់ចំណេញ។ |
| **១០១- សហគ្រាសឯកបុគ្គល**<br>អ. sole proprietorship<br>បារ. entreprise individuelle | សហគ្រាសអាជីវកម្មដែលជាកម្មសិទ្ធិ១០០%របស់រូបវន្តបុគ្គលណាម្នាក់។ (ក្នុងច្បាប់ស្តីពីសារពើពន្ធ ប្តី ប្រពន្ធ និងកូនក្នុងបន្ទុកត្រូវចាត់ទុកជា រូបវន្ត-បុគ្គលតែម្នាក់) |

| | |
|---|---|
| **១០២- សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត**<br>អ. single member private limited company<br>បារ. entreprise unipersonnelle à responsabilité limitée ( EURL ) | ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលមានម្ចាស់ភាគហ៊ុនតែម្នាក់។ |
| **១០៣- សហគ្រិនភាព**<br>អ. entrepreneurship<br>បារ. esprit d'entreprise | សមត្ថភាពនិងឆន្ទៈ ដើម្បីបង្កើត ចាត់ចែង និងគ្រប់គ្រងអាជីវកម្មណាមួយដែលអាចមានហានិភ័យក្នុងគោលបំណងទទួលបានប្រាក់ចំណេញ និងធានាបាននូវសុខុមាលភាពសង្គម។ ចរិតនៃសហគ្រិនភាពកំណត់ដោយនវានុវត្តន៍ និងការប្រឈមនឹងហានិភ័យ។ |
| **១០៤- សេញ៉រិច**<br>អ. seigniorage<br>បារ. seigneuriage ( m. ) | ប្រាក់ចំណូលដែលរដ្ឋាភិបាលបានពីការបោះពុម្ពរូបិយវត្ថុ ជាពិសេសគឺភាពខុសគ្នារវាងថ្លៃដើមនៃការផលិតរូបិយវត្ថុនិងថ្លៃចារឹកនៅលើរូបិយវត្ថុនោះ។ |
| **១០៥- សេវាធនាគារចល័ត/ធនាគារកិច្ចចល័ត**<br>អ. mobile banking<br>បារ. service bancaire mobile | សេវាផ្តល់ដោយធនាគារឬគ្រឹះស្ថានហិរញ្ញវត្ថុដែលអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុពីចម្ងាយដោយប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកចល័ត ដូចជា ទូរសព្ទដៃ កុំព្យូទ័រ ជាដើម និងដោយប្រើកម្មវិធីរបស់ធនាគារ ឬ គ្រឹះស្ថានហិរញ្ញវត្ថុនោះ។ |
| **១០៦- ហិរញ្ញប្បទានផ្ទាល់**<br>អ. direct financing<br>បារ. financement direct | ការផ្តល់ធនធានហិរញ្ញវត្ថុពីអ្នកផ្តល់ទៅអ្នកទទួលដោយមិនចាំបាច់ឆ្លងកាត់អន្តរការីហិរញ្ញវត្ថុ។ |
| **១០៧- ហិរញ្ញប្បទានមិនផ្ទាល់**<br>អ. indirect financing<br>បារ. financement indirect | ការផ្តល់ធនធានហិរញ្ញវត្ថុពីអ្នកផ្តល់ទៅអ្នកទទួលតាមរយៈអន្តរការីហិរញ្ញវត្ថុ។ |
| **១០៨- ឥណទាន**<br>អ. credit<br>បារ. crédit ( m. ) | ១- វិធីដែលអ្នកខ្ចីទទួលបានប្រាក់ ទំនិញ ឬសេវាដោយយល់ព្រមទូទាត់សងជាមួយនឹងការប្រាក់តាមកាលបរិច្ឆេទជាក់លាក់នាពេលអនាគត។<br>២- ប្រាក់ ទំនិញ ឬសេវាសម្រាប់ឱ្យគេខ្ចីហើយដែលអ្នកខ្ចីយល់ព្រមទូទាត់សងជាមួយនឹងការប្រាក់តាមកាលបរិច្ឆេទជាក់លាក់នាពេលអនាគត។ |

| | |
|---|---|
| **១០៩- ឥណទាយក**<br>អ. creditor<br>បារ. créditeur ( m. ) | បុគ្គលដែលមានឥណទានក្នុងគណនីណាមួយ។ |
| **១១០- អតិផរណា**<br>អ. inflation<br>បារ. inflation ( f. ) | ការកើនឡើងនៃកម្រិតថ្លៃជាទូទៅរបស់ទំនិញនិងសេវាក្នុងប្រទេស ឬតំបន់ក្នុងរយៈពេលជាក់លាក់ណាមួយ។ |
| **១១១- អតិផរណាជាថ្មី/ បុនាតិផរណា**<br>អ. reinflation<br>បារ. réinflation ( f. ) | ការកើនឡើងវិញនៃអត្រាអតិផរណា។ |
| **១១២- អតិផរណាហួសហេតុ/ អធិកផរណា**<br>អ. hyperinflation<br>បារ. hyperinflation ( f. ) | ការកើនឡើងខ្លាំងហើយលឿនក្នុងរយៈពេលខ្លីដែលមិនអាចគ្រប់គ្រងបាននៃអត្រាអតិផរណា។ |
| **១១៣- អប្បផរណា/ បរិត្តផរណា**<br>អ. deflation<br>បារ. déflation ( f. ) | ការធ្លាក់ចុះនៃកម្រិតថ្លៃជាទូទៅរបស់ទំនិញនិងសេវាក្នុងប្រទេសឬតំបន់ក្នុងរយៈពេលជាក់លាក់ណាមួយ ក្នុងពេលដែលអត្រាអតិផរណាធ្លាក់ចុះក្រោមសូន្យភាគរយ។ |
| **១១៤- អប្បផរណាករ/ជផ្លាទ័រ / បរិត្តផរណាករ**<br>អ. deflator<br>បារ. déflateur ( m. ) | អត្រាអតិផរណាដែលប្រើជាតួចែកដើម្បីបំប្លែងថ្លៃទំនិញនិងសេវាពីចំនួនណូមីណាល់ទៅចំនួនពិត។ |
| **១១៥- អាករលើតម្លៃបន្ថែម (អ.ត.ប.)**<br>អ. value added tax ( VAT )<br>បារ. taxe sur la valeur ajoutée ( T.V.A. ) | ពន្ធប្រយោលមួយប្រភេទដាក់លើទំនិញ ឬសេវាណាមួយនៅពេលដែលតម្លៃត្រូវបានបន្ថែមនៅគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផ្គត់ផ្គង់ពីចំណុចផលិតកម្មទៅដល់ចំណុចលក់។ |

| | |
|---|---|
| **១១៦- អាជីវករប្តូរប្រាក់**<br>អ. money changer | អ្នកប្រកបមុខរបរប្តូរប្រាក់ដែលមានអាជ្ញាបណ្ណ។ |
| **១១៧- អ្នកគ្រប់គ្រងផ្នែកលក់**<br>អ. sales manager<br>បារ. chef des ventes | អ្នកអនុវត្តយុទ្ធសាស្ត្រលក់ដោយកំណត់គោលដៅ កម្រិតចំនួននៃការលក់ រៀបចំផែនការលក់ វិភាគទិន្នន័យ រៀបចំបណ្តុះបណ្តាល របៀបលក់ កំណត់ទីតាំងលក់ និងត្រួតពិនិត្យសមាជិកក្រុមអ្នកលក់។ |
| **១១៨- អ្នកជាប់ពន្ធ**<br>អ. taxpayer<br>បារ. contribuable ( n. ) | រូបវន្តបុគ្គលឬនីតិបុគ្គលដែលជាប់កាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។ |
| **១១៩- អ្នកដំណើរការតតិយភាគី/ប្រតិបត្តិករតតិយភាគី**<br>អ. third-party processor<br>បារ. processeur tiers | រូបវន្តបុគ្គលឬនីតិបុគ្គលដែលធនាគារបានប្រគល់សិទ្ធិឱ្យធ្វើប្រតិបត្តិការលើមួយ ឬច្រើនផ្នែកនៃសេវាប្រតិបត្តិការទូទាត់ប្រាក់របស់ធនាគារ។ |
| **១២០- អ្នកត្រួតពិនិត្យផ្នែកលក់**<br>អ. sale supervisor<br>បារ. superviseur de vente | អ្នកទទួលខុសត្រូវបន្ទាប់ពីប្រធានផ្នែកលក់ ដែលទទួលបន្ទុកអនុវត្តផែនការលក់ និងគ្រប់គ្រងបុគ្គលិកផ្នែកលក់ក្នុងអង្គភាពអាជីវកម្ម។ |
| **១២១- អ្នកសម្របសម្រួលផ្នែកលក់**<br>អ. sale coordinator<br>បារ. coordinateur de vente | អ្នកទទួលខុសត្រូវសម្របសម្រួលក្រុមអ្នកលក់ មានភារកិច្ចគ្រប់គ្រងពេលវេលាលក់ បំពេញឯកសារសំខាន់ៗ ផ្តល់និងទទួលព័ត៌មានពាក់ព័ន្ធការលក់ និងដោះស្រាយបញ្ហានានាដែលកើតចេញពីអតិថិជន។ |
| **១២២- អ្នកឯកទេសផ្នែកលក់**<br>អ. sale specialist<br>បារ. spécialiste de vente | អ្នកលក់ទំនិញផ្ទាល់ដែលមានចំណេះដឹងបច្ចេកទេសច្បាស់លាស់អំពីផលិតផល។ |

# ២- បច្ចេកសព្ទស្នើដោយគណៈកម្មការទស្សនវិជ្ជា

| | |
|---|---|
| **១-ករុណា**<br>អ. mercy/compassion<br>បារ. merci/compassion (f.) | ការតម្រូវខាងសីលធម៌ឱ្យមនុស្សម្នាក់ៗគួរប្រឹងប្រែងអស់ពីលទ្ធភាព ដើម្បីកាត់បន្ថយការលំបាកខាងផ្លូវកាយ ឬ ផ្លូវចិត្ត និងខាងសម្ភារៈរបស់អ្នកដទៃ។ |
| **២- កាតាឡិបស៊ីស**<br>អ. katalepsis<br>បារ. katalepsis (m.) | តាមទស្សនវិទូអត់ធ្មត់និយម មានន័យថា មូលបដិញ្ញាចម្បងបែបមនោគមវិជ្ជា ដោយចាត់ទុកថា សភាពចិត្តរបស់អ្នកណាម្នាក់ជាប់ពាក់ព័ន្ធទៅនឹងការយល់ដឹង និងការទទួលយកបញ្ញត្តិទស្សនវិជ្ជាមូលដ្ឋាននានា។ តាមភាសាក្រិក ពាក្យកាតាឡិបស៊ីសមានន័យថា ការចាប់យក។ |
| **៣- ការកុហក**<br>អ. lying<br>បារ. mentir (m.) | ការនិយាយ ការសរសេរ ឬការសម្តែងដោយកាយវិការនូវអ្វីមួយ ដែលអ្នកណាម្នាក់ដឹងឬជឿថាមិនពិតដោយចេតនា ដើម្បីបំភាន់មនុស្សម្នាក់ឬច្រើននាក់។ អ្នកកុហកមានអ្វីមួយនៅក្នុងចិត្តរបស់ខ្លួន ហើយបានបញ្ជាក់ដោយការអះអាងផ្ទុយពីនេះក្នុងបំណងបញ្ឆោត ឬយ៉ាងហោចណាស់ ដើម្បីបិទបាំងលទ្ធភាពនៃការបញ្ឆោត។ (ពាក្យនេះ គេប្រើក្នុងសីលវិជ្ជា) |
| **៤- ការបង្កើតថ្មី**<br>អ. creativity<br>បារ. créativité (f.) | ជាទូទៅ ការបង្កើតថ្មីសំដៅយកការបង្កើតអ្វីមួយដែលថ្មី ដែលរួមទាំងវត្ថុរូបី និងគំនិត។ ការបង្កើតថ្មីត្រូវបានគេប្រើយ៉ាងទូលំទូលាយនៅក្នុងសកម្មភាពរបស់មនុស្ស ប៉ុន្តែវាមានសារៈសំខាន់ដោយឡែកនៅក្នុងការបង្កើតសិល្បៈ។ ការបង្កើតថ្មីបង្ហាញនូវភាពថ្មី និងពាក់ព័ន្ធជាមួយការបង្កើតអ្វីមួយដែលខុសពីអ្វីដែលបានបង្កើតពីមុន ប៉ុន្តែវាក៏ពង្រីកទៅហួសពីអ្វីដែលគ្រាន់តែជាភាពថ្មីដែរ។<br>(ពាក្យនេះ គេប្រើនៅក្នុងសោភណវិជ្ជា) |
| **៥- ការបាត់ស្ទើយគ្រប់គ្រង**<br>អ. ecstasy<br>បារ. extase | សភាពមួយដែលការទទួលដឹងដោយញាណធម្មតាឈប់ដំណើរការមួយរយៈ ហើយប្រធានបែរជាដឹងពីភាពអស្ចារ្យជាងមុនប្រកបដោយភាពសប្បាយរីករាយ ប៉ុន្តែបន្ទាប់មកអ្វីដែលប្រធានដឹងនោះ មិនអាចទទួលដឹងបានជាធម្មតានោះទេ។ ម្យ៉ាងទៀត ការបាត់ស្ទើយគ្រប់គ្រងជាសភាពខាងខួរក្បាល ជាធម្មតាបង្កដោយការឆ្លងកាត់បទពិសោធន៍គម្ពីរនិយមជ្រុលខាងសាសនា ការត្រេកត្រអាលផ្លូវភេទ ឬការញៀនគ្រឿងញៀន...ក្នុងនោះ ពេលខ្លះ បុគ្គលបានបាត់ស្ទើយគ្រប់គ្រង និងសម្បជញ្ញៈដោយសារតែការគ្របដណ្តប់ពីវេទនារម្មណ៍យ៉ាងខ្លាំង។ |
| **៦- ការយល់សប្តិ/សុបិន**<br>អ. dream<br>បារ. rêve (m.) | ស៊េរី(ដំណើរបន្តគ្នា)នៃរូបភាព គំនិត វេទនារម្មណ៍ និងឥន្ទ្រីយារម្មណ៍ ដែលជាធម្មតាកើតឡើងដោយអចេតនានៅក្នុងចិត្តក្នុងរយៈពេលនៃដំណាក់កាលណាមួយនៃដំណេក។ ថ្វីបើខ្លឹមសារនិងគោលបំណងនៃការយល់សប្តិមិនត្រូវបានគេយល់ដឹងពេញលេញក៏ដោយ ក៏ការយល់សប្តិបានក្លាយទៅជាប្រធានបទនៃការសន្មតបែបវិទ្យាសាស្ត្រ ហើយវាក៏ជាប្រធានបទនៃចំណាប់អារម្មណ៍ខាង |

| | |
|---|---|
| | ទស្សនវិជ្ជានិងសាសនា តាំងពីមានការកត់ត្រានៅក្នុងប្រវត្តិសាស្ត្រ។ ការសិក្សាបែបវិទ្យាសាស្ត្រអំពីការយល់សប្តិត្រូវបានគេហៅថា សុបិនវិទ្យា(Oneirology)។ |
| **៧- ការសម្រុះសម្រួល**<br>អ. compromise<br>បារ. compromis (m.) | ការព្រមព្រៀងមួយដែលសម្រេចឡើងដោយភាគីពាក់ព័ន្ធតាមរយៈការចរចារួមគ្នា បន្ទាប់ពីភាគីនីមួយៗបានធ្វើសម្បទានមួយចំនួនចេញពីការទាមទារដំបូងៗរបស់ខ្លួន ដើម្បីអាចទទួលយកបានទាំងអស់គ្នា។ ការសម្រុះសម្រួលផ្អែកលើមូលដ្ឋានដែលភាគីនីមួយៗធ្វើសហប្រតិបត្តិការក្នុងការដោះស្រាយបញ្ហាជាជាងការធ្វើឱ្យខូចទំនាក់ទំនង។<br>(ពាក្យនេះ គេប្រើនៅក្នុងសីលវិជ្ជា និងទស្សនវិជ្ជានយោបាយ) |
| **៨- ការុញ្ញហេតុ**<br>អ. pathos<br>បារ. pathos (m.) | អំណាចនៃស្ថានភាព ឬស្នាដៃនិពន្ធ ឬស្នាដៃសិល្បៈ ឬក៏វោហារសាស្ត្រដែលជំរុញឱ្យមនុស្សមានភាពទុក្ខព្រួយនិងការអាណិតអាសូរ។<br>(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាបុរាណក្រិកនិងទស្សនវិជ្ជាអំពីចិត្ត) |
| **៩- កុសលចុងក្រោយ**<br>អ. final good<br>បារ. bien final | កុសលទោល ដែលជាកុសលចុងក្រោយ(ល្អបំផុត ខ្ពង់ខ្ពស់បំផុត) ឬហៅថាបំណងចុងក្រោយ។ សញ្ញាណនៃកុសលចុងក្រោយមានមូលដ្ឋានគ្រឹះនៅក្នុងប្រព័ន្ធសីលវិជ្ជាបុរាណសម័យ។ រាល់អំពើត្រូវបានជំរុញដើម្បីបំណងមួយ ហើយបំណងនោះល្អសម្រាប់អ្នកធ្វើ។ កុសលមួយចំនួនត្រូវបានធ្វើដើម្បីឆ្ពោះទៅរកកុសលខ្ពស់ជាង ហេតុដូច្នេះ កុសលមានឋានានុក្រម។ ក្នុងន័យនេះ ត្រូវតែមានកុសលទោលមួយ ដែលត្រូវបានស្វែងរកសម្រាប់បំណងចុងក្រោយ ចំណែកកុសលផ្សេងទាំងអស់ត្រូវបានស្វែងរកសម្រាប់ឈានទៅដល់កុសលទោលនោះ។ កុសលចុងក្រោយគួរតែនៅចុងក្រោយបំផុត ទូលំទូលាយ និងស្វ័យគ្រប់គ្រាន់ ទោះបីលក្ខខណ្ឌចុងក្រោយនេះស្ថិតនៅក្នុងវិវាទក៏ដោយ។ នៅក្នុងទស្សនវិជ្ជាក្រិកបុរាណ និកាយសីលវិជ្ជានីមួយៗយល់ស្របថា កុសលចុងក្រោយនេះ គឺសុខុមាលភាព ឬសុភមង្គល ប៉ុន្តែនិកាយទាំងនោះយល់ខុសៗគ្នាទៅតាមនិយមន័យសុភមង្គលរៀងៗខ្លួន ដោយកំណត់និយមន័យ«សុភមង្គល»ថាជាកិត្តិយស ភាពរីករាយ គុណធម៌ ការសញ្ជឹងគិត ឬភាពស្ងប់។<br>(ពាក្យនេះ គេប្រើក្នុងសីលវិជ្ជា និងទស្សនវិជ្ជាអំពីសកម្មភាព) |
| **១០- ខុងជឺនិយម**<br>អ. confucianism<br>បារ. confucianisme (m.) | ប្រព័ន្ធគំនិតសំខាន់នៅក្នុងទស្សនវិជ្ជាចិន ដែលបានរីកចម្រើនចន្លោះឆ្នាំ ៥៥១ដល់៤៧៩មុនគ្រិស្តសករាជ ចេញពីការបង្រៀនរបស់ខុងជឺ និងសាវ័ករបស់គាត់ ដែលបានយកចិត្តទុកដាក់ចំពោះគោលការណ៍ស្តីពីចរិយាត្រឹមត្រូវ ជំនាញនៃការគ្រប់គ្រងរដ្ឋ គតិបណ្ឌិតស័ក្តិសិទ្ធិ និងទំនាក់ទំនងសង្គមត្រឹមត្រូវ។ ខុងជឺនិយមបានជះឥទ្ធិពលលើឥរិយាបថប្រជាជនចិន ចំពោះជីវិត គំរូនៃការរស់នៅ និងគំរូនៃតម្លៃសង្គម ព្រមទាំងបានផ្តល់មូលដ្ឋានខាងបញ្ញាសម្រាប់ទ្រឹស្តីនិងស្ថាប័ននយោបាយចិនទៀតផង។ ខុងជឺនិយម បានរាលដាលចេញពីប្រទេសចិនទៅ |

| | |
|---|---|
| | ដល់កូរ៉េ ជប៉ុន និងវៀតណាម និងបានក្លាយទៅជាកត្តារឹងមាំក្នុងវប្បធម៌អាស៊ីខាងកើត ព្រមទាំងបានជំរុញឱ្យមានការចាប់អារម្មណ៍ក្នុងចំណោមអ្នកប្រាជ្ញបស្ចិមប្រទេសស្ទើរតែទាំងអស់។ ទោះបីខុងជឺនិយមបានក្លាយទៅជាមនោគមវិជ្ជាផ្លូវការរបស់រដ្ឋចិនក៏ដោយ ក៏ខុងជឺនិយមមិនដែលមានអត្ថិភាពជាសាសនាផ្លូវការទេ។ ខុងជឺ បានចងក្រងគម្ពីរឈ្មោះថា «លារ៉យី» មានន័យថា សិល្បៈទាំង៦ ជាសិល្បៈសេរី មានគោលដៅស្វែងរកនូវសេរីភាពក្នុងនយោបាយ និងសេដ្ឋកិច្ច ដែលមានដូចខាងក្រោម ៖<br>១- គម្ពីរយី និយាយពីការផ្ទេរកម្មសិទ្ធិ និងផ្ទេរមរតក<br>២- គម្ពីរចេ ជាកំណាព្យនិទានសម្រាប់បម្រើសោភ័ណធម្មជាតិ<br>៣- គម្ពីរលី និយាយពីការប្រារព្ធពិធីសែនព្រេនផ្សេងៗ<br>៤- គម្ពីរយ៉ូ និយាយពីបទភ្លេង និងចម្រៀងបណ្តែតអារម្មណ៍<br>៥- គម្ពីរជូ និយាយពីប្រវត្តិសាស្ត្រ និងពង្សាវតា នៃប្រទេសចិន<br>៦- គម្ពីរឈូស៊ាវ ឬគម្ពីរនិទាយរដូវ និយាយពីសរទរដូវជាប្រវត្តិសាស្ត្រជាក់ស្តែងរបស់សន្តតិវង្សលូ។ |
| **១១- គង្វាលសាស្ត្រ**<br>អ. patristics<br>បារ. patristique ( f. ) | ការសិក្សាអំពីវណ្ណកម្ម និងជីវិតរបស់គ្រូគង្វាល ឬលោកឪពុកសំខាន់ៗនៃវិហារគ្រិស្តសាសនាពីសតវត្សរ៍ទី១ដល់ទី៥នៃគ្រិស្តសករាជ។ |
| **១២- គតិបណ្ឌិតប្រតិបត្តិ**<br>អ. practical wisdom<br>បារ. sagesse pratique | បច្ចេកសព្ទរបស់អារីស្តូត( Aristote/Aristotle )សម្រាប់ការពិចារណាដែលនាំទៅដល់សកម្មភាពប្រតិបត្តិ ពោលគឺសំដៅទៅដល់គុណធម៌ដែលកើតចេញពីការពិចារណាអំពីការអនុវត្តត្រឹមត្រូវនូវការយល់ដឹងទូទៅនិងការយល់ដឹងខាងទ្រឹស្តីសីលធម៌ចំពោះករណីជាក់ស្តែងដោយឡែកៗ។ អារីស្តូត និយាយថា គតិបណ្ឌិតប្រតិបត្តិ គឺជាសភាពពិត និងសមហេតុផលនៃសមត្ថភាពក្នុងការធ្វើអំពើណាមួយ ដោយគិតដល់ផលល្អ និងអាក្រក់ចំពោះមនុស្ស។ ( បញ្ញត្តិនេះគេប្រើនៅក្នុងទស្សនវិជ្ជាក្រិកបុរាណ សីលវិជ្ជា និង ទស្សនវិជ្ជាស្តីអំពីអំពើ [គតិបណ្ឌិតប្រតិបត្តិ=ការពិចារណា=ការយល់ដឹង=បញ្ញា=ហេតុផល ប្រតិបត្តិ=ការប្រុងប្រយ័ត្ន] )។ |
| **១៣- គុណធម៌ធម្មជាតិ**<br>អ. natural virtue<br>បារ. vertu naturelle | ចំពោះ ដាវីដ ហ៊ូម( David Hume) គុណធម៌ គឺជាគុណភាពខាងសីលធម៌នៅក្នុងខ្លួនរបស់យើង ឬ ក្នុងខ្លួនរបស់អ្នកដទៃ ដែលត្រូវបានយល់ព្រមដោយទស្សនៈខាងសីលធម៌។ ហ៊ូម បានញែកគុណធម៌ធម្មជាតិចេញពីគុណធម៌-សិប្បនិម្មិត។ គុណធម៌ធម្មជាតិ គឺជាទំនោរនិងលក្ខណៈគុណធម៌ ដែលកើត-ឡើងពីឧបនិស្ស័យមូលដ្ឋាននៃធម្មជាតិពិតរបស់មនុស្ស ហើយ វាមិនមែនជាអ្វីដែល ត្រូវបានគេបណ្តុះដោយចេតនាទេ។ លក្ខណៈទាំងនេះមានដូចជា សេចក្តីករុណា ចិត្តសប្បុរស ចិត្តប្រណី ចិត្តទូលាយ សេចក្តីស្រឡាញ់របស់អ្នកណាម្នាក់ |

| | |
|---|---|
| | ចំពោះ ក្មេងៗ ការអភ័យទោស។ល។ ផ្ទុយទៅវិញ គុណធម៌ សិប្បនិម្មិត ដូចជា យុត្តិធម៌ ស្វាមីភក្តិ សេចក្តីស្មោះត្រង់ គឺជាលទ្ធផលនៃល្បិចដ៏ប៉ិនប្រសប់ និង ការអប់រំ ដែលគេទទួលបានក្នុងអំឡុងពេលដ៏យូរ។ លក្ខណៈទាំងនេះ ជាសិប្ប និម្មិត និង ត្រូវបានគេប្រឌិត ប៉ុន្តែមិនមែនធ្វើឡើងតាមទំនើងចិត្តនោះទេ។ ហ៊ូម អះអាងថា គុណធម៌ធម្មជាតិ ផ្តល់មូលដ្ឋានចំពោះ ជីវិតគ្រួសារ និងទំនាក់ទំនង ជិតស្និទ្ធ រវាងមិត្តភក្តិ។ ចំណែកឯ គុណធម៌សិប្បនិម្មិតវិញ គឺជាតម្រូវការ ចាំបាច់ចំពោះ ជីវិតសង្គមដ៏ទូលំទូលាយរបស់យើង។<br>( ពាក្យនេះ គេប្រើនៅក្នុងសីលវិជ្ជា ) |
| **១៤- គុណូបការៈ/<br>គុណូបការ**<br>អ. merit<br>បារ. mérite ( m. ) | ឧត្តមភាពឬតម្លៃដែលសក្តិសមនឹងទទួលបានការតបស្នងជារង្វាន់ឬកិត្តិយស។ គុណូបការៈចែកចេញជាពីរគឺ គុណូបការៈសីលធម៌ ដូចជា គុណធម៌ ជាដើម និងគុណូបការៈមិនមែនសីលធម៌ ដូចជា ជំនាញ បំណិន ជាដើម។ គុណូបការៈ ទាំងអស់ គឺជាគុណសម្បត្តិដែលត្រូវគោរព ឬគួរគោរព និងកោតសរសើរនៅក្នុង សង្គម។<br>( ពាក្យនេះ គេប្រើក្នុងទស្សនវិជ្ជាសីលធម៌ និង ទស្សនវិជ្ជានយោបាយ ) |
| **១៥- គោលជំហរ**<br>អ. attitude ( position )<br>បារ. attitude ( position ) | សភាពនៃការយល់ព្រម ឬ ការមិនយល់ព្រមខាងគំនិត ការពេញចិត្តឬការមិន ពេញចិត្ត ដែលទាក់ទងនឹងវេទនារម្មណ៍និងអារម្មណ៍ ហើយដែលផ្ទុយទៅនឹង ជំនឿ។ ជំនឿទាក់ទងនឹងហេតុការណ៍ និងការគិត ចំណែកឯ គោលជំហរ វិញ ទាក់ទងនឹងការវាយតម្លៃនិងការឆ្លើយតបខាងវេទនារម្មណ៍។ មនុស្សដែលមាន ជំនឿដូចគ្នា អាចមានគោលជំហរខុសគ្នាឬក៏មនុស្សដែលមានគោលជំហរដូចគ្នា អាចមានជំនឿខុសគ្នាចំពោះកម្មវត្ថុតែមួយ។ ដូច្នេះ ការខុសគ្នារវាងគោលជំហរ និងជំនឿ ដូចគ្នាទៅនឹងការខុសគ្នារវាងតម្លៃនិងហេតុការណ៍។ សីលវិជ្ជា អត្តនោម័តិ អះអាងថា គោលជំហរ ទាក់ទងដោយផ្ទាល់នឹងហេតុផលជំរុញ និង ឥរិយាបថ និងអះអាងថា ការវិនិច្ឆ័យខាងសីលវិជ្ជានិងខាងតម្លៃ គឺជាបញ្ហានៃ គោលជំហរជាជាងបញ្ហានៃការគិត។<br>( ពាក្យនេះ គេប្រើនៅក្នុងសីលវិជ្ជា និងទស្សនវិជ្ជាស្តីពីអំពើ ) |
| **១៦- ឃាតកម្ម**<br>អ. killing<br>បារ. meurtre ( m. ) | អំពើនៃការបញ្ចប់ជីវិត។ ឃាតកម្មលើភាវៈមនុស្ស ជានិច្ចកាលត្រូវបានគេចាត់ ទុកថាជាអំពើអាក្រក់បំផុតខាងសីលធម៌ ហើយសិទ្ធិរស់រានមានជីវិតត្រូវបាន គេចាត់ទុកជាសិទ្ធិមនុស្សសំខាន់បំផុត។ ការហាមមិនឱ្យសម្លាប់មនុស្សដែល គ្មានទោស គឺជាគោលការណ៍ទូទៅខាងសីលធម៌ និងចាស់ជាងគេបំផុត។ នៅក្នុង សង្គមបុរាណ គោលការណ៍ទូទៅនេះ អនុវត្តតែក្នុងសហគមន៍ផ្ទាល់ខ្លួន ប៉ុណ្ណោះ។ ក្នុងក្របខណ្ឌសាសនា មានសាសនាព្រះពុទ្ធ និង សាសនាគ្រិស្ត ជាដើម គោលការណ៍ទូទៅនេះ បានពង្រីកទៅដល់ការហាមមិនឱ្យសម្លាប់ មនុស្ស សត្វគ្រប់ប្រភេទ។ ទ្រឹស្តីសីលធម៌សម័យទំនើប ធ្វើយុត្តិកម្មភាពមិនអាច |

| | |
|---|---|
| | បំពានបាននៃជីវិតមនុស្សក្នុងក្របខណ្ឌនៃសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលជាភាវៈប្រកបដោយវិចារណញ្ញាណ។ ជាប្រពៃណី ឃាតកម្មត្រូវបានគេធ្វើយុត្តិកម្មតែនៅក្នុងយុត្តសង្គ្រាម និងការកាត់ទោសប្រហារជីវិតប៉ុណ្ណោះ ទោះបីជាមូលដ្ឋានទាំងពីរនេះនៅតែត្រូវបានគេជជែកដេញដោលនៅឡើយក៏ដោយ។<br>(ពាក្យនេះ គេប្រើនៅក្នុងសីលវិជ្ជា) |
| **១៧- ចិត្ត**<br>អ. mind<br>បារ. esprit (m.) | សមត្ថភាពគិត យល់ដឹង ពិចារណា វិនិច្ឆ័យ និងសម្រេចចិត្តរបស់មនុស្ស។ លើសពីនេះទៀតចិត្តក៏ជាមជ្ឈមណ្ឌលនៃញាណ ដែលបង្កើតការគិត អារម្មណ៍ គំនិត ប្រត្យក្សារម្មណ៍ និងជាកន្លែងផ្ទុកពុទ្ធិនិងការចងចាំ។ លោក រ៉ឺណេ ដេកាត(René Déscartes) បានប្រើពាក្យចិត្ត(mind) និងព្រលឹង(soul) អាចជំនួសគ្នាទៅវិញទៅមកបាន។ ចំពោះគាត់ ចិត្ត(mind) ដូចគ្នានឹងអត្តៈ(មនុស្ស) ដែលជាសារជាតុអាចគិត ជឿ សង្ស័យ មានចំណង់ យល់ដឹង និងធ្វើអំពើ។ ចំពោះទស្សនវិទូដទៃទៀត ដូចជា ដាវីដ ហ៊ូម(David Hume) យល់ថា ចិត្ត(Mind) គឺជាបណ្តុំនៃសភាពខាងចិត្តសាស្ត្រ ហើយក្នុងន័យនេះ វាស្រដៀងគ្នាទៅនឹងញាណ(Consciousness) ប៉ុន្តែវាផ្ទុយទៅនឹងសភាពខាងរូបកាយ។ ការយល់ដឹងខុសៗគ្នាអំពីចិត្តនាំទៅដល់ការយល់ដឹងខុសគ្នាអំពីបញ្ហាចិត្តកាយ (mind-body problem)។<br>(បញ្ញតិនេះ គេប្រើក្នុងទស្សនវិជ្ជាអំពីចិត្ត) |
| **១៨- ឆន្ទៈ**<br>អ. will<br>បារ. volonté (f.) | អំណាចនៃចិត្តក្នុងការជ្រើសរើសចំណង់ខ្លាំងបំផុតក្នុងចំណោមចំណង់ជាច្រើនដែលមានក្នុងខណៈពេលមួយនៃការសម្រេចចិត្ត ដែលស្តែងឡើងតាមរយៈសកម្មភាពជាក់លាក់ណាមួយ។ ឆន្ទៈមិនសំដៅលើចំណង់ជាក់លាក់ណាមួយទេ ប៉ុន្តែសំដៅលើសមត្ថភាពក្នុងការប្រព្រឹត្តប្រកបដោយការសម្រេចចិត្តចំពោះចំណង់របស់បុគ្គលណាម្នាក់។ នៅក្នុងទស្សនវិជ្ជា ឆន្ទៈសំខាន់ណាស់ក្នុងនាមជាផ្នែកច្បាស់លាស់មួយនៃចិត្តរួមជាមួយនឹងវិចារណញ្ញាណនិងការយល់ដឹង។ ឆន្ទៈត្រូវបានចាត់ទុកថាសំខាន់នៅក្នុងសីលវិជ្ជា ដោយសារតែតួនាទីស្នូលនៅក្នុងការជួយមនុស្សម្នាក់ឱ្យប្រព្រឹត្តប្រកបដោយបំណង។ |
| **១៩- ជែនសិននិយម**<br>អ. jansenism<br>បារ. jansénisme (m.) | ចលនាទស្សនវិជ្ជា និងសាសនាដែលគេបានដាក់ឈ្មោះដូច្នេះបន្ទាប់ពីសាសនវិទូហូឡង់ ឈ្មោះជែនសិន(Cornelius Otto Jansen,1585-1638) បានស្លាប់ទៅ។ ជែនសិននិយមរីកចម្រើនក្នុងសតវត្សរ៍ទី១៧និងទី១៨ នៅអឺរ៉ុបខាងលិចជាពិសេសក្នុងប្រទេសបារាំង។ លក្ខណៈពិសេសរបស់ចលនានេះ រួមមានបុព្វវាសនានិយមដាច់ខាត និងការប្រតិបត្តិតឹងរ៉ឹងខាងសីលធម៌។ កំណត់និយម |

| | |
|---|---|
| | បែបជែនសិន ជឿថា យើងមិនអាចបំពេញបទបញ្ញារបស់អាទិទេពបានដោយគ្មានជំនួយពីអាទិទេពឡើយ ប៉ុន្តែយើងមិនអាចបដិសេធជំនួយនេះបានឡើយប្រសិនបើអាទិទេពផ្តល់ឱ្យយើង។ លទ្ធិជែនសិនត្រូវបានរិះគន់យ៉ាងខ្លាំងថាជាអញ្ញទិដ្ឋិ ដោយសម្តេច ប៉ាបទី១០ (Pope Innocent X)ហើយសហគមន៍ជែនសិនត្រូវបានរំលាយក្នុងឆ្នាំ១៧០៩។ ចលនាជែនសិននិយមនេះបានជះឥទ្ធិពលលើការគិតរបស់ ប្លេស ប៉ាស្កាល(Blaise Pascal)ជនជាតិបារាំងបន្ត រហូតដល់សតវត្សរ៍ទី១៩។<br>(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាអំពីសាសនា) |
| **២០- ញាណ**<br>អ. consciousness<br>បារ. conscience (f.) | សភាពនៃការដឹងខ្លួន ការស្គាល់ ការយល់ ការចេះ និងការដឹងពីអ្វីមួយ ដែលកំពុងកើតឡើងនៅជុំវិញខ្លួនយើង។ ម្យ៉ាងទៀត ញាណ គឺជាសភាពចិត្ត ដូចជាការឈឺចាប់ វេទនារម្មណ៍ គំនិត និងការយល់ដឹងខាងផ្លូវចិត្តផ្សេងៗទៀត។ |
| **២១- តថភាពនិយម កញ្ឆោត**<br>អ. naive realism<br>បារ. réalisme naïf | ទស្សនៈសុភនិច្ឆ័យស្តីអំពីពិភពលោកដែលប្រកាន់យកដោយប្រជាជនសាមញ្ញភាគច្រើនបំផុត។ យោងតាមទស្សនៈនេះ ពិភពខាងក្រៅផ្សំពីវត្ថុផ្សេងៗ ដូចជា ទឹក ដី ភ្លើង ខ្យល់ ព្រៃឈើ ថ្ម ដី ជាដើម និង គុណភាពរបស់វត្ថុទាំងនោះ។ ពិភព-លោកមានអត្ថិភាពនិងរីកចម្រើនដោយឯករាជ្យពីឥន្ទ្រិយារម្មណ៍ និងគំនិតរបស់យើង។ ឥន្ទ្រិយារម្មណ៍របស់យើងប្រៀបដូចជាកញ្ចក់ដែលឆ្លុះបញ្ចាំងអំពីតថភាពរបស់ពិភពលោក។ ទស្សនៈនេះក៏ជឿដោយឥតសង្ស័យដែរថា យើងមានលទ្ធភាពដឹងពីពិភពលោក។ ទោះជាយ៉ាងនោះក៏ដោយផ្អែកលើការពិចារណា ទស្សនវិទូជាច្រើនបានរកឃើញថា ធម្មជាតិនៃពិភពលោកនិងចំណេះដឹងរបស់យើងអំពីពិភពលោកមានលក្ខណៈស្មុគស្មាញ និងអាចកំបាំងជាងការពន្យល់របស់តថភាពនិយមកញ្ឆោត។ គុណភាពជាច្រើនដែលគេហៅថា បន្ទាប់បន្សំ ដូចជា ពណ៌ រសជាតិ និង ក្លិន គឺមិនអាចផ្តាច់ចេញពីវិញ្ញាណរបស់យើងដូចលក្ខណៈស្នូល(ចាំបាច់)របស់វត្ថុដែលឯករាជ្យពីយើងនោះទេ។ ប្រត្យក្សារម្មណ៍របស់យើង ពេលខ្លះបំភាន់យើង។ ដោយផ្តើមចេញពីទស្សនៈនេះ យើងអាចដកស្រង់សំណួរទស្សនវិជ្ជាសំខាន់ៗជាច្រើន ដូចជា "តើអ្វីជាការណ៍ពិត?" "តើអ្វីជាភាពស្តែងចេញ?" "តើមាយាការអាចកើតឡើងរបៀបណា?" "តើបទពិសោធន៍របស់យើងគឺជាប្រភពពុទ្ធិដែលអាចទុកចិត្តបានដែរឬទេ?" កិច្ចការមួយក្នុងចំណោមកិច្ច |

| | |
|---|---|
| | ការសំខាន់របស់ទស្សនវិជ្ជា គឺគាស់កកាយការលំបាកនានាដែលកប់នៅក្នុងការសន្មតទូទៅអំពីការយល់ឃើញ ដូចជា តថភាពនិយមកញ្ឆោត ជាដើម ដើម្បីយល់ដឹងពីពិភពលោកឱ្យកាន់តែច្បាស់។<br>(ពាក្យនេះ គេប្រើនៅក្នុងពុទ្ធិវិទ្យា) |
| **២២- តម្រេកនិយម សីលវិជ្ជា**<br>អ. ethical hedonism<br>បារ. hédonisme éthique | ទ្រឹស្តីសីលវិជ្ជាដែលអះអាងថា សេចក្តីរីករាយ ឬសុភមង្គល គឺជាកុសលធម្មជាតិខ្ពស់បំផុត និងជាគោលបំណងនៅក្នុងជីវិត និងថាមនុស្សគួរតែស្វែងរកសេចក្តីរីករាយឱ្យបានច្រើនបំផុតនិងកាត់បន្ថយការឈឺចាប់ឱ្យនៅតិចបំផុត។ ទ្រឹស្តីនេះការពារដោយទស្សនវិទូក្រិក អារីស្ទីពុស (Arisstippus) និងអេពីកួ (Epicurus) ទស្សនវិទូពិសោធន៍និយមជនជាតិអង់គ្លេស តូម៉ាស ហូប(Thomas Hobbes) ទស្សនវិទូផលប្រយោជន៍និយម ចន ឡុក (John Lock) ដាវីដ ហ៊្យូម (David Hume) និងទស្សនវិទូផលប្រយោជន៍និយមផ្សេងទៀត។ ទោះបីយ៉ាងណាក៏ដោយ ក៏ទស្សនវិទូតម្រេកនិយមបានបង្ហាញឱ្យឃើញពីភាពខុសគ្នាជាច្រើនទាក់ទងនឹងសេចក្តីរីករាយនេះ ហើយការយល់ដឹងពីភាពខុសគ្នានេះនាំឱ្យមានប្រភេទខុសៗគ្នានៃតម្រេកនិយម។ ជាទូទៅមានការលើកឡើងថា សេចក្តីរីករាយគឺជាពាក្យអវិជ្ជមានដោយសារគេគិតថា សេចក្តីរីករាយនេះ សំដៅតែទៅលើតម្រូវការខាងរាងកាយឬខាងវិញ្ញាណ។ ប៉ុន្តែទស្សនវិទូខាងតម្រេកនិយមអះអាងថា សេចក្តីរីករាយនេះ មិនសំដៅតែទៅលើសេចក្តីរីករាយខាងឥន្ទ្រីយ៍នោះទេ លើសពីនេះទៀតសេចក្តីរីករាយក៏សំដៅទៅលើចំណង់ចំណូលចិត្តសុភមង្គល និងឧត្តមគតិផងដែរ។<br>(ពាក្យនេះ គេប្រើក្នុងសីលវិជ្ជា) |
| **២៣- តម្លៃសច្ចភាព**<br>អ. truth-value<br>បារ. valeur de vérité | ភាពពិតឬភាពមិនពិតដែលមាននៅក្នុងសេចក្តីថ្លែងនីមួយៗ។ តក្កវិជ្ជាបុរាណអះអាងថា រាល់សេចក្តីថ្លែងត្រូវតែពិតឬមិនពិត ហើយភាពពិត ឬភាពមិនពិតរបស់វា គឺជាតម្លៃសច្ចភាពរបស់វា។ ប្រសិនបើសេចក្តីថ្លែងនោះពិត តម្លៃសច្ចភាពរបស់វា គឺភាពពិត ប្រសិនបើសេចក្តីថ្លែងនោះមិនពិត តម្លៃសច្ចភាពរបស់វា គឺភាពមិនពិត។ «ធ្យូងថ្មនោះមានពណ៌ស» មិនពិត ដូច្នេះ យើងនិយាយថា តម្លៃសច្ចភាពនៃប្រយោគនោះគឺភាពមិនពិត។ «ទឹកកកសំឡីមានពណ៌ស»ពិត ដូច្នេះ យើងនិយាយថា តម្លៃសច្ចភាពនៃប្រយោគនោះគឺភាពពិត។ ប្រសិនបើសេចក្តីថ្លែងពីរដូចគ្នា វាមានតម្លៃសច្ចភាពដូចគ្នា។ គោលការណ៍ស្តីពីទ្វិកលក្ខណៈនៅក្នុងតក្កវិជ្ជាបុរាណទទួលស្គាល់តម្លៃសច្ចភាពតែពីរប៉ុណ្ណោះ ចំណែកឯទម្រង់មួយចំនួននៃតក្កវិជ្ជាទំនើប បដិសេធការសន្មតនេះ ហើយ អះអាងថាតក្កវិជ្ជាមានតម្លៃបីឬច្រើន។ លោក ស្ត្រសាន់(Strawson) អះអាងថា អាចមានសេចក្តី |

| | |
|---|---|
| | ថ្លែងដែលគ្មានតម្លៃសច្ចភាព ពោលគឺ សេចក្តីថ្លែងដែលមិនពិត ហើយក៏មិនខុសដែរ និង ដែលមានចន្លោះតម្លៃសច្ចភាព។<br>(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា) |
| **២៤- តម្លៃសោភ័ណ**<br>អ. aesthetic value<br>បារ. valeur esthétique | លក្ខណៈនានាដែលធ្វើឱ្យស្នាដៃសិល្បៈមួយល្អ ឬ ជោគជ័យ ដូចជា តុល្យភាព ភាពទាក់ទាញ ប្រណីតភាព ភាពរស់រវើក ភាពស៊ីចង្វាក់ ភាពពេញលេញ ឬ ឯកភាព ពោលគឺជាអ្វីដែលជួយឱ្យស្នាដៃសិល្បៈមួយមាន «សោភណភាព» ហើយដែលខុសពីអ្វីដែលផ្តល់ប្រយោជន៍ សច្ចភាពនិងសីលកុសលរបស់ស្នាដៃនោះ។<br>(បញ្ញត្តិនេះ គេប្រើនៅក្នុងសោភណវិជ្ជា)។ |
| **២៥- តាវនិយម**<br>អ. taoism<br>បារ. taoïsme (m.) | ទស្សនវិជ្ជាចិនបុរាណដែលមានអត្ថន័យពីរយ៉ាង ៖<br>- ទីមួយ គឺជាទស្សនវិជ្ជាស្តីអំពីភាពសាមញ្ញនិងភាពមិនជ្រៀតជ្រែក ពោលគឺ សំដៅយកទស្សនវិជ្ជាចិនដែលគាំទ្រជីវិតសាមញ្ញនិងគោលការណ៍នៃការមិនជ្រៀតជ្រែកដំណើរវិវត្តន៍បែបធម្មជាតិរបស់អ្វីមួយ។ តាវនិយមត្រូវបានគេរកឃើញក្នុងសតវត្សរ៍ទី៦ មុនគ្រិស្តសករាជ ដោយ ឡៅស៊ឺ(Lao-tzu) ដែលជាទស្សនវិទូនិងអ្នកអធិធម្មជាតិ។<br>- ទីពីរ គឺជាសាសនាពេញនិយមរបស់ចិនដែលស្វែងរកសុខដុមនិងអាយុវែងតាមរយៈទស្សនវិជ្ជារបស់តាវនិយម ដែលផ្សំពីអាទិទេពធម្មជាតិនិងការប្រតិបត្តិខាងវេទមន្ត។ |
| **២៦- ត្រីមូរ្តិ/ត្រីមូរតិ**<br>អ. trimurti<br>បារ. trimurti (f.) | បញ្ញត្តិមួយដែលគេប្រើនៅក្នុងសាសនាហិណ្ឌូ សំដៅទៅលើអាទិទេពបីអង្គ គឺ ព្រះព្រហ្ម(អ្នកបង្កើតលោក)ព្រះវិស្ណុ/ព្រះនរាយណ៍ (អ្នកការពារនិងថែរក្សាលោក) និងព្រះសិវៈ/ព្រះឥសូរ(អ្នកបំផ្លាញឬបង្កើតលោកឡើងវិញ) ហើយត្រូវបានគេធ្វើបដិរូបកម្មជាប្រជុំអាទិទេព។ នៅពេលដែលអាទិទេពទាំង៣របស់ត្រីមូរ្តិ/ត្រីមូរតិប្រែក្លាយទៅជាអវតារតែមួយគេហៅថា ទត្តាត្រេយ។ |
| **២៧- ត្រីអង្គ**<br>អ. trinity<br>បារ. trinité (f.) | បញ្ញត្តិមួយស្តីពីអាទិទេពនៅក្នុងលទ្ធិគ្រិស្តសាសនា ដែលជឿថា អាទិទេពមានអត្ថិភាពជាអង្គបី គឺព្រះវរបិតា ព្រះរាជបុត្រា(ព្រះយេស៊ូគ្រិស្ត) និងព្រះវិញ្ញាណបរិសុទ្ធ។ |
| **២៨- ត្រីអង្គនិយម**<br>អ. trinitarianism<br>បារ. trinitarianisme (m.) | លទ្ធិមួយនៅក្នុងគ្រិស្តសាសនាដែលជឿថា អាទិទេពមានអត្ថិភាពជាអង្គបី ប៉ុន្តែជាភាវៈតែមួយ។ អង្គទាំងបីនោះត្រូវបានគេយល់ថាមានអត្ថិភាពជាព្រះវរបិតា ព្រះរាជបុត្រា(ព្រះយេស៊ូគ្រិស្ត) និងព្រះវិញ្ញាណបរិសុទ្ធ ហើយអង្គនីមួយៗមានធម្មជាតិឬសារជាតិដូចគ្នា។ |

| | |
|---|---|
| **២៩- ទស្សនវិជ្ជាបស្ចិមប្រទេស**<br>អ. western philosophy<br>បារ. philosophie occidentale | ស្នាដៃនិងគំនិតនៃពួកបស្ចិមប្រទេស(បណ្ដាប្រទេសអឺរ៉ុបនិងអាម៉េរិក)ត្រូវបានគេបង្កើតឡើងដោយកការគិតបែបទស្សនវិជ្ជាស្ដីពីអរិយធម៌បស្ចិមប្រទេសជាពិសេស អរិយធម៌ដែលចាប់ផ្ដើមដោយទស្សនវិជ្ជាក្រិកបុរាណ។ ទស្សនវិជ្ជា-បស្ចិមប្រទេសខុសគ្នាពីទស្សនវិជ្ជាបូព៌ាប្រទេសនិងទស្សនវិជ្ជាអន្ដោគ្រាម។ |
| **៣០- ទឡ្ហីករណ៍បុព្វហេតុទីមួយ**<br>អ. first cause argument<br>បារ. argument de la cause première | ទឡ្ហីករណ៍មួយនៃទឡ្ហីករណ៍បុរាណស្ដីអំពីអត្ថិភាពរបស់អាទិទេព។ ហេតុការណ៍នីមួយៗនៅក្នុងពិភពធម្មជាតិមានបុព្វហេតុរបស់វា។ ទោះបីជាយ៉ាង ណាក៏ដោយគេមិនអាចរកឃើញបុព្វហេតុដំបូងបំផុតដែរ គឺគេគ្រាន់តែអាចត្រឡប់ទៅរកបុព្វហេតុនានាដោយពន្លាតថយក្រោយបន្តបន្ទាប់ប៉ុណ្ណោះ។ ដើម្បីបញ្ឈប់ការត្រឡប់ពន្លាតថយក្រោយនេះ យើងត្រូវតែសន្មតថា អ្វីមួយជាបុព្វហេតុទីមួយ។ បុព្វហេតុទីមួយនេះត្រូវបានគេសន្មតថាជាសកម្មភាពនៃការបង្កើតរបស់អាទិទេព។ |
| **៣១- ទឡ្ហីករណ៍ឯកភាព**<br>អ. henological argument<br>បារ. argument hénologique | ប្រភេទនៃអំណះអំណាងបែបទេវនិយមសម្រាប់អះអាងអំពីអត្ថិភាពរបស់អាទិទេពដោយប្រើប្រាស់ទម្រង់ដែលដូចគ្នានឹងវិធីទីបួនក្នុងវិធីទាំងប្រាំរបស់អាគីណាស់(Aquinas)។ តាមរយៈការសង្កេតដែលមានកម្រិតផ្សេងៗនៃកុសលភាព សុក្រឹតភាព សច្ចភាព និងតថភាពនៅក្នុងពិភពលោក អំណះអំណាងនេះសន្និដ្ឋានថា ត្រូវតែមានភាវៈមួយដែលតាងឱ្យកម្រិតខ្ពស់បំផុតនៃលក្ខណៈវិជ្ជមានទាំងអស់នេះ ក្នុងនាមជាភាពពេញលេញរបស់ពួកវា។ ភាវៈនេះជាភាវៈល្អបំផុត សុក្រឹតបំផុត សច្ចៈបំផុត និងពិតបំផុត ហើយភាវៈនោះ គឺអាទិទេព។ ប្រសិនបើលក្ខណៈវិជ្ជមានអាចកើតមាននៅក្នុងកម្រិតផ្សេងៗគ្នាដោយមិនត្រូវបានសម្រេចនៅក្នុងភាវៈមួយនៅកម្រិតខ្ពស់បំផុត ឬប្រសិនបើពុំមានកម្រិតខ្ពស់ដូចនោះទេអំណះអំណាងនេះ បរាជ័យ។<br>(ពាក្យនេះ គេប្រើនៅទស្សនវិជ្ជាអំពីសាសនា) |
| **៣២- ទេវាធិបតេយ្យ**<br>អ. theocracy<br>បារ. théocratie (f.) | ទម្រង់នៃការគ្រប់គ្រងរដ្ឋ ដែលច្បាប់និងបទបញ្ញត្តិទាំងឡាយកើតចេញពីក្រឹត្យក្រម(ច្បាប់) ដែលកំណត់ដោយសាសនាណាមួយ។ ទម្រង់នៃការគ្រប់គ្រងរដ្ឋបែបនេះ ដឹកនាំដោយផ្អែកលើច្បាប់អាទិទេព ហើយអាទិទេពត្រូវបានចាត់ទុកជាប្រមុខរដ្ឋ។ គម្ពីរពិសិដ្ឋរបស់សាសនា ត្រូវបានចាត់ទុកជាសារ ឬបទបញ្ជា ឬក៏ច្បាប់របស់អាទិទេព ហើយត្រូវបានប្រើប្រាស់ដើម្បីដឹកនាំសង្គមឬរដ្ឋ។ ជាញឹកញាប់ទម្រង់នៃការគ្រប់គ្រងរដ្ឋបែបទេវាធិបតេយ្យត្រូវបានគ្រប់គ្រងដោយឥស្សរជនសាសនា ឬក្រុមបព្វជិត ដែលកាន់អំណាចនយោបាយក្នុងនាមអាទិទេព។ ឥស្សរជនទាំងនោះបកស្រាយគម្ពីរពិសិដ្ឋសាសនាដើម្បីគោលបំណងនយោបាយរបស់ខ្លួន ហើយអះអាងថា ពួកគេគោរពនិងអនុវត្តឆន្ទៈរបស់អាទិទេព។ |

| | |
|---|---|
| **៣៣- ទំនាក់ទំនងនិយម**<br>អ. relativism<br>បារ. relativisme (m.) | លទ្ធិមួយដែលតែងតែបញ្ជាក់ថា ក្នុងវិស័យមួយចំនួនយ៉ាងហោចណាស់ សច្ចភាពខ្លួនវាទាក់ទងទៅនឹងទស្សនៈរបស់អ្នកវិនិច្ឆ័យ (ឧទាហរណ៍ : សោភណភាពនៃអ្វីមួយអាស្រ័យលើភ្នែករបស់អ្នកសង្កេត)។ សេចក្តីថ្លែងបុរាណដំបូងគេ គឺជាលទ្ធិរបស់ពួកសូហ្វីស (Sophist) ដែលប្រូតាហ្គ័រ (Protagoras)អះអាងថា «មនុស្ស គឺជារង្វាស់នៃអ្វីៗទាំងអស់»។ ទំនាក់ទំនងនិយមអាចជាលទ្ធិសាកលមួយដែលនិយាយអំពីរាល់ពុទ្ធិទាំងអស់ ឬជាលទ្ធិដោយឡែកមួយដែលនិយាយអំពីវិស័យណាមួយ(ឧទាហរណ៍ : សោភណវិជ្ជា សីលវិជ្ជា ឬការវិនិច្ឆ័យអំពីគុណភាពបន្ទាប់បន្សំ)។ ទិដ្ឋភាពនានាដែលជះឥទ្ធិពលលើការវិនិច្ឆ័យរបស់ប្រធាន(អ្នកវិនិច្ឆ័យ)ចំពោះការសន្មតថាអ្វីមួយពិតឬមិនពិតចំពោះពួកគេអាចរួមមាន មូលដ្ឋានប្រវត្តិសាស្ត្រ វប្បធម៌ សង្គម ភាសា ឬចិត្តសាស្ត្រ ឬក៏សុខភាពនៃសរីរាង្គវិញ្ញាណ។ ទំនាក់ទំនងនិយម ជាញឹកញាប់ត្រូវបានបដិសេធដោយផ្អែកលើមូលដ្ឋានថា ជំនឿ ឬការវិនិច្ឆ័យត្រូវតែឆ្លើយតបទៅនឹងនិយាមនានាដោយឯករាជ្យពីទំនោររបស់មនុស្សម្នាក់ៗ។ |
| **៣៤- ទំនោរ**<br>អ. tendency<br>បារ. tendance (f.) | ទិដ្ឋភាពនៃការប្រព្រឹត្តរបស់មនុស្សម្នាក់ៗ ដែលបង្ហាញតាមវិធីជាក់លាក់ណាមួយ ហើយជាកម្លាំងចលករខាងផ្លូវចិត្តច្បាស់លាស់តម្រង់ទៅរកគោលបំណងជាក់លាក់ណាមួយ។ តាមធម្មជាតិរបស់មនុស្ស ទំនោរសុទ្ធតែជាកម្លាំងពិតប្រាកដ ហើយសុទ្ធតែមានគោលបំណងជាក់លាក់។ តាមវិទ្យាសាស្ត្រ គោលបំណងទាំងឡាយពុំមែនកើតឡើងដោយឯកឯងនោះទេ ផ្ទុយទៅវិញ វាសុទ្ធតែមានប្រភពរបស់វា។ |
| **៣៥- នរក**<br>អ. hell<br>បារ. enfer (m.) | តាមលទ្ធិគ្រិស្តសាសនា នរក ជាលោកឬសភាវៈសម្រាប់អ្នកសាងបាបដែលមិនភ្ញាក់រឭកក្រោយពេលពួកគេស្លាប់ទៅ ហើយអ្នកសាងបាបទាំងនោះត្រូវកាត់ផ្តាច់ពីអាទិទេព និងទទួលរងទណ្ឌកម្មផ្សេងៗផងដែរ។ តាមទស្សនៈពុទ្ធសាសនា នរក ជាទីអបាយភូមិឬអធោលោក ដែលមានរណ្តៅជាលំនៅនៃសត្វមានបាបនៅរងទុក្ខតាមកម្លាំងកម្មដែលខ្លួនបានធ្វើ។ |
| **៣៦- នវប្លាតុងនិយម**<br>អ. neoplatonism<br>បារ. néoplatonisme (m.) | ប្រព័ន្ធទស្សនវិជ្ជាមួយផ្សំពីប្លាតុងនិយមនិងជំនឿខាងសាសនា ដែលមានលក្ខណៈអាថ៌កំបាំង/គូឡ្ហធម្ម(Mysticism) នៅក្នុងគំនិតរបស់យូដា (Judaic ideas) និងនៅក្នុងគំនិតរបស់គ្រិស្តសាសនិក (Christian ideas)។ ប្រព័ន្ធទស្សនវិជ្ជានេះ ត្រូវបានបង្កើតឡើងដំបូងដោយ លោក ផ្លូទីនុស (Plotinus) ជាទស្សនវិទូរ៉ូម៉ាំងចាប់ពីសតវត្សរ៍ទី៣ ហើយបន្តអភិវឌ្ឍដល់សតវត្សរ៍ទី៥នៃគ្រិស្តសករាជ។ |

| | |
|---|---|
| **៣៧- នវសេរីនិយម**<br>អ. neoliberalism<br>បារ. néolibéralisme (m.) | គំរូគោលនយោបាយមួយស្ដីអំពីការសិក្សាសង្គមនិងសេដ្ឋកិច្ច ដែលផ្ទេរការគ្រប់គ្រងវិស័យសេដ្ឋកិច្ចពីរដ្ឋទៅឯកជន។ នវសេរីនិយមមានប្រភពពីគោលការណ៍មូលដ្ឋាននៃសេដ្ឋកិច្ចនវក្លាសិក (neoclassical economics) ដែលស្នើថារដ្ឋាភិបាលត្រូវតែកម្រិតឧបត្ថម្ភធន ធ្វើកំណែទម្រង់ច្បាប់ពន្ធ ដើម្បីពង្រីកមូលដ្ឋានពន្ធ កាត់បន្ថយឱនភាពថវិកា កម្រិតគាំពារនិយម (limit protectionism) និងបើកចំហទីផ្សារទៅរកពាណិជ្ជកម្ម។ នវសេរីនិយមក៏ស្វែងរកការលុបចោលនូវអត្រាប្ដូរប្រាក់ថេរ គាំទ្រការកាត់បន្ថយការគ្រប់គ្រងរបស់រដ្ឋមកលើធុរកិច្ច អនុញ្ញាតឱ្យមានទ្រព្យសម្បត្តិឯកជន និងធ្វើឯកជននីយកម្មធុរកិច្ច។ |
| **៣៨- និព្វាន**<br>អ. nirvana<br>បារ. nirvana (m.) | និព្វានត្រូវបានបកស្រាយខុសៗគ្នាដូចខាងក្រោម ៖<br>- ឈ្មោះធម្មជាត ឬ ចិត្តដែលចេញចាកផុតពីកិលេស និងតណ្ហា អស់មានកម្មជាអ្នកតាក់តែងនាំឱ្យមានការកើតក្នុងវដ្ត និងជាទីបរមសុខស្ងប់ដែលកើតចេញពីសីល សមាធិ និងបញ្ញា។<br>- សភាពឥតខ្ចោះឬបរមសុខនិងភាពស្ងប់ ដែលកើតឡើងដោយការរំលត់ចំណង់និងតណ្ហា និង ភាពអស្ចារ្យក្នុងការផ្ដាច់អត្ថិភាពរបស់អត្តៈ។ (ពុទ្ធសាសនា)<br>- ការរួបរួមឬការដឹងអំពីអត្តសញ្ញាណនៃអាត្ម័នជាមួយព្រហ្ម័ន ដែលគេជឿថាអាត្ម័ននេះមានភាពអមតៈ(Brahman)។ (ហិណ្ឌូសាសនា)<br>- ការរំដោះព្រលឹងចេញពីទាសភាពនៃកម្មនិងសំសារៈ ហើយវាក៏មានន័យថា ជាគោលដៅសង្គ្រោះផងដែរ។ (ជេនសាសនា) (វេវចនៈនឹងពាក្យនិព្វាន មានដូចជា និវ៌ាណ មោក្ស មោក្ខ វិមុត្តិ ជាដើម)។ |
| **៣៩- និមិត្តសត្វ**<br>អ. animal symbolicum<br>បារ. animaux symbolicum | តាមទស្សនៈរបស់លោក កាស៊ីរឺ (Ernst Cassirer) និមិត្តសត្វ សំដៅទៅលើមនុស្ស ដែលមានលក្ខណៈពិសេសរបស់ខ្លួនអាស្រ័យទៅលើសមិទ្ធផល ដោយមិនអាស្រ័យលើរូបកាយនិងស្មារតីនោះទេ។ |
| **៤០- បញ្ញត្តិកម្ម**<br>អ. conception<br>បារ. conception (f.) | ការបង្កើតគំនិត ពោលគឺជាដំណើរនៃការឈានទៅដល់គំនិតឬជំនឿអរូបីមួយ ឬខណៈមួយដែលគំនិតអរូបីនោះចាប់ផ្ដើមចាប់យកទម្រង់មួយឬផុសឡើង។ |
| **៤១- បញ្ហាចិត្ត-កាយ**<br>អ. mind-body problem | បញ្ហាទស្សនវិជ្ជាអំពីចិត្តដែលនិយាយអំពីទំនាក់ទំនងរវាងចិត្តនិងកាយ។ បញ្ញតិនេះត្រូវបានបង្កើតឡើងដំបូងដោយប្លាតុង(Platon/Plato)និងអារីស្តូត(Aristote/Aristotle) ហើយក្រោយមក ដេកាត(Descartes)បានចាត់ទុក បញ្ហាចិត្ត-កាយនេះជាបញ្ហាស្នូលក្នុងទស្សនវិជ្ជាទំនើប។ ដេកាត ជឿថា ចិត្ត មានការគិតជាខ្លឹមរបស់វា ហើយចិត្តគឺជាអង្គដាច់ដោយឡែកពីរាងកាយឬជាសារធាតុបន្ថែម។ មានទស្សនៈពីរដែលនិយាយពីបញ្ហាចិត្ត-កាយ គឺឯកនិយម (monism)និងទ្វិកនិយម |

| | |
|---|---|
| | (dualism)។ ឯកនិយម(monism) អះអាងថា មនុស្សត្រូវបានបង្កើតពីរូបធាតុឬកាយ ហើយអ្វីៗដែលលេចចេញពីកាយ គឺគ្រាន់តែមុខងារនៃកាយប៉ុណ្ណោះ។ ចំណែកឯទ្វិកនិយម(dualism)វិញ អះអាងថា មនុស្សត្រូវបានបង្កើតឡើងពីធាតុពីរ គឺកាយ(រូបធាតុ)និងចិត្ត (ស្មារតីឬព្រលឹង)ដែលមិនអាចកាត់ផ្តាច់ពីគ្នាបានទេ។<br>(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាអំពីចិត្ត) |
| **៤២- បិតាធិបតេយ្យ**<br>អ. paternalism<br>បារ. paternalisme (m.) | របៀបនៃការគ្រប់គ្រងនិងការដឹកនាំរដ្ឋដែលមានលក្ខណៈស្រដៀងនឹងការគ្រប់គ្រងរបស់ឪពុកទៅលើកូន ឬការគ្រប់គ្រងដែលមានលក្ខណៈរួមផ្សំរវាងការប្រើអំណាចជាមួយនឹងការទទួលខុសត្រូវក្នុងការមើលថែសមាជិក ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ នៅក្នុងសីលវិជ្ជា ពាក្យនេះមានន័យថា ជាការជ្រៀតជ្រែកចូលទៅក្នុងសេរីភាពរបស់អ្នកណាម្នាក់ដោយជឿថាការជ្រៀតជ្រែកនោះ គឺដើម្បីលើកកម្ពស់កុសលរបស់អ្នកនោះ ឬការពារអ្នកនោះពីគ្រោះថ្នាក់ដែលកើតឡើង ទោះបីការជ្រៀតជ្រែកនោះបង្កឱ្យមានការជំទាស់ ឬការតវ៉ាពីបុគ្គល ដែលត្រូវបានគេជ្រៀតជ្រែកសេរីភាពនោះក៏ដោយ។ បច្ចុប្បន្ន បិតាធិបតេយ្យត្រូវបានជំទាស់ដោយទស្សនៈសេរីនិយម ដោយគេយល់ថាជាការធ្វើឱ្យបាត់បង់សេរីភាព ស្វ័យភាព និងសិទ្ធិបុគ្គល។<br>(ពាក្យនេះ គេប្រើនៅក្នុងសីលវិជ្ជា និងទស្សនវិជ្ជានយោបាយ)។ |
| **៤៣- បុព្វវាសនា**<br>អ. predestination<br>បារ. prédestination (f.) | សាសនវិជ្ជាដែលអះអាងថា ព្រឹត្តិការណ៍ទាំងអស់នៅក្នុងដំណើរជីវិតរបស់មនុស្សម្នាក់ៗ ពោលគឺអ្វីៗដែលបានកើតឡើង កំពុងកើតឡើង ឬនឹងកើតឡើងត្រូវបានកំណត់ជាមុនដោយអាទិទេពនិងមិនអាចកែប្រែបាន។ ការកំណត់ថាតើព្រលឹងរបស់មនុស្សម្នាក់ៗនឹងឡើងទៅឋានសួគ៌ឬធ្លាក់ទៅឋាននរកត្រូវបានសម្រេចដោយឆន្ទៈរបស់អាទិទេពតាំងពីមនុស្សនោះកើតមកម្ល៉េះ ដោយមិនអាស្រ័យលើការប្រព្រឹត្តរបស់គេឡើយ។<br>(ពាក្យនេះគេប្រើនៅក្នុងទស្សនវិជ្ជាអំពីសាសនា អស្តិរូបវិជ្ជា និងតក្កវិជ្ជា) |
| **៤៤- ប្រូតេស្តង់និយម**<br>អ. protestantism<br>បារ. protestantisme<br>(m.) | លទ្ធិមួយក្នុងចំណោមលទ្ធិសំខាន់ៗទាំង៣នៃគ្រិស្តសាសនា រួមមាន រ៉ូម៉ាំង-កាតូលិកនិយម(Catholicism) អ័រតូដុកនិយម(Orthodoxy) និង ប្រូតេស្តង់និយម (Protestantism)។ ប្រូតេស្តង់និយមបានចាប់ផ្តើមឡើងនៅសតវត្សរ៍ទី១៦ ជាចលនាមួយដើម្បីកែទម្រង់សហគមន៍គ្រិស្តសាសនានៅបស្ចិមប្រទេស ដោយបង្កើតសហគមន៍ប្រូតេស្តង់ចេញពីរ៉ូម៉ាំងកាតូលិក។ គោលបំណងរបស់ពួកប្រូតេស្តង់និយម គឺស្រោចស្រង់ជំនឿគ្រិស្តសាសនាឱ្យល្អដូចដើមឡើងវិញ។ ទន្ទឹមនឹងនេះពួកគេក៏បានរក្សាទុកនូវអ្វីដែលពួកគេគិតថាមានតម្លៃ ហើយដែលបានអភិវឌ្ឍដោយពួករ៉ូម៉ាំងកាតូលិកនៅចន្លោះសតវត្សរ៍ទី៥ដល់ទី១៥។ |

| | |
|---|---|
| **៤៥- ពុត**<br>អ. hypocrisy<br>បារ. hypocrisie ( f. ) | សភាពនៃការស្តែងចេញខាងក្រៅរបស់មនុស្សណាម្នាក់ដែលមិនមែនជាសញ្ញានៃសភាពពិតខាងក្នុងរបស់ខ្លួន។ ការស្តែងចេញខាងក្រៅនោះ អនុលោមទៅតាមការទាមទារខាងសីលធម៌ ចំណែកឯ សភាពលាក់បាំងខាងក្នុងនោះប្រាសចាកសីលធម៌។ ពុតអាចត្រូវផ្តន្ទាទោសខាងសីលធម៌ ពីព្រោះវាជាប្រភេទនៃការបំភាន់ ឬ ការក្លែងធ្វើអ្វីមួយ ដែលប្រាសចាកសីលធម៌សង្គម។ ដូច្នេះ ពុតជាប់ទាក់ទងនឹងកង្វះភាពគួរឱ្យទុកចិត្តបាន ភាពមិនស្មោះត្រង់និងភាពមិនពិត ហើយជាទូទៅ វាមានវិបាកដែលមិនគួរឱ្យចង់បាន។<br>( ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាសីលធម៌ ) |
| **៤៦- ពូជសាសន៍និយម/ ពូជនិយម**<br>អ. racism<br>បារ. racisme ( m. ) | អំណះអំណាងមួយដែលថា មានឋានានុក្រមនៃសមត្ថភាពឬតម្លៃដែលកំណត់ដោយជីវសាស្ត្រក្នុងចំណោមពូជផ្សេងៗគ្នានិងអះអាងដោយខុសឆ្គងថា ពូជទាបគួរត្រូវបានគ្រប់គ្រងដោយពូជខ្ពស់។ ជាទូទៅ ពូជសាសន៍និយម/ពូជនិយម បង្កប់ឬជំរុញដោយការភ័យខ្លាចនិងការស្អប់ខ្ពើម ហើយដែលនាំទៅដល់អំពើហិង្សា ឬអំពើប្រល័យពូជសាសន៍ទ្រង់ទ្រាយធំៗ។<br>( ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជានយោបាយ ) |
| **៤៧- ព្រលឹង**<br>អ. soul<br>បារ. âme ( f. ) | ផ្នែកអរូបធាតុដែលគេសន្មតថាមានវត្តមានតែនៅក្នុងភាវៈរស់ប៉ុណ្ណោះ។ ដោយសារតែហាក់ដូចជាគ្មានភាពខុសគ្នាខាងរូបធាតុរវាងភាវៈរស់នៅក្នុងខណៈនៃជីវិតដែលហៀបនឹងស្លាប់ និងរាងកាយដែលទើបនឹងស្លាប់ថ្មីៗ ទើបទស្សនវិទូជាច្រើនតាំងពីសម័យប្លាតុង( Plato )បានអះអាងថា ព្រលឹង គឺជាសមាសភាគអរូបធាតុរបស់ភាវៈរស់។ ដោយហេតុថាមានតែវត្ថុរូបធាតុប៉ុណ្ណោះដែលមានទីបញ្ចប់ ទើបប្លាតុង ចាត់ទុកថាភាពអរូបធាតុរបស់ព្រលឹងជាមូលដ្ឋាននៃអមតភាពរបស់ព្រលឹង។ ទាំងប្លាតុង ទាំងអារីស្តូត មិនបានគិតថា មានតែមនុស្សទេដែលមានព្រលឹង ៖ អារីស្តូត អះអាងថា ព្រលឹងក៏មានចំពោះសត្វនិងរុក្ខជាតិដែរ ពីព្រោះសត្វនិងរុក្ខជាតិសុទ្ធតែបង្ហាញមុខងារខ្លះជាភាវៈមានជីវិត។ ខុសពីប្លាតុង អារីស្តូតបដិសេធការចាកចេញនៃព្រលឹងពីអម្បូរមួយទៅអម្បូរមួយទៀតឬពីរាងកាយមួយទៅរាងកាយមួយទៀតបន្ទាប់ពីការស្លាប់។ គាត់សង្ស័យចំពោះសមត្ថភាពចាកចេញពីរាងកាយរបស់ព្រលឹង ថាតើព្រលឹងអាចចាកចេញដោយរលូន នៅមានជីវិត និងបំពេញមុខងារដោយគ្មានរាងកាយបានដែរឬទេ។ រ៉ឺណេ ដេកាត ( René Déscartes ) អះអាងថា មានតែមនុស្សទេដែលមានព្រលឹងនិងអះអាងថា ធម្មជាតិអរូបធាតុរបស់ព្រលឹងអាចបង្កើតសេរីភាពបានទោះបីជារាងកាយរបស់មនុស្សស្ថិតនៅ ឬមិនស្ថិតនៅក្រោមការកំណត់របស់ច្បាប់រូបធាតុក៏ដោយ។ |

| | |
|---|---|
| **៤៨- ព្រះរាជបុត្រា/ ទេវបុត្រា**<br>អ. God the Son<br>បារ. Dieu le fils | ឈ្មោះដែលគ្រិស្តសាសនិកផ្តល់ឱ្យព្រះយេស៊ូគ្រិស្ត ជាពិសេស សំដៅដល់តួអង្គមួយក្នុងចំណោមត្រីអង្គ។ ព្រះរាជបុត្រា/ទេវបុត្រា ឬយេស៊ូគ្រិស្ត គឺជាតួអង្គសំខាន់ទីពីរក្នុងគ្រិស្តសាសនា ដែលប្រសូតនៅចន្លោះឆ្នាំទី៨ និង ឆ្នាំទី៤ មុនគ្រិស្តសករាជ ហើយសោយទិវង្គតប្រហែលក្នុងឆ្នាំ២៩ នៃគ្រិស្តសករាជនៅក្រុងបេថ្លេអែម( Bethléem ) ខេត្តជូដា( Judaea )ចក្រភពរ៉ូម៉ាំង។<br>( បញ្ញត្តិនេះ គេប្រើក្នុងគ្រិស្តសាសនា ) |
| **៤៩- ព្រះវរបិតា**<br>អ. God the father<br>បារ. Dieu le père | ព្រះនាមដែលគ្រិស្តសាសនិកថ្វាយដល់អាទិទេពនៅក្នុងគ្រិស្តសាសនា។ ព្រះវរបិតាត្រូវគេចាត់ទុកថា ជាតួអង្គសំខាន់ទីមួយនៅក្នុងត្រីអង្គ ជាព្រះបិតារបស់ព្រះយេស៊ូគ្រិស្តនិងជាអ្នកបង្កើតចក្រវាល។<br>( បញ្ញត្តិនេះ គេប្រើក្នុងបរិបទគ្រិស្តសាសនា ) |
| **៥០- ព្រះវិញ្ញាណបរិសុទ្ធ**<br>អ. God the Holy Spirit<br>បារ. Dieu le Saint-Esprit | ព្រះនាម ដែលគ្រិស្តសាសនិកថ្វាយដល់អាទិទេពនៅក្នុងគ្រិស្តសាសនា។ ព្រះវិញ្ញាណបរិសុទ្ធ គឺជាតួអង្គសំខាន់ទីបីនៅក្នុងត្រីអង្គនិងជាកម្លាំងខាងស្មារតីរបស់អាទិទេព។<br>( បញ្ញត្តិនេះ គេប្រើក្នុងបរិបទគ្រិស្តសាសនា ) |
| **៥១- ភាពចាំបាច់ដាច់ខាត**<br>អ. absolute necessity<br>បារ. nécessité absolue | ភាពចាំបាច់ដែលមាននៅក្នុងខ្លួនរបស់វា ហើយភាពចាំបាច់ដាច់ខាតនេះត្រូវបានហៅផងដែរថា ភាពចាំបាច់ខាងគណិតវិទ្យា ភាពចាំបាច់ខាងអស្តិរូបវិជ្ជា ឬភាពចាំបាច់ខាងតក្កវិជ្ជា។ ភាពចាំបាច់ដាច់ខាតនេះ ផ្ទុយពីភាពចាំបាច់សន្មត។ ភាពចាំបាច់ដាច់ខាតនេះគឺជាករណីសាកលនិងគ្មានលក្ខខណ្ឌ។ សច្ចភាពនៃភាពចាំបាច់ប្រភេទនេះ គឺជាសច្ចភាពនៃវិចារណញ្ញាណ។<br>( ពាក្យនេះ គេប្រើ នៅក្នុងតក្កវិជ្ជា អស្តិរូបវិជ្ជា និងទស្សនវិជ្ជាអំពីគណិតវិទ្យា ) |
| **៥២- ភាពចាំបាច់សន្មត**<br>អ. hypothetical necessity<br>បារ. nécessité hypothétique | ភាពចាំបាច់ដែលគេផ្តល់ឱ្យដូចដែលមានអត្ថិភាពនៅក្នុងសង្គម ហើយភាពចាំបាច់សន្មតនេះត្រូវបានហៅផងដែរថា ភាពចាំបាច់ខាងសីលធម៌ ភាពចាំបាច់ខាងវិបាក ឬភាពចាំបាច់ខាងរូបី។ យោងតាម ឡេបនីស( Leibniz ) សភាពរបស់ពិភពលោកបច្ចុប្បន្នមិនមែនជាភាពចាំបាច់ដាច់ខាតទេ ប៉ុន្តែ វាគ្រាន់តែជាភាពចាំបាច់សន្មតប៉ុណ្ណោះ។ ចំណែកឯទស្សនវិទូផ្សេងៗទៀត បានហៅភាពចាំបាច់សន្មតនេះថា ជាភាពចាំបាច់មិនដាច់ខាត ពីព្រោះ វាទាក់ទងទៅនឹងការសន្មតជាមូលដ្ឋានណាមួយ។ |
| **៥៣- ភាវៈមនុស្ស**<br>អ. human being<br>បារ. être humain | ចំពោះអារីស្តូត( Aristotle ) «ភាវៈមនុស្ស» គឺជាសត្វប្រកបដោយវិចារណញ្ញាណ។ ចំពោះរ៉ឺណេដេកាត( René Déscartes )«ភាវៈមនុស្ស» មិនមែនជា |

| | |
|---|---|
| | សរីរាង្គតែមួយទេ ប៉ុន្តែវាជាបន្សំនៃធាតុខុសគ្នាពីរគឺចិត្តនិងកាយ។ ទោះបីជាមានភាពខុសគ្នាក្នុងការកំណត់បញ្ញត្តិភាវៈមនុស្សរវាងអារីស្តូត និងរ៉ឺណេដេកាតក៏ដោយ ក៏អ្នកទាំងពីរបានចាត់ទុកថា វិចារណញ្ញាណ គឺជាលក្ខណៈសំខាន់នៃភាវៈមនុស្ស។ ភាវៈមនុស្សត្រូវបានគេប្រើជាសទិសន័យជាមួយពាក្យ«មនុស្ស» ដែលគេយល់ថា ជាភាវៈមួយដែលមានសិទ្ធិមិនអាចដកហូតបានពោលគឺសិទ្ធិរស់រានមានជីវិត និងសិទ្ធិមានសេរីភាពព្រមទាំងជាភាវៈមួយខ្ពស់ជាងសត្វផ្សេងៗដែលមិនមែនជាមនុស្ស។ ទស្សនវិជ្ជាសីលធម៌ សហសម័យមានទំនោរចង់ផ្តាច់«មនុស្ស»ចេញពី«ភាវៈមនុស្ស» ដោយជឿថា «មនុស្ស» គឺជាភាវៈដែលមានស្វ័យញាណ ចំណែកឯ«ភាវៈមនុស្ស»គ្រាន់តែជាសមាជិកនៃពូជដើមរបស់មនុស្សគឺអូម៉ូសាព្យាង(Homo sapiens) ប៉ុណ្ណោះ។<br>(ពាក្យនេះ គេប្រើនៅក្នុងអស្តិរូបវិជ្ជា សីលវិជ្ជា និងទស្សនវិជ្ជាអំពីចិត្ត)។ |
| **៥៤- ភ្នាក់ងារ**<br>អ. agent<br>បារ. agent (m.) | មនុស្សដែលប្រកបដោយវិចារណញ្ញាណនិងជាប្រធាននៃអំពើ ដែលអាចសម្រេចចិត្តធ្វើឬមិនធ្វើអំពើណាមួយ ហើយអាចពិចារណារកវិធី និងអនុវត្តវិធីនោះដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរ។<br>(ពាក្យនេះប្រើក្នុងទស្សនវិជ្ជាស្តីពីអំពើ និងសីលវិជ្ជា) |
| **៥៥- មនសិការ**<br>អ. conscience<br>បារ. conscience (f.) | ការភ្ញាក់រលឹករបស់មនុស្សដែលជួយឱ្យមនុស្សស្គាល់ត្រូវ ស្គាល់ខុស និងដឹងថាអ្វីគួរធ្វើ អ្វីមិនគួរធ្វើ។ មនសិការត្រូវបានគេជឿថាជាប្រភពមួយក្នុងចំណោមប្រភពសំខាន់ៗនៃសីលធម៌។ ទស្សនវិទូផ្សេងៗបានយល់ខុសគ្នាអំពីមនសិការដោយចាត់ទុកមនសិការថាជាសមត្ថភាពខាងសីលញាណរបស់មនុស្ស សំឡេងរបស់អាទិទេព សតិផ្ទាល់ខ្លួន និងជាសំឡេងរបស់វិចារណញ្ញាណ។ |
| **៥៦- មនុស្សជាតិ**<br>អ. humanity<br>បារ. humanité (f.) | ភាពរួមនៃអម្បូរមនុស្សទាំងមូល។ គំនិតនេះចាប់ផ្តើមដោយអ្នកអត់ធ្មត់និយមដែលតែងយល់ថា មនុស្សជាតិជាកម្មវត្ថុនៃការគោរពនៅក្នុងជីវិតប្រកបដោយសីលធម៌។ ដោយឡែក នៅក្នុងសតវត្សរ៍ទី២០ កាស្ស៊ីរ័រ(Cassirer)បានស្នើថាមនុស្សជាតិគួរត្រូវបានគេយល់ក្នុងក្របខណ្ឌនៃសកម្មភាពដែលនាំទៅដល់ស្នាដៃខាងវប្បធម៌និងប្រវត្តិសាស្ត្រ។ ស៊ីស៊ីរ៉ូ(Cicero) និងសេណេកា(Seneca) បានបង្កើតពាក្យមនុស្សជាតិសម្គាល់ន័យថា ជាឧត្តមគតិខាងសីលធម៌ សោភ័ណ ឬវិថីនៃជីវិត ជាគំនិតមួយដែលត្រូវបានគេធ្វើឱ្យរស់ឡើងវិញនៅក្នុងបុនសម័យ ឬសម័យកកើតឡើងវិញ។<br>(ពាក្យនេះ គេប្រើនៅក្នុងសីលវិជ្ជានិងសោភណវិជ្ជា) |
| **៥៧- យុត្តសង្គ្រាម**<br>អ. just war<br>បារ. juste la guerre | ទ្រឹស្តីយុត្តសង្គ្រាមដំបូងបង្អស់ជាប់ពាក់ព័ន្ធទៅនឹងគំនិតរបស់និកាយកាតូលិកដែលអះអាងថា ការប្រើកម្លាំង គឺជាអំពើត្រឹមត្រូវតាមច្បាប់សម្រាប់ដាក់ទោសអ្នកប្រព្រឹត្តអាក្រក់ប្រឆាំងនឹងសាសនារបស់ខ្លួន។ បច្ចុប្បន្ន វាជាប្រធានបទ |

| | |
|---|---|
| | សំខាន់មួយនៅក្នុងទស្សនវិជ្ជានយោបាយ ដែលចាត់ទុកការប្រើប្រាស់កម្លាំងសម្រាប់គោលបំណងខាងនយោបាយថាជារឿងត្រឹមត្រូវខាងសីលធម៌។ ជាធម្មតាទ្រឹស្តីយុត្តសង្គ្រាមពាក់ព័ន្ធនឹងលក្ខខណ្ឌពីរ ពោលគឺ បុព្វហេតុត្រឹមត្រូវចំពោះសង្គ្រាម និងមធ្យោបាយត្រឹមត្រូវរបស់សង្គ្រាម។ បុព្វហេតុត្រឹមត្រូវសំដៅយកការធ្វើសង្គ្រាមដើម្បីការពារព្រំដែន ឆ្លើយតបទៅនឹងការឈ្លានពាន និងស្វែងរកសន្តិភាព។ មធ្យោបាយត្រឹមត្រូវ គឺសំដៅយកការប្រើប្រាស់អាវុធធម្មតាសម្រាប់ធ្វើសង្គ្រាម ដោយជៀសវាងការប្រើប្រាស់អាវុធមហាប្រល័យ ដូចជា អាវុធបរមាណូ អាវុធជីវសាស្ត្រ និងអាវុធគីមី ជាដើម។ យុត្តសង្គ្រាមត្រូវតែផ្តួចផ្តើម ដឹកនាំ និងប្រកាសជាផ្លូវការដោយអាជ្ញាធរធម្មានុរូប ត្រូវតែប្រយុទ្ធដើម្បីបុព្វហេតុយុត្តិធម៌ ប្រកបដោយគោលបំណងត្រឹមត្រូវ និងត្រូវតែការពារនិងជៀសវាងការសម្លាប់បុគ្គលិកយោធាដែលមិនប្រយុទ្ធ(គ្រូពេទ្យ បព្វជិត...)ជាពិសេស ប្រជាជនដែលគ្មានកំហុស។<br>(ពាក្យនេះ គេប្រើក្នុងបរិបទសីលវិជ្ជានិងទស្សនវិជ្ជានយោបាយ) |
| **៥៨- រាជានិយម**<br>អ. royalism<br>បារ. royalisme (m.) | ទស្សនៈដែលគាំទ្រគោលការណ៍ដឹកនាំដោយក្សត្រឬសន្តតិវង្សណាមួយនិងជំនឿចំពោះអំណាចធម្មានុរូបរបស់រដ្ឋបាលរាជាធិបតេយ្យឬក្សត្រ។ |
| **៥៩- រូបតំណាង**<br>អ. realistic statue<br>បារ. statue réaliste | រូបភាពដែលប្រត្យក្សារម្មណ៍ផ្តល់ឱ្យអង្គចងចាំ(លំនឹក) នៅពេលដែលមនុស្សបានជួបប្រាស្រ័យផ្ទាល់ជាមួយអង្គវត្ថុជាច្រើនលើក ហើយបានផ្តិតស្លាកស្នាមរបស់វាចូលទៅក្នុងខួរក្បាលមនុស្ស ក្រោយមកអង្គចងចាំបង្ហាញឡើងវិញនូវលក្ខណៈពិសេសមួយចំនួន ពេលដែលមនុស្សមិននៅផ្ទាល់ជាមួយអង្គវត្ថុ។ |
| **៦០- លូថែនិយម**<br>អ. Lutheranism<br>បារ. Luthéranisme (m.) | ទម្រង់ដំបូងនៃលទ្ធិប្រូតេស្តង់ដែលបង្កើតឡើងដោយ ម៉ាទីន លូថែ (Martin Luther 1483-1546 German) នាសតវត្សរ៍ទី១៦ នៅប្រទេសអាល្លឺម៉ង់។ លទ្ធិនេះផ្តោតទៅលើការបង្រៀនរបស់ព្រះយេស៊ូគ្រិស្ត និងសង្កត់ធ្ងន់ទៅលើជំនឿនិងសេចក្តីស្មោះត្រង់របស់បុគ្គលទៅលើអំណាចរួមរបស់សហគមន៍គ្រិស្ត-សាសនា។ លូថែនិយមសាយភាយដំបូងឆ្លងកាត់អឺរ៉ុបខាងជើង ជាពិសេសឆ្លងកាត់តំបន់ស្កង់ឌីណាវី (Scandinavia) បច្ចុប្បន្ន លទ្ធិនេះត្រូវបានគេប្រតិបត្តិពាសពេញពិភពលោក។ |
| **៦១- វប្បធម៌ស្ថាប័ន**<br>អ. organizational culture<br>បារ. culture organisationnelle | ឥរិយាបថរួមរបស់មន្ត្រីនិងបុគ្គលិក ដែលជាផ្នែកមួយរបស់ស្ថាប័ន និងជាតម្លៃដែលមនុស្សចងភ្ជាប់ទៅនឹងការងារឬអំពើរបស់ពួកគេ។ វប្បធម៌នេះ រួមមានតម្លៃទស្សនវិស័យ និយាម ភាសា ការងារ ប្រព័ន្ធសញ្ញា ជំនឿ និងទម្លាប់របស់ស្ថាប័ន។ វប្បធម៌ស្ថាប័នជះឥទ្ធិពលលើរបៀបដែលមនុស្ស និងក្រុមនីមួយៗធ្វើអន្តរកម្មជាមួយគ្នា លើអតិថិជន និងលើអ្នកពាក់ព័ន្ធផ្សេងទៀត។ ឧទាហរណ៍ |

| | |
|---|---|
| | សមាជិកថ្មីនៃស្ថាប័ននីមួយៗ តែងតែត្រូវបានគេបង្រៀនអំពីវប្បធម៌ស្ថាប័នជាពិសេស បង្រៀនអំពីគំរូនៃឥរិយាបថ និងការកំណត់រួម ដែលទាក់ទងទៅនឹងវិធីនៃការយល់ឃើញ ការគិត និងការមានអារម្មណ៍អំពីការងារ។ |
| **៦២- វិជ្ជមាននិយម**<br>អ. positivism<br>បារ. positivisme ( m. ) | ប្រព័ន្ធគំនិតទស្សនវិជ្ជា ដែលបង្កើតឡើងដោយទស្សនវិទូបារាំង អូហ្គុកុង (Auguste Comte) ប៉ុន្តែឫសគល់របស់វាចេញមកពីហ្វ្រង់ស៊ីសបេខឹន (Francis Bacon)។ ស្មារតីរួមរបស់វិជ្ជមាននិយមគឺថា ទស្សនវិជ្ជាគួរតែផ្តោតការយកចិត្តទុកដាក់តែទៅលើអ្វីដែលបទពិសោធផ្តល់ឱ្យជាក់ស្តែង និងគួរតែចៀសវាងពីការគិតបែបសន្មត ដែលទៅហួសពីបទពិសោធ។ ដូច្នេះ វិជ្ជមាននិយមចាត់ទុកការសិក្សាអំពីវិធីវិទ្យាសាស្ត្រថាជាកិច្ចការចម្បងរបស់ខ្លួននិងបង្ហាញខ្លួន ឯងថាជាប្រភេទនៃទស្សនវិជ្ជាអំពីវិទ្យាសាស្ត្រ។<br>( ពាក្យនេះគេប្រើនៅក្នុងទស្សនវិជ្ជា អំពីវិទ្យាសាស្ត្រ ពុទ្ធិវិទ្យា ទស្សនវិជ្ជាអំពីវិទ្យាសាស្ត្រសង្គម និងទស្សនវិជ្ជា អំពីសាសនា )។ |
| **៦៣- វិធីសូន្យ**<br>អ. zero method<br>បារ. méthode zéro | វិធីមួយដែលបង្ហាញយ៉ាងច្បាស់អំពីទម្រង់មូលដ្ឋាននៃភាសាដោយការបង្កើតពាក្យមួយតាមរយៈបន្សំនៃសញ្ញានានា។ ដោយសារតែទម្រង់តែមួយគត់របស់វាសញ្ញាទាំងនេះបានលុបចោលទាំងស្រុងនូវខ្លឹមសាររូបធាតុរបស់ខ្លួន។ វិធីសូន្យគឺជាវិធីតក្កវិជ្ជាស្តីពីការបង្កើតគំរូមួយផ្អែកលើការសន្មតទៅតាមសនិទានភាព។ ឧទាហរណ៍៖ ក្នុងវិធីសូន្យ គេបង្កើតពាក្យ «ត្រី» ( បញ្ញត្តិត្រី ) ពីទម្រង់ ឬរូបរាងផ្សេងៗរបស់សត្វត្រីជាក់ស្តែង។<br>( ពាក្យនេះ គេប្រើក្នុងតក្កវិជ្ជា និងទស្សនវិជ្ជាអំពីភាសា ) |
| **៦៤- វិភាគ**<br>អ. analysis<br>បារ. analyse ( f. ) | ដំណើរនៃការគិតដោយបំបែកបញ្ហាទាំងមូលទៅជាសមាសភាគរបស់វា និងទំនាក់ទំនងរវាងសមាសភាគទាំងនោះ។ |
| **៦៥- វិរុទ្ធនិទស្សន៍ករណីដោយឡែក**<br>អ. fallacy of secundum quid<br>បារ. erreur de secundum quid | ការយល់ខុសដោយការគិតមិនគ្រប់ជ្រុងជ្រោយអំពីគុណវុឌ្ឍិ ដែលប្រើគំនិតខុសឆ្គងថា អ្វីដែលពិតដោយមានគុណវុឌ្ឍិជាក់លាក់ណាមួយ វាក៏ពិតដោយគ្មានគុណវុឌ្ឍិជាក់លាក់នោះដែរ។ វិរុទ្ធនិទស្សន៍ករណីដោយឡែកស្រដៀងគ្នាទៅនឹងវិរុទ្ធនិទស្សន៍ចៃដន្យ ដែលប្រើគោលការណ៍ឬវិធានទូទៅ ដោយមិនគិតពីទិដ្ឋភាពជាក់លាក់នៃកាលៈទេសៈក្នុងការប្រើប្រាស់របស់វា។ វិរុទ្ធនិទស្សន៍ករណីដោយឡែក មានទម្រង់បន្ថែមមួយទៀតដែលធ្វើទូទៅនីយកម្មវិធានមួយចេញពីតួយ៉ាងណាមួយដែលអាចមានលក្ខណៈដោយឡែកឬករណីលើកលែង។ នៅក្នុងទម្រង់នេះ វិរុទ្ធនិទស្សន៍ករណីដោយឡែក ធ្វើទូទៅនីយកម្មយ៉ាងប្រញាប់ប្រញាល់ដោយចេញពីករណីដោយឡែកទៅរកករណីទូទៅ។ ឧទាហរណ៍ : សៅជាខ្មែរ គាត់រួសរាយចំពោះមនុស្សគ្រប់គ្នា ដូច្នេះខ្មែរទាំងអស់រួសរាយ។ |

| | |
|---|---|
| | ឧទាហរណ៍ : វិចិត្រករ ញ៉ឹក ឌឹម ជាជនជាតិខ្មែរ គាត់មានទេពកោសល្យ គូររូបទេសភាពនិងសម្រស់នារីខ្មែរ ដូច្នេះវិចិត្រករខ្មែរទាំងអស់សុទ្ធតែមានទេពកោសល្យគូររូបទេសភាព និងសម្រស់នារីខ្មែរ។ |
| **៦៦- វិរុទ្ធនិទស្សន៍បុព្វហេតុមិនពិត**<br>អ. fallacy of false cause<br>បារ. erreur de la fausse cause | ហេតុផលនៃទឡ្ហីករណ៍ដែលអះអាងថា ក្នុងចំណោមវត្ថុជាប់ទាក់ទងគ្នាពីរ ក និង ខ, ក ជាបុព្វហេតុរបស់ ខ ដោយសារតែ ក នៅមុន ខ។ ដូចគ្នានេះដែរ វិរុទ្ធនិទស្សន៍បុព្វហេតុមិនពិតគឺជាទឡ្ហីករណ៍មួយដែលផ្ដល់ហេតុផលខុសឆ្គង ដោយភ្ជាប់ព្រឹត្តិការណ៍ បាតុភូត ឬសកម្មភាពពីរឬច្រើន ដែលកើតឡើងបន្តបន្ទាប់គ្នា ដោយអះអាងថា ព្រឹត្តិការណ៍ បាតុភូត ឬ សកម្មភាពទី១ បណ្ដាលឱ្យកើតព្រឹត្តិការណ៍ បាតុភូត ឬសកម្មភាពបន្តបន្ទាប់។ ឧទាហរណ៍១ : ក្រោយមាន់រងាវព្រះអាទិត្យរះ ដូច្នេះ មាន់រងាវបណ្ដាលឱ្យព្រះអាទិត្យរះ។ ឧទាហរណ៍២ : ជានិច្ចកាល ខ្ញុំផឹកតែក្រោយអាហារថ្ងៃត្រង់ ដូច្នេះ អាហារថ្ងៃត្រង់ជាបុព្វហេតុនៃការផឹកតែរបស់ខ្ញុំ។ អំណះអំណាងទាំងនេះមិនត្រឹមត្រូវទេ ព្រោះមានការភាន់ច្រឡំរវាងលំដាប់និងដំណើរនៃបុព្វហេតុ។ វាផ្លាស់ពីលំដាប់នៃព្រឹត្តិការណ៍ដែលគ្រាន់តែទាក់ទងនឹងពេលវេលាទៅលំដាប់ខាងបុព្វហេតុ។ បុព្វហេតុមិនពិតមិនបណ្ដាលឱ្យមានវិបាកទេ ហើយក៏មិនមែនជាបុព្វហាតុទាល់តែសោះ។ (ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា) |
| **៦៧- វិរុទ្ធនិទស្សន៍ពន្ធុ**<br>អ. genetic fallacy<br>បារ. erreur génétique | ទឡ្ហីករណ៍ដែលវិនិច្ឆ័យ វាយតម្លៃឬពន្យល់អ្វីមួយផ្អែកតែទៅលើប្រភពកំណើតឬបរិបទដើម ដែលវាកើតឡើងឬត្រូវបានបង្កើតឡើងដោយមិនផ្អែកលើការវិវត្តឬបច្ចុប្បន្នភាពរបស់វា។ ដោយសារវាអាចមានភាពខុសគ្នាសំខាន់ៗមួយចំនួនរវាងប្រភពកំណើតនៃអ្វីមួយ និងសភាពបច្ចុប្បន្នរបស់វា ទើបទឡ្ហីករណ៍បែបនេះតែងតែត្រូវបានចាត់ទុកថា ជាវិរុទ្ធនិទស្សន៍ពន្ធុ ជាពិសេស នៅពេលគេប្រើទឡ្ហីករណ៍នោះ ដើម្បីបដិសេធគំនិតជំទាស់ណាមួយ។ មនុស្សដែលមានប្រភពកំណើតចេញពីសត្វស្វាមិនមានន័យថា ពួកគេនៅតែជាសត្វស្វានោះទេ។ (ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា) |
| **៦៨- វិរុទ្ធនិទស្សន៍សមាសភាព**<br>អ. fallacy of composition<br>បារ. erreur de composition | ប្រភេទនៃការផ្ដល់ហេតុផលខុស ដែលអះអាងថា បើផ្នែកនីមួយៗនៃអង្គទាំងមូលមានលក្ខណសម្បត្តិជាក់លាក់ណាមួយ នោះអង្គទាំងមូលក៏មានលក្ខណសម្បត្តិដូចនោះដែរ។ ឧទាហរណ៍ : បើគ្រឿងបង្គុំនីមួយៗរបស់រថយន្តមួយមានគុណភាពល្អនាំឱ្យរថយន្តនោះក៏មានគុណភាពល្អដែរ។ បច្ចេកសព្ទនេះក៏ត្រូវបានគេប្រើដែរសម្រាប់ទឡ្ហីករណ៍មួយដោយផ្ដើមចេញពីមូលបដិញ្ញាដែលថា ជាតុនីមួយៗនៃបណ្ដុំមួយមានលក្ខណសម្បត្តិជាក់លាក់ណាមួយ ឈានទៅដល់ការសន្និដ្ឋានថា បណ្ដុំនោះក៏មានលក្ខណសម្បត្តិដូចនោះដែរ។ ទឡ្ហីករណ៍នេះគ្មានសុពលភាពទេ ព្រោះវាសន្មតដោយខុសឆ្គងថា អង្គទាំងមូលឬបណ្ដុំជាការផ្គុំគ្នាយ៉ាងសាមញ្ញមួយនៃផ្នែកឬជាតុនីមួយៗ។ ដោយបញ្ច្រាសមកវិញ |

| | |
|---|---|
| | វិរុទ្ធនិទស្សន៍ បំបែកដែលអះអាងថា ប្រសិនបើអង្គទាំងមូល ឬ បណ្តុំមួយមានលក្ខណសម្បត្តិជាក់លាក់ណាមួយ ជាតុឬផ្នែកនីមួយៗក៏មានលក្ខណសម្បត្តិដូចនោះដែរ។ ឧទាហរណ៍ : សហរដ្ឋអាម៉េរិកជាប្រទេសអ្នកមាន ដូច្នេះ ពលរដ្ឋអាម៉េរិកម្នាក់ៗ ក៏ជាអ្នកមានដែរ។ វិរុទ្ធនិទស្សន៍នេះមិនដឹងថា មិនមានទំនាក់ទំនងផ្ទេររវាងអង្គទាំងមូលនិងផ្នែកផ្សេងៗរបស់វាទេ។ ទាំងវិរុទ្ធនិទស្សន៍សមាសភាព ទាំងវិរុទ្ធនិទស្សន៍បំបែកគឺជាគំរូរបស់វិរុទ្ធនិទស្សន៍នៃភាពមិនច្បាស់លាស់ ពីព្រោះជាញឹកញាប់ វិរុទ្ធនិទស្សន៍ទាំងពីរនេះជាប់ពាក់ព័ន្ធនឹងការភាន់ច្រឡំរវាងការប្រើប្រាស់ដាច់ដោយឡែកៗ និងការប្រើប្រាស់បែបប្រមូលផ្តុំនៃពាក្យមួយ។<br>(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា) |
| **៦៩-វិរុទ្ធនិទស្សន៍សំណួរស្មុគស្មាញ**<br>អ. fallacy of many questions/fallacy of complex questions<br>បារ. erreur de nombreuses questions | ប្រភេទនៃសំណួរប្រកបដោយល្បិចបែបវោហារសាស្ត្រ ដែលអ្នកឆ្លើយមិនអាចគេចផុតពីការទទួលយកបុរេសន្មតរបស់អ្នកសួរបានឡើយ។ លោក សុខ សួរ លោក សៅ មួយសំណួរ ហើយទាមទារចម្លើយសាមញ្ញថា«បាទ»ឬ«ទេ»។ ប៉ុន្តែសំណួរនោះបង្កប់នូវបុរេសន្មតមិនសមហេតុផលណាមួយដែលតម្រូវឱ្យឆ្លើយដាច់ពីគ្នា។ ចម្លើយសាមញ្ញថា«បាទ»ឬ«ទេ»នឹងធ្វើឱ្យ លោក សៅ យល់ព្រមទទួលបុរេសន្មតដែលមិនសមហេតុផល។ ឧទាហរណ៍ : តើអ្នកឈប់វាយឪពុករបស់អ្នកហើយឬនៅ? មិនថាលោក សៅ ឆ្លើយ«បាទ»ឬ«ទេ» នោះទេ គឺចម្លើយរបស់គាត់បញ្ជាក់ថា គាត់យល់ព្រមទទួលស្គាល់ថា គាត់បានវាយឪពុករបស់គាត់ ប៉ុន្តែ តាមពិត វាអាចមិនដូច្នោះទេ។<br>(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា) |
| **៧០- វិរុទ្ធនិទស្សន៍សំនៀង**<br>អ. fallacy of accent<br>បារ. erreur d′ accent | ទឡ្ហីករណ៍មួយឈានទៅសន្និដ្ឋានដោយការផ្លាស់ប្តូរសំនៀងព្យាង្គនៃពាក្យមួយដែលធ្វើឱ្យខ្លឹមសាររបស់វាផ្លាស់ប្តូរ។ ជាការណ៍ពិត ទឡ្ហីករណ៍មួយបែបនេះគ្មានសុពលភាពទេ។ ក្រោយមកវិរុទ្ធនិទស្សន៍សំនៀងត្រូវបានពង្រីកគ្របដណ្តប់លើករណីផ្សេងៗ ដែលក្នុងនោះគេធ្វើទឡ្ហីកម្មដោយការសង្កត់សំឡេងលើផ្នែកផ្សេងៗនៃឈ្មោះមួយដែលធ្វើឱ្យអត្ថន័យរបស់វាក៏ផ្លាស់ប្តូរផងដែរ។ វិរុទ្ធនិទស្សន៍-សំនៀង ហៅម្យ៉ាងទៀតថាវិរុទ្ធនិទស្សន៍សង្កត់សូរ ហើយជានិច្ចកាល វាកើតឡើងនៅក្នុងភាសានិយាយ។ ឧទាហរណ៍ : - ខ្ញុំធ្វើស្រែ។(មុខរបររបស់ខ្ញុំធ្វើស្រែ) - ខ្ញុំ ធ្វើស្រែ។ (កាលណាគេនិយាយសង្កត់សូរទៅលើពាក្យខ្ញុំ មានន័យថា ខ្ញុំមិនសមធ្វើ ស្រែទេ ឬអាចមានន័យថា ខ្ញុំសប្បាយចិត្តនឹងធ្វើស្រែ)។<br>(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា) |

| | |
|---|---|
| **៧១- វិសេសានុមាន**<br>អ. abduction<br>បារ. enlèvement ( m. )/ abduction ( f. ) | វិធីបង្ហាញពីដំណើរនៃការប្រើប្រាស់ភស្តុតាង ដើម្បីឈានទៅរកការសន្និដ្ឋានមួយដ៏ទូលំទូលាយ ដែលជាការពិចារណាមួយឆ្ពោះទៅរកការពន្យល់មួយសមហេតុផលបំផុត។ វិសេសានុមានបង្ហាញដោយទស្សនវិទូជនជាតិអាម៉េរិក ឆាល សេនដឺ ផៀស (Charles Sanders Peirce ១៨៣៩-១៩១៤) ដែលលោកបានចាត់ទុកថា វិសេសានុមានជារបៀបបែបច្នៃប្រឌិតក្នុងការទាញសេចក្ដីសន្និដ្ឋាន ប៉ុន្តែគាត់បញ្ជាក់ថា លទ្ធផលនៃការសន្និដ្ឋាននេះ ត្រូវស្ថិតនៅក្រោមការវាយតម្លៃប្រកបដោយវិចារណញ្ញាណ។<br>ឧទាហរណ៍៖<br>១- អនុមានញែក( Deduction )<br>- ក្បួន( rule ) : សណ្ដែកទាំងអស់នៅក្នុងថង់នេះពណ៌ស<br>- ករណី( case ) : សណ្ដែកទាំងនេះ យកចេញពីថង់នេះ<br>- លទ្ធផល( result ) : សណ្ដែកទាំងនេះ ពណ៌ស។<br>២- អនុមានរួម ( Induction )<br>- ករណី( case ) : សណ្ដែកទាំងនេះ យកចេញពីថង់នេះ<br>- លទ្ធផល ( result ) : សណ្ដែកទាំងនេះ ពណ៌ស<br>- ក្បួន( rule ) : សណ្ដែកទាំងអស់នៅក្នុងថង់នេះពណ៌ស។<br>៣- វិសេសានុមាន( Abduction )<br>- ក្បួន( rule ) : សណ្ដែកទាំងអស់នៅក្នុងថង់នេះពណ៌ស<br>- លទ្ធផល( result ) : សណ្ដែកទាំងនេះ ពណ៌ស<br>- ករណី ( case ) : សណ្ដែកទាំងនេះយកចេញពីថង់នេះ។<br>( បញ្ញត្តិនេះ គេប្រើនៅក្នុងតក្កវិជ្ជា ) |
| **៧២- សច្ចភាពចាំបាច់**<br>អ. necessary truth<br>បារ. vérité nécessaire | សច្ចភាពជម្មជាតិដែលមានសភាពពិតនៅក្នុងខ្លួនវា។ សច្ចភាពចាំបាច់ត្រូវតែពិត និងមិនអាចមិនពិតទេ។ សច្ចភាពបែបតក្កវិជ្ជា និងគណិតវិទ្យា ជាទូទៅត្រូវបានគេចាត់ទុកថាជាគំរូនៃសច្ចភាពចាំបាច់។ ពួកវិចារណញ្ញាណនិយម អះអាងថា សច្ចភាពចាំបាច់ គឺជាសច្ចភាពនៃវិចារណញ្ញាណ និងផ្អែកលើការយល់ឆ្លុះជ្រៅទៅក្នុងទំនាក់ទំនងពិតរវាងហេតុការណ៍នានា។ ចំណែកឯពួក-ពិសោធន៍និយមវិញ អះអាងថា ពុទ្ធិស្ដីពីពិភពលោកត្រូវតែផ្អែកលើការយល់ដឹងដោយវិញ្ញាណ។ ដូច្នេះ វាអាចគ្មានសច្ចភាពចាំបាច់ ឬមានសច្ចភាពចាំបាច់ ប៉ុន្តែ វាគ្មានការបញ្ជាក់ផ្ទាល់ពីពិភពពិតទេ។<br>( ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា ពុទ្ធិវិទ្យា អស្ដិរូបវិជ្ជា និងទស្សនវិជ្ជាអំពីវិទ្យាសាស្ត្រ ) |

| | |
|---|---|
| **៧៣- សត្យានុមតិភាព/ វត្ថុវិស័យភាព**<br>អ. objectivity<br>បារ. objectivité (f.) | អត្ថិភាពពិតនៃអ្វីមួយដែលមិនផ្អែកលើចំណាប់អារម្មណ៍ឬគំនិតរបស់មនុស្ស។ ឧទាហរណ៍ទី១ រសជាតិជូរនៃផ្លែអំពិលគឺជាសត្យានុម័តិភាព។ ឧទាហរណ៍ទី២ សច្ចភាពនៅក្នុងហេតុការណ៍មួយគឺជាសត្យានុម័តិភាព។ |
| **៧៤- សន្និដ្ឋភាព**<br>អ. acquaintance<br>បារ. connaissance (f.) | វិធីដែលប្រធានយល់ដឹងពីកម្មវត្ថុតាមរយៈបទពិសោធន៍ផ្ទាល់និងភ្លាមៗ។ សន្និដ្ឋភាពមានលក្ខណៈផ្ទុយពីការពិពណ៌នា ដែលក្នុងនោះកម្មវត្ថុនៃការពិពណ៌នាត្រូវបានគេស្គាល់តាមរយៈអន្តរការណ៍នៃការសន្និដ្ឋាន។ កម្មវត្ថុសន្និដ្ឋភាពកើតឡើងតាមរយៈទិន្នន័យខាងវិញ្ញាណ ការចងចាំ និងបញ្ញត្តិទូទៅ ដូចជា ភាពក្រហម ភាពមូល ជាដើម។ សញ្ញាណនៃសន្និដ្ឋភាពត្រូវបានគេប្រើដើម្បីកំណត់ព្រំដែនអ្វីដែលយើងអាចដឹងតាមរយៈការសង្កេតឃើញភ្លាមៗ។<br>(ពាក្យនេះ គេប្រើក្នុងពុទ្ធិវិទ្យា) |
| **៧៥- សព្ទវិវាទ**<br>អ. logomachy<br>បារ. logomachie (f.) | ការខ្វែងគំនិតគ្នាអំពីការប្រើប្រាស់ពាក្យ។ |
| **៧៦- សភាវគតិ**<br>អ. instinct<br>បារ. instinct (m.) | គំរូឥរិយាបថរបស់មនុស្សនិងសត្វដែលមានតាំងពីកំណើត ហើយមិនអាចផ្លាស់ប្តូរបានតាមកាលៈទេសៈ និងមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់គំនិតនិងវិចារណញ្ញាណឡើយ។ |
| **៧៧- សមធម៌**<br>អ. equity<br>បារ. équité (f.) | លក្ខខណ្ឌតម្រូវជាមូលដ្ឋាននៃយុត្តិធម៌សង្គម ដែលជាប់ពាក់ព័ន្ធនឹងភាពត្រឹមត្រូវ ឬចំណែកត្រឹមត្រូវ ហើយខុសពីសមភាព ឬចំណែកស្មើគ្នា។ មិនដូចសមភាពដាច់ខាត ដែលមិនបានពិចារណាពីភាពខុសគ្នាក្នុងករណីនីមួយៗនោះទេ សមធម៌ទាមទារឱ្យករណីដូចគ្នា ត្រូវបានគេប្រព្រឹត្តដោយស្មើភាពគ្នា និងករណីផ្សេងគ្នាត្រូវបានគេប្រព្រឹត្តដោយមិនស្មើភាពគ្នា។ ការបែងចែកធនធាននៅក្នុងសង្គមត្រូវកំណត់ដោយយោងទៅតាមគុណូបការៈ តម្រូវការ និងសមត្ថភាពរបស់អ្នកទទួល។ មានតែមនុស្សដែលស្ថិតក្នុងប្រភេទដូចគ្នា និងមានលក្ខខណ្ឌ ដូចគ្នាប៉ុណ្ណោះ ទើបត្រូវទទួលបានការប្រព្រឹត្តដូចគ្នា។ សមធម៌ ទាមទារឱ្យមានការបញ្ជាក់ពីវិធានទូទៅដើម្បីឆ្លើយតបទៅនឹងស្ថានភាពពិសេស និងស្វែងរកការផ្តល់សេចក្តីសម្រេចចិត្តត្រឹមត្រូវក្នុងករណីដោយឡែកៗ។<br>(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជានយោបាយ) |

| | |
|---|---|
| **៧៨- ស៊ីរ៉េណៃ**<br>អ. cyrenaics<br>បារ. cyrène | និកាយទស្សនវិជ្ជាតម្រេកនិយម ដែលបង្កើតឡើងដោយអារីស្ទិបកុសនៃស៊ីរ៉េន (Aristippus of Cyrene) ហើយបានរីកចម្រើននៅចុងសតវត្សរ៍ទី៤ មុនគ្រិស្តសករាជ។ អារីស្ទិបកុសបានអះអាងនៅក្នុងលទ្ធិសំខាន់របស់គាត់ថា ពុទ្ធិមានលក្ខណៈមិនអាចទុកចិត្តបាន និងគ្មានប្រយោជន៍ ហើយមនុស្សគួរខិតខំព្យាយាមត្រួតត្រាកាលៈទេសៈរបស់ខ្លួនជាជាងទុកឱ្យកាលៈទេសៈត្រួតត្រាពួកគេ។ ការស្វែងរកសេចក្តីរីករាយភ្លាមៗ គឺជាគោលបំណងសំខាន់នៃជីវិត។ សេចក្តី-រីករាយខាងវិញ្ញាណគួរឱ្យចង់បានជាងសេចក្តីរីករាយខាងបញ្ញា ដែលមានលក្ខណៈល្អិតល្អន់និងស្មុគស្មាញ ទោះបីជាសេចក្តីរីករាយមិនត្រូវបានស្វែងរកហួសពីព្រំដែនដែលបានកម្រិតដោយច្បាប់ និងប្រពៃណីទំនៀមទម្លាប់ក៏ដោយ។<br>(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាក្រិកបុរាណ) |
| **៧៩- សាកលរូបី**<br>អ. concrete universal<br>បារ. universel concret | បច្ចេកសព្ទមួយដែលបង្ហាញដោយហេហ្គែល(Hegel) ដើម្បីកែតម្រូវទស្សនៈបុរាណដែលថា សាកលគឺអរូបី ដោយផ្អែកទៅលើធម្មជាតិទូទៅនៃប្រភេទភាវៈមួយតាមរយៈអរូបីកម្ម។ ហេហ្គែល ជឿថាសាកលគឺជាទម្រង់រូបីជាជាងអរូបី។ "សាកលពិត"មិនមែនគ្រាន់តែជាបណ្តុំនៃលក្ខណៈទូទៅចំពោះវត្ថុមួយចំនួននោះទេ ប៉ុន្តែ វាជាការរៀបរាប់លម្អិតអំពីខ្លួនវា ឬការបញ្ជាក់យ៉ាងច្បាស់អំពីខ្លួនវា។ សាកលមិនមែនដាច់ចេញពីភាពដោយឡែកនានាទេ ហើយវាក៏មិនមែនទៅហួសពីភាពដោយឡែកដែរ។ ផ្ទុយទៅវិញ សាកលមានមកជាប់ជាមួយនឹងភាពដោយឡែក ដែលជាកត្តាសំខាន់នៃភាពដោយឡែកទាំងនោះ។<br>(ពាក្យនេះ គេប្រើនៅក្នុងបរិបទអស្តិរូបវិជ្ជា)។ |
| **៨០- សីលវិជ្ជាកាតព្វកិច្ច**<br>អ. deontological ethics<br>បារ. éthique déontologique | ជំហរសីលវិជ្ជានិយាមដែលវិនិច្ឆ័យសីលធម៌របស់អំពើមួយផ្អែកលើការអនុលោមតាមច្បាប់ឬវិធាននានាស្តីពីអំពើនោះ។ សីលវិជ្ជាកាតព្វកិច្ច គឺជាសីលធម៌ផ្អែកលើច្បាប់ឬវិធាននានា ឬកាតព្វកិច្ច ដែលសង្កត់ធ្ងន់ទៅលើអំពើត្រឹមត្រូវជាជាងវិបាកល្អ។ ពេលខ្លះ សីលវិជ្ជាកាតព្វកិច្ចត្រូវបានគេពិពណ៌នាថាជាសីលវិជ្ជាដែលផ្អែកលើ«កាតព្វកិច្ច»ឬ«ច្បាប់»ពីព្រោះច្បាប់ទាំងនោះចងភ្ជាប់អ្នកទៅនឹងកាតព្វកិច្ចរបស់អ្នក។ ជាទូទៅ សីលវិជ្ជាកាតព្វកិច្ចផ្ទុយទៅនឹងវិបាកនិយម សីលវិជ្ជាគុណធម៌ និងសីលវិជ្ជាប្រតិបត្តិនិយម។ នៅក្នុងបច្ចេកសព្ទសីលវិជ្ជាកាតព្វកិច្ច និងអំពើសំខាន់ជាងវិបាក។ |
| **៨១- សីលវិជ្ជាជីវៈ**<br>អ. bioethics<br>បារ. bioéthique (f.) | មែកធាងមួយនៃសីលវិជ្ជាអនុវត្ត ដែលទាក់ទងនឹងបញ្ហាសីលធម៌ស្តីពីជីវិត និងមរណភាព ដែលផ្តើមចេញពីការស្រាវជ្រាវខាងជីវសាស្ត្រនិងវេជ្ជសាស្ត្រទំនើប និងការប្រតិបត្តិក្នុងការថែទាំសុខភាព។ សីលវិជ្ជាជីវៈជាក្រមសីលធម៌នៃជីវិតតម្រូវឱ្យអ្នកស្រាវជ្រាវខាងជីវវិទ្យា វេជ្ជសាស្ត្រ ឱសថសាស្ត្រ បសុសាស្ត្រ គីមីសាស្ត្រ |

| | |
|---|---|
| | បរិស្ថានវិទ្យា និងបច្ចេកវិទ្យាផ្សេងៗប្រតិបត្តិតាម ហើយវាក៏ជានិយាមសីលធម៌មួយប្រើសម្រាប់វាស់អំពើរបស់អ្នកសិក្សាស្រាវជ្រាវក្នុងវិស័យខាងលើឱ្យដឹងថា តើពួកគេប្រតិបត្តិតាមគោលការណ៍សីលវិជ្ជាជីវៈបានកម្រិតណា។ បញ្ហាដែលពាក់ព័ន្ធនឹងសីលវិជ្ជាជីវៈ ដូចជា ការផ្តល់ធនធានវេជ្ជសាស្ត្រកម្រ កម្រិតស្វ័យភាពរបស់អ្នកជំងឺ ព្រមទាំងវិសាលភាពនិងព្រំដែននៃអំណាចរបស់វេជ្ជបណ្ឌិតនិងគិលានុបដ្ឋាក ការរំលូតកូននិងសុឃាត ការធ្វើពិសោធន៍លើមនុស្ស ការស្រាវជ្រាវពន្ធុ (ហ្សែន) ការពន្យារកំណើត បច្ចេកទេសក្នុងការបង្កកំណើតមនុស្ស ការពិនិត្យគភ៌ ការពពោះជំនួស ការបរិច្ចាគជាលិកាឬសរីរាង្គ ជាដើម។ |
| **៨២- សីលវិជ្ជានិយាម**<br>អ. normative ethics<br>បារ. éthique normative | សីលវិជ្ជាមួយប្រភេទ ដែលទាក់ទងនឹងការសម្រេចអំពីស្តង់ដា ឬខ្នាតគំរូ សីលធម៌ដែលកំណត់ថា ឥរិយាបថណាមួយត្រឹមត្រូវគួរធ្វើតាម និងឥរិយាបថខុសឆ្គងគួរជៀសវាង។ |
| **៨៣- សីលវិជ្ជាអនុវត្តន៍**<br>អ. applied ethics<br>បារ. éthique appliquée | សីលវិជ្ជាមួយប្រភេទដែលទាក់ទងនឹងការវិភាគជាក់លាក់អំពីបញ្ហាវិវាទប្បដិវាទ (បញ្ហាចម្រូងចម្រាស)ខាងសីលធម៌ ដូចជា ការរំលូតកូន ការសម្លាប់ទារក សិទ្ធិសត្វ កង្វល់ខាងបរិស្ថាន ការសម្លាប់មនុស្ស ដែលមានជំងឺធ្ងន់មើលមិនជា សីលធម៌សុខាភិបាល សីលធម៌ជំនួញ ការស្រឡាញ់ភេទដូចគ្នា សីលធម៌រួមភេទ ការកាត់ទោសប្រហារជីវិត និងសង្គ្រាមបរមាណូជាដើម។ |
| **៨៤- សីលវិជ្ជាអស្តិរូប**<br>អ. metaethics<br>បារ. méta-éthique | សីលវិជ្ជាមួយប្រភេទដែលសិក្សាអំពីប្រភពនិងអត្ថន័យនៃបញ្ញត្តិទស្សនវិជ្ជា-សីលធម៌។ |
| **៨៥- សុឃាត**<br>អ. euthanasia<br>បារ. euthanasie ( f. ) | ការប្រតិបត្តិនូវការបញ្ចប់ជីវិតអ្នកជំងឺដោយចេតនា ដើម្បីបំបាត់ការឈឺចាប់ខាងផ្លូវកាយនិងផ្លូវចិត្ត។ |
| **៨៦- សូហ្វីស**<br>អ. sophist<br>បារ. sophiste ( m. ) | កាលពីដំបូងពាក្យសូហ្វីសសំដៅយកមនុស្សដែលប្រកបដោយគតិបណ្ឌិត ដូចជា កវីនិពន្ធ អ្នកព្យាករ ព្រឹទ្ធាចារ្យប្រកបដោយភាពឈ្លាសវៃ។ ប៉ុន្តែ នៅក្នុងសតវត្សរ៍ទី៥មុនគ្រិស្តសករាជ ពាក្យសូហ្វីស សំដៅយកបច្ចេកសព្ទពិសេសមួយដែលមានន័យថា គ្រូបង្រៀនជំនាញដែលបានដើរផ្សេងព្រេងពីទីក្រុងមួយទៅទីក្រុងមួយដើម្បីបង្រៀនមុខវិជ្ជាជាច្រើនដែលមិនធ្លាប់មានពីមុនមក ដូចជា វោហារសាស្ត្រ ភាសាវិទ្យា ជាដើម ដែលយុវជនក្រិកត្រូវការជាចាំបាច់ដើម្បីបញ្ចុះបញ្ចូលអ្នកនយោបាយ។ សូហ្វីសបានយកថ្លៃបង្រៀនពីសិស្សដែលមករៀនជាមួយពួកគេ។ នៅក្នុងពេលនោះ ពាក្យ សូហ្វីសមិនមានន័យអវិជ្ជមាន ឬ |

| | |
|---|---|
| | ន័យអាក្រក់ទេ។ ពួកសូហ្វីសមិនមែនចេញមកពីនិកាយណាមួយ ហើយភាគច្រើននៃពួកគេក៏មិនមែនជាទស្សនវិទូដែរ។ ក្នុងចំណោមពួកសូហ្វីសដែលល្បីល្បាញបំផុតមាន ប្រូតាហ្គោរ៉ាស(Protagoras) ហ្គ័រហ្សៀយ៉ាស (Gorgias) ត្រាស៊ីម៉ាជុស (Thrasymachus) ប្រូឌីគុស(Prodicus) ហ៊ីប្យាស (Hippias)។<br>ក្រោយពីជំនាន់ពួកសូហ្វីសខាងលើមក ពាក្យសូហ្វីសមានអត្ថន័យអវិជ្ជមានរហូតមកដល់បច្ចុប្បន្ន។ ការប្រែប្រួលដ៏ធំនេះបណ្តាលមកពីការឃោសនាជំទាស់របស់ប្លាតុង និងអារីស្តូត ដែលចោទពួកសូហ្វីសថាជាអ្នករកលុយពីការបង្រៀនរបស់ ពួកគេ និងយកតម្លៃខ្ពស់ក្នុងការបង្រៀនបច្ចេកទេសយកឈ្នះក្នុងការតស៊ូមតិ។ ពួកសូហ្វីសជាច្រើន ជាគោលដៅចំអកនៅក្នុងអត្ថបទសន្ទនារបស់ប្លាតុង ហើយ ក្រោយមកពួកសូហ្វីសត្រូវបានញែកចេញពីអ្នកប្រកបមុខវិជ្ជាខាងបញ្ញាដោយ ពិតប្រាកដ។ ប៉ុន្តែផ្តើមពីការខ្វះខាតខាងព័ត៌មានសម្រាប់ដំណើរការពួកសូហ្វីស ប្រៀបដូចជាអ្នករួមគ្នាបង្កើតចលនាសេរី ដែលបង្កជាភាពសង្ស័យក្នុងប្រពៃណី និងក្នុងចំណុចខ្លះនៃការបំភ្លឺ។ ពួកសូហ្វីសបានរួមវិភាគទានដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រនៃការគិតក្នុងជំនាញវេយ្យាករណ៍ និងទ្រឹស្តីភាសាវិទ្យាសីលធម៌ និងទ្រឹស្តីនយោបាយ ទ្រឹស្តីអំពីធម្មជាតិនិងប្រភពរបស់មនុស្ស និងសង្គម។ ដោយគ្មានសំណេររបស់សូហ្វីសណាម្នាក់នៅសល់ ដូច្នេះវាជាការលំបាកក្នុងការកែតម្រូវបុរេនិច្ឆ័យពីមុនដែលប្រឆាំងនឹងពួកសូហ្វីស។<br>(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាក្រិកបុរាណសម័យ។) |
| **៨៧- សួគ៌**<br>អ. heaven<br>បារ. ciel (m.) | លោកឬភពនៃសន្តិនិងសុភមង្គលដ៏ឧត្តមដែលគេជឿថា បុគ្គលល្អនឹងបានទៅកើតនៅក្រោយពេលគេស្លាប់ទៅ។ អារីស្តូតឱ្យនិយមន័យពាក្យ«សួគ៌»បីយ៉ាងផ្សេងៗគ្នា ៖<br>១- មណ្ឌលដែលស្ថិតនៅចុងបំផុតនៃចក្រវាល<br>២- មេឃឬសួគ៌តាមន័យទូទៅ<br>៣- ចក្រវាលទាំងមូលដែលជាសទិសន័យនឹងលោកធាតុ។<br>នៅក្នុងប្រពៃណីគ្រិស្តសាសនា សួគ៌គឺជាកន្លែងបម្រុងទុកសម្រាប់មនុស្សបាបដែលព្រះបានសង្គ្រោះក្រោយពេលស្លាប់។ តាមន័យនេះ សួគ៌ជាភពដែលអាទិទេព និងអស់ទេវតាស្ថិតនៅ។ |
| **៨៨- សេរីនិយមក្លាស៊ិក/ សេរីនិយមបែបបុរាណ**<br>អ. classic liberalism<br>បារ. libéralisme classique | មនោគមវិជ្ជានយោបាយម្យ៉ាង និងជាមែកធាងមួយនៃសេរីនិយម ដែលគាំទ្រសេរីភាពពលរដ្ឋនៅក្រោមនីតិរដ្ឋនិងផ្តោតលើសេរីភាពខាងសេដ្ឋកិច្ច។ សេរីនិយមក្លាស៊ិកទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងសេរីនិយមនិងសេរីនិយមខាងសេដ្ឋកិច្ច។ នៅដើមសតវត្សរ៍ទី១៩សេរីនិយមក្លាស៊ិកត្រូវបានអភិវឌ្ឍដោយឈរលើគំនិតរបស់ទស្សនវិទូនៃសតវត្សរ៍មុនៗជាការឆ្លើយតបទៅនឹងនគរូបនីយកម្ម និង |

| | |
|---|---|
| | បដិវត្តន៍ឧស្សាហកម្មនៅអឺរ៉ុបនិងសហរដ្ឋអាម៉េរិក។ បុគ្គលល្បីល្បាញដែលគំនិតរបស់ពួកគាត់បានរួមចំណែកនៅក្នុងសេរីនិយមក្លាសិក រួមមាន ចន ឡុក (John Locke) តូម៉ាស ជេហ្វ័រសាន់ (Thomas Jefferson) ហ្សង់ បាបទីស្ត-សាយ(Jean-Baptiste Say) តូម៉ាស ម៉ាល់ថឹស(Thomas Malthus) និង ដេវីដ រីកាដូ (David Ricardo)។ សេរីនិយមក្លាសិកត្រូវបានដកស្រង់ចេញពីទ្រឹស្តីសេដ្ឋកិច្ច (Economics) របស់ អាដាម ស្មីត(Adam Smith) ជំនឿ លើច្បាប់ធម្មជាតិ(Natural law) ទ្រឹស្តីផលប្រយោជន៍និយម(Utilitarianism) និង ភាពរីកចម្រើន (Progress)។ |
| **៨៩- សេរីភាពវិជ្ជមាន**<br>អ. positive freedom<br>បារ. liberté positive | លទ្ធភាពដែលអាចធ្វើឱ្យនរណាម្នាក់ក្លាយជាម្ចាស់ក្នុងការកំណត់អំពីជីវិត និង សកម្មភាពផ្ទាល់ខ្លួន។ សេរីភាពវិជ្ជមាននេះ គឺជាសេរីភាពបែបសង្គម ដែលមានព្រំដែនជាក់លាក់នៅក្នុងជំនឿ ទំនៀមទម្លាប់ ប្រពៃណី សីលធម៌ ច្បាប់រដ្ឋ និង កំណត់ដោយសមត្ថភាព ធនធាន និង ឱកាសរបស់មនុស្សម្នាក់ៗ។<br>(ពាក្យនេះ គេប្រើនៅក្នុងសីលវិជ្ជានិងទស្សនវិជ្ជានយោបាយ) |
| **៩០- ហឋយោគ**<br>អ. hatha-yoga<br>បារ. hatha-yoga | ផ្នែកមួយនៃប្រព័ន្ធទស្សនវិជ្ជាយោគៈដែលជាការហ្វឹកហាត់និងលត់ដំរាងកាយ និង ចិត្តឱ្យមានតុល្យភាព ដោយប្រើវិធីផ្សេងៗ ដូចជា ការធ្វើសមាធិ ការហាត់-ប្រាណ ជាដើម ហើយដែលមានកម្រិតស្រាលជាងប្រព័ន្ធវិធីយោគៈផ្សេងៗទៀត។ |
| **៩១- ឯកអគ្គទេវនិយម**<br>អ. henotheism<br>បារ. hénothéisme (m.) | បច្ចេកសព្ទរបស់ ម៉ាក មូល័រ (Max Müller) សំដៅដល់លទ្ធិមួយដែលអនុញ្ញាតឱ្យមានអត្ថិភាពអាទិទេពច្រើន ប៉ុន្តែលទ្ធិនេះបានអះអាងថា មានអាទិទេពតែមួយអង្គគត់ដែលជាអ្នកដឹកនាំកំពូលរបស់ពួកអាទិទេពទាំងនោះ ហើយអាទិទេពអង្គនោះសក្តិសមនឹងទទួលបានភាពស្មោះត្រង់ ការគោរព និងការស្តាប់បង្គាប់ពីអាទិទេពទាំងឡាយ។ ឯកអគ្គទេវនិយម ជាការសម្រុះសម្រួលរវាងពហុទេវ-និយមដែលជឿថា មានអាទិទេពច្រើន និង ឯកទេវនិយមដែលជឿថាអាទិទេពមានតែមួយអង្គគត់។ ទស្សនវិទូសាសនាខ្លះ ចាត់ទុកឯកអគ្គទេវនិយមជាដំណាក់កាលកណ្តាលក្នុងការអភិវឌ្ឍពីពហុទេវនិយមទៅជាឯកទេវនិយម។ តាម តាលីហ្វេរ៉ូ (Taliaferro) «ឯកអគ្គទេវនិយម គឺជាការទទួលស្គាល់អាទិទេពតែមួយសម្រាប់គោលបំណងឧទ្ទិសនិងបូជា ដោយមិនបដិសេធនូវអត្ថិភាពនៃអធិភាវៈដទៃទៀតទេ»។<br>(ពាក្យនេះ គេប្រើនៅទស្សនវិជ្ជាអំពីសាសនា) |
| **៩២- អញ្ញទិដ្ឋិ**<br>អ. heresy<br>បារ. hérésie (f.) | ទស្សនៈ ជំនឿ ឬដំណើរយល់ឃើញផ្ទាល់ខ្លួន ដែលផ្ទុយឬប្រឆាំងទៅនឹងគោលការណ៍ឬទស្សនៈរបស់សាសនាផ្លូវការឬពេញនិយមណាមួយ។ នៅបុរាណ-សម័យនិកាយណាក៏ដោយ ដូចជា និកាយប៉េរីប៉ាតេទិកនិយម (Peripatetics) អាកាដេមិកនិយម(Academics)ពួកអេពីគួនិយម(Epicureans)ឬពួកអត់ធ្មត់និយម(Stoics) ត្រូវបានចាត់ទុកថាជាអញ្ញទិដ្ឋិ។ អញ្ញទិដ្ឋិកជន សំដៅលើ |

| | |
|---|---|
| | មនុស្សណាម្នាក់ឬក្រុមណាមួយដែលបង្រៀនតាមទស្សនៈផ្ទាល់ខ្លួន។ ដំបូងឡើយ អញ្ញទិដ្ឋិមិនមែនជាបច្ចេកសព្ទក្នុងន័យអវិជ្ជមាននោះទេ សូម្បីតែគ្រិស្តសាសនាក៏គិតថា ខ្លួនឯងជាអញ្ញទិដ្ឋិដែរ។ ប៉ុន្តែចាប់ពីពេលដែលគ្រិស្តសាសនាបានទទួលអំណាចលើសលប់ជាងគេក្នុងមជ្ឈិមសម័យ សាសនានេះបានប្រើពាក្យអញ្ញទិដ្ឋិសំដៅលើទស្សនៈណាមួយ ដែលមិនស្របតាមការបង្រៀនរបស់គ្រិស្តសាសនានិកាយអ័រតូដុក ឬនិកាយណាមួយដែលធ្វើការបកស្រាយគម្ពីរប៊ីប(Bible)ខុសពីការបកស្រាយផ្លូវការនៃសហគមន៍គ្រិស្តសាសនា។ លក្ខណៈប្រហាក់ប្រហែលនឹងអញ្ញទិដ្ឋិ គឺការបដិសេធ ការច្រានចោលគំនិត ឬទ្រឹស្តីណាមួយ ដែលខុសពីគំនិតរបស់ខ្លួន។ អញ្ញទិដ្ឋិកើតឡើងនៅក្នុងវិស័យអាណាចក្រ ជាពិសេសនៅទីណាដែលការប្រើអាជ្ញាសំខាន់ជាងការប្រើវិចារណញ្ញាណនៅក្នុងការដោះស្រាយទំនាស់ខាងទ្រឹស្តី។<br>(បញ្ញត្តិនេះ គេប្រើនៅក្នុងទស្សនវិជ្ជាអំពីសាសនា) |
| **៩៣- អដ្ឋង្គិកមគ្គ**<br>អ. eightfold path<br>បារ. octuple sentier | ផ្លូវដែលប្រកបដោយអង្គប្រាំបីដែលជាមជ្ឈិមាបដិបទា (ផ្លូវកណ្តាល) បានដល់សីល សមាធិ បញ្ញា ជាផ្លូវប្រតិបត្តិដើម្បីរំដោះខ្លួនឱ្យចេញផុតពីសេចក្តីទុក្ខ។ អង្គរបស់អដ្ឋង្គិកមគ្គទាំង៨មាន៖ ១- សម្មាទិដ្ឋិ គំនិតយល់ឃើញត្រូវ គឺគំនិត យល់ឃើញថា ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប ជាដើម។ សមាទិដ្ឋិនេះទៀតសោត គឺសំដៅយកបញ្ញាយល់ឃើញប្រពៃ គឺឃើញនូវអរិយសច្ចទាំងបួនមានទុក្ខសច្ច សមុទយសច្ច និរោធសច្ច និងមគ្គសច្ច។ ២- សម្មាសង្កប្បោ ត្រិះរិះត្រូវ គឺត្រិះរិះចេញចាកកាម ត្រិះរិះដល់ការមិនព្យាបាទ ហៅថាអព្យាបាទ និងការត្រិះរិះមិនជាហេតុបៀបបៀនអ្នកដទៃ(អវិហិង្សា)។ ៣- សម្មាវាចា សម្តីនិយាយត្រូវបានដល់វាចាវៀរចាកវចីទុច្ចរិត៤។ ៤- សម្មាកម្មន្តោ ការងារត្រូវបានដល់ការងារដែលវៀរចាកនូវទុច្ចរិតទាំង៣ ឬការងារទាំងឡាយណាដែលមិនមានទោស ហើយផ្តល់ប្រយោជន៍ដល់ខ្លួននិងសង្គម។ ៥- សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ បើគ្រហស្ថបានដល់ការលះបង់នូវជំនួញខុសទាំង៥(មិច្ឆាជីវ) បើបព្វជិតបានដល់ការលះបង់នូវបាបធម៌៥ និងអនេសនៈ២១ ជាដើម។ ៦- សម្មាវាយាមោ ការព្យាយាមត្រូវបានដល់ការព្យាយាមក្នុងស្ថានទាំង៤ មានកម្ចាត់បង់នូវអំពើអាក្រក់ និងព្យាយាមធ្វើអំពើល្អ។ ៧- សម្មាសតិ រឭកប្រពៃ គឺរឭកក្នុងសតិប្បដ្ឋាន៤។ ៨- សម្មាសមាធិ តាំងចិត្តខ្ជាប់ប្រពៃ គឺចម្រើនក្នុងឈាន៤។ អដ្ឋង្គិកមគ្គមិនមែនជាការអភិវឌ្ឍត្រង់ភ្លឹងដូចបន្ទាត់នោះទេ ប៉ុន្តែជាការបំបែកជាតុខុសៗគ្នា ដែលគេត្រូវការដើម្បីឱ្យជីវិតរស់រួចផុតពីសេចក្តីទុក្ខបាន។ អដ្ឋង្គិកមគ្គ ឬហៅម្យ៉ាងទៀតថា មជ្ឈិមប្បដិបទា(ផ្លូវកណ្តាល)ក៏បាន។ ឧទាហរណ៍<br>ព្រះសង្ឃទូន្មានឱ្យពុទ្ធបរិស័ទយកអដ្ឋង្គិកមគ្គធ្វើជាមាគ៌ាជីវិត។ |

| | |
|---|---|
| **៩៤- អត្តនោមតិភាព/ ប្រធានវិស័យភាព**<br>អ. subjectivity<br>បារ. subjectivité (f.) | អត្ថិភាពនៃអ្វីមួយដោយផ្អែកលើទស្សនៈឬអារម្មណ៍របស់បុគ្គលជាជាងផ្អែកលើហេតុការណ៍ខាងក្រៅឬកស្តុតាង។ ឧទាហរណ៍ ការយល់ថា ព្រះអាទិត្យរះនៅទិសខាងកើតនិងលិចនៅទិសខាងលិច គឺជាអត្តនោមតិភាពរបស់មនុស្ស។ |
| **៩៥- អត្តស្នេហានិយម**<br>អ. narcissism/ narcisism<br>បារ. narcissisme (m.) | ការជក់ចិត្តនឹងខ្លួនឯងហួសប្រមាណ ការស្រឡាញ់ខ្លួនឯងហួសហេតុ មោទនភាពជ្រុលចំពោះខ្លួនឯង។ ពាក្យនេះមានប្រភពមកពីទេវកថាក្រិក រឿងណាគីសូស (narkissos) ឬណាស៊ីស៊ូស(Narcissus)។ |
| **៩៦- អនន្តភាព**<br>អ. eternity<br>បារ. éternité (f.) | លក្ខណៈមួយក្នុងចំណោមលក្ខណៈផ្សេងៗរបស់អាទិទេព ដែលត្រូវបានគេបកស្រាយបានតាមរបៀបពីរយ៉ាងខុសគ្នា។ របៀបទី១ អាទិទេព គឺជា អនន្តដោយសារតែអាទិទេពមិនចងដោយពេលវេលា។ អត្ថិភាពរបស់អាទិទេពនៅក្រៅពេលវេលាឬមិនចំណុះពេលវេលា, អាទិទេពគ្មានពេលកំណត់ ប៉ុន្តែអាទិទេពជាអ្នកបង្កើតពេល។ ដោយសារតែអាទិទេពមិននៅក្នុងពេលវេលា រាល់ព្រឹត្តិការណ៍ដែលកើតឡើងក្នុងពេល ចំពោះទ្រង់គឺកើតឡើងដំណាលគ្នា។ ខណៈ «ឥឡូវ»របស់យើងសម្គាល់ពេលវេលានិងវត្តអត្ថិភាពក្នុងពេល ប្រែប្រួល រីឯ «ឥឡូវ»របស់អាទិទេព ឋិតថេរមិនប្រែប្រួលនិងមិនអាចធ្វើឱ្យប្រែប្រួល។ របៀបទី២ អាទិទេពមានលោកិយភាព ពេលគឺមានអតីតកាល បច្ចុប្បន្នកាល និង អនាគតកាល ប៉ុន្តែព្រះអង្គជាអនន្តភាពពីព្រោះអាទិទេពតែងតែមានអត្ថិភាពនៅក្នុងអតីតកាល មានអត្ថិភាពនៅក្នុងបច្ចុប្បន្នកាល និងតែងតែមានអត្ថិភាពនៅក្នុងអនាគតកាល។ អនន្តភាព ស្មើនឹងចំនួនសរុបនៃកាលទាំងបី (អតីតកាល បច្ចុប្បន្នកាល និងអនាគតកាល)។<br>(ពាក្យនេះ គេប្រើនៅក្នុងអស្តិរូបវិជ្ជា និងទស្សនវិជ្ជាអំពីសាសនា) |
| **៩៧- អនុមាន**<br>អ. inference<br>បារ. inférence (f.) | វិធីនៃការទាញសេចក្តីសន្និដ្ឋានដែលមានតម្លៃខាងតក្កវិជ្ជា ពិតឬមិនពិតចេញពីសេចក្តីថ្លែង/អំណះអំណាងមួយឬច្រើន។ ជាទូទៅ អនុមានចែកចេញជាអនុមានរួម(Induction) និងអនុមានញែក(Deduction)។ ក្នុងករណីខ្លះគេរាប់បញ្ចូលវិសេសានុមាន(Abduction) ជាប្រភេទទីបីនៃអនុមានដែរ ប៉ុន្តែជាញឹកញាប់គេចាត់ទុកវាថាជាករណីវិសេសនៃអនុមានរួម។<br>(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា) |
| **៩៨- អនុមានញែក**<br>អ. deduction<br>បារ. déduction (f.) | វិធីនៃការពិចារណា ដែលទាញសេចក្តីសន្និដ្ឋានពីសច្ចភាពសាកលទៅរកសច្ចភាពដោយឡែកៗ ដោយផ្អែកលើតក្កសាស្ត្រ។ សេចក្តីសន្និដ្ឋានរបស់អនុមានញែក មានសភាពពិតដាច់ខាត។ ឧទាហរណ៍៖ - មនុស្សទាំងអស់ជាយថាហេតុនឹងស្លាប់។ - សុខ ជាមនុស្ស។ ដូច្នេះ សុខ ជាយថាហេតុនឹងស្លាប់ដែរ។ (ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា) |

| | |
|---|---|
| **៩៩- អនុមានរួម**<br>អ. induction<br>បារ. induction (f.) | វិធីនៃការពិចារណាដែលទាញសេចក្តីសន្និដ្ឋានចេញពីសច្ចភាព ឬករណីដោយឡែកៗទៅរកសច្ចភាពសាកល ឬការធ្វើទូទៅនីយកម្មលើមូលដ្ឋាននៃសច្ចភាពឬក៏ករណីដោយឡែកៗមួយចំនួនផ្អែកលើតក្កសាស្ត្រ។ សេចក្តីសន្និដ្ឋានរបស់អនុមានរួម ជាទូទៅមានសភាពប្រហែលជាជាងសភាពពិតជាច់ខាត។ ឧទាហរណ៍១ ៖<br>-ដែកចម្លងអគ្គិសនី ទង់ដែងចម្លងអគ្គិសនី ប្រាក់ចម្លងអគ្គិសនី។<br>- ដែក ទង់ដែង ប្រាក់ ជាលោហៈ។ ដូច្នេះ លោហៈទាំងអស់ចម្លងអគ្គិសនី។<br>ឧទាហរណ៍ទី២ ៖<br>- ជនជាតិព្នងមានជំនឿលើព្រលឹងដូនតា ជនជាតិកួយ មានជំនឿលើព្រលឹងដូនតា ជនជាតិគ្រឹងមាន ជំនឿលើព្រលឹងដូនតា។<br>- ជនជាតិកួយ ជនជាតិព្នង ជនជាតិគ្រឹង...ជា ជនជាតិដើម។ ដូច្នេះ ជនជាតិដើមទាំងអស់មានជំនឿលើព្រលឹង ដូនតា។<br>(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា) |
| **១០០- អន្តរកម្មនិយម**<br>អ. interactionism<br>បារ. interactionnisme (m.) | ទស្សនៈរបស់ពួកទ្វិកនិយមដែលអះអាងថា ថ្វីបើចិត្តនិងកាយជាសារជាតុពីរដាច់ដោយឡែកពីគ្នាក៏ដោយ ក៏វាជះឥទ្ធិពលលើគ្នាទៅវិញទៅមកតាមទំនាក់ទំនងហេតុផល។ ចិត្តនិងកាយជាធាតុពីរឯករាជ្យពីគ្នា ប៉ុន្តែនៅក្នុងជីវិតទាំងមូលកាយនិងចិត្តមានអន្តរកម្មជាមួយគ្នា។<br>(ពាក្យនេះ គេប្រើក្នុងអស្តិរូបវិជ្ជា និងទស្សនវិជ្ជាអំពីចិត្ត) |
| **១០១- អភិប្រាយវិជ្ជា**<br>អ. hermeneutics<br>បារ. herméneutiques (f.) | ការសិក្សាអំពីទ្រឹស្តីនិងវិធីសាស្ត្រដែលនិយាយពីការបកស្រាយនិងការយល់ដឹងអំពីអត្ថបទ។ អភិប្រាយវិជ្ជាចែកចេញជាពីរគឺ ទីមួយជាវិទ្យាសាស្ត្រ និងវិធីសាស្ត្រស្តីពីការបកស្រាយបែបវិទ្យាសាស្ត្រនូវអត្ថបទនានាតាមរយៈសំណេរ ជាពិសេសគម្ពីរសាសនា គតិបណ្ឌិតនៅក្នុងអក្សរសាស្ត្រ អត្ថបទទស្សនវិជ្ជា ជាដើម។ ទីពីរជាទេវវិជ្ជាស្តីពីបញ្ញត្តិសាសនាដែលជាមែកជាងនៃទេវវិជ្ជា ហើយ ដែលទាក់ទងនឹងការពន្យល់ឬការបកស្រាយតាមរយៈពាក្យសម្តីនូវបញ្ញត្តិ ទ្រឹស្តី និងគោលការណ៍ខាងសាសនា និងទស្សនវិជ្ជា។ |
| **១០២- ឥរិយាបថនិយម**<br>អ. behaviorism<br>បារ. behaviorisme (m.) | ទ្រឹស្តីដែលអះអាងថា ឥរិយាបថមនុស្សនិងសត្វ អាចត្រូវបានបកស្រាយក្នុងលក្ខខណ្ឌមួយដោយមិនគិតអំពីគំនិតឬអារម្មណ៍ និងអះអាងថា ចិត្តវិបល្លាស (psychological disorders) គេអាចព្យាបាលបានតាមរយៈការផ្លាស់ប្តូរគំរូឥរិយាបថផ្សេងៗ។ ក្នុងន័យទូលាយ ឥរិយាបថនិយម គឺជាទស្សនៈដែលយល់ថា ឥរិយាបថ គឺជាមូលដ្ឋានក្នុងការយល់ដឹងអំពីបាតុភូតចិត្ត។<br>(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាអំពីចិត្ត) |

| | |
|---|---|
| **១០៣- ឥរិយាបថស្ថាប័ន**<br>អ. organizational behavior<br>បារ. comportement organisationnel | វិស័យមួយនៃការសិក្សាដោយអង្កេតលើផលប៉ះពាល់ដែលកើតចេញពីឥរិយាបថរបស់បុគ្គលម្នាក់ៗ ក្រុមនីមួយៗ និងរចនាសម្ព័ន្ធនានានៅក្នុងស្ថាប័នមួយ។ វិស័យនៃការសិក្សានេះជាប់ពាក់ព័ន្ធជាមួយមុខវិជ្ជាជាច្រើន រួមមាន សង្គមវិទ្យា ចិត្តវិទ្យា ទំនាក់ទំនង ការគ្រប់គ្រង ទ្រឹស្តីស្ថាប័ន និង ធនធានមនុស្សវិទ្យា។ លើសពីនេះទៀត វាក៏អាចសំដៅទៅរកស្ថាប័នវិទ្យា ឬវិទ្យាសាស្ត្រស្ថាប័ន ទៀតផង។ ឥរិយាបថស្ថាប័នមានឫសគល់នៅក្នុងចិត្តវិទ្យាឧស្សាហកម្ម និងចិត្តវិទ្យាស្ថាប័ន។ |
| **១០៤- អវិជ្ជា**<br>អ. avijjā (ignorance)<br>បារ. avijjā (ignorance) (f.) | ក្នុងន័យទូទៅ អវិជ្ជាមានន័យថា ការមិនដឹងច្បាស់ សេចក្តីល្ងង់ មោហៈ។ នៅក្នុងព្រះពុទ្ធសាសនា អវិជ្ជា(avijja) មានន័យថា ការមិនដឹង ឬមិនយល់ពីធម្មជាតិពិតនៃជីវិតរបស់យើងនិង/ឬធម្មជាតិពិតរបស់វត្ថុ។ អវិជ្ជា នៅក្នុងទ្រឹស្តីបដិច្ចសមុប្បាទ(Dependent Origination)គឺអវិជ្ជាអំពីអរិយសច្ចទាំង៤ មានន័យថា ៖<br>១-មិនយល់ពីសេចក្តីទុក្ខ(ទុក្ខអរិយសច្ច)<br>២-មិនយល់ពីប្រភពនៃទុក្ខ (ទុក្ខសមុទយអរិយសច្ច)<br>៣-មិនយល់ពីសេចក្តីរំលត់ទុក្ខ(ទុក្ខនិរោធ អរិយសច្ច) និង<br>៤-មិនយល់ពីមាគ៌ាដែលដឹកនាំទៅរកការរំលត់ទុក្ខ(មគ្គអរិយសច្ច)។ អវិជ្ជានេះនាំឱ្យមនុស្សធ្វើអំពើអកុសល ឬអំពើបាបជាច្រើនរាប់មិនអស់។ ហេតុនេះ ការយល់ដឹងពីអរិយសច្ចទាំង៤ ពិតជាមានសារៈសំខាន់ក្រៃលែងដោយសារតែមនុស្សម្នាក់ៗខកខានមិនបានយល់ពីអរិយសច្ចទាំង៤នេះហើយ ទើបបានជាពួកគេត្រូវវិលវល់នៅក្នុងគំនិតជាប់ជំពាក់មិនចេះចប់និងវិលវល់ក្នុងវដ្តសង្សារ។ |
| **១០៥- អសារនិយម**<br>អ. nihilism<br>បារ. nihilisme (m.) | ១- ទស្សនៈដែលយល់ថា ជំនឿនិងតម្លៃជាប្រពៃណីគ្មានហេតុផល និងថាអត្ថិភាពគ្មានន័យនិងគ្មានប្រយោជន៍។<br>២- ទស្សនៈដែលបដិសេធនូវមូលដ្ឋានសត្យានុម័តិនានានៃសច្ចភាពជាពិសេស សច្ចភាពខាងសីលធម៌។<br>៣- ទស្សនៈ ដែលជឿថា គ្រប់អង្គការសាសនានិងនយោបាយអាក្រក់ណាស់ ឬជាប្រព័ន្ធគំនិតមួយដែលថាគ្មានគោលការណ៍ឬជំនឿណាដែលមានន័យ ឬអាចជាការណ៍ពិតបានទេ។ ឧទាហរណ៍ ពួកអសារនិយមខាងសីលធម៌ យល់ថាសីលធម៌គ្មានអត្ថិភាពពីធម្មជាតិទេ។ |
| **១០៦- អសុទ្ធចិត្ត**<br>អ. bad faith<br>បារ. mauvaise foi | លក្ខខណ្ឌមួយដែលមនុស្សម្នាក់បង្វែរការយល់ឃើញរបស់នរណាម្នាក់ទៀតចេញពីការណ៍ពិត ឬអំណាចជ្រើសរើសនិងជម្រើសនានាក្នុងកម្រិតណាមួយដែលគេដឹងថាវាមាន។ លក្ខខណ្ឌនេះកត់សម្គាល់ដោយ ហ្សង់ ប៉ូល សាត្រ (Jean-Paul Sartre)។ |

| | |
|---|---|
| **១០៧- អស្តិទស្សនវិជ្ជា**<br>អ. metaphilosophy<br>បារ. métaphilosophie (f.) | ទស្សនវិជ្ជាដែលសិក្សាអំពីទស្សនវិជ្ជាខ្លួនឯង ពោលគឺ សិក្សាពីធម្មជាតិ វិធី គោលបំណង ស្វ័យភាព សត្យានុម័តភាព និងសំណួររបស់ទស្សនវិជ្ជា ព្រមទាំង ទំនាក់ទំនងរវាងទស្សនវិជ្ជានិងមុខវិជ្ជាដទៃទៀត។ អស្តិទស្សនវិជ្ជា ជាបច្ចេកសព្ទ មួយបង្ហាញដោយទស្សនវិទូ ឡាសេរ៉ូវីត (Lazerowitz ១៩០៧-១៩៨៧) ជន ជាតិប៉ូឡូញ សញ្ជាតិអាម៉េរិក។ |
| **១០៨- អាជ្ញា**<br>អ. authority<br>បារ. autorité (f.) | សិទ្ធិអំណាច ដែលកាន់កាប់ដោយមនុស្សម្នាក់ ស្ថាប័នមួយ ឬរដ្ឋមួយដើម្បី ចេញបញ្ជាឱ្យគោរព។ សិទ្ធិនេះបញ្ជាក់ពីកាតព្វកិច្ចមួយ ដែលអ្នកនៅក្រោម បង្គាប់នៃអាជ្ញានេះត្រូវតែគោរពនិងអនុវត្តតាម។ អាជ្ញា គឺជាប្រភេទមួយនៃ អំណាច ប៉ុន្តែអំណាចទាំងអស់មិនមែនសុទ្ធ តែជាអាជ្ញាទេ។ ប្រភេទអំណាច មួយចំនួនគ្រាន់តែជាកម្លាំងបង្ខិតបង្ខំ ហើយវាមិនមានធម្មានុរូបភាពទេ។ អាជ្ញា អាចគ្រប់គ្រងតែតំបន់និងមនុស្សមួយចំនួន ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ច របស់ខ្លួន ប៉ុន្តែមិនមែនគ្រប់គ្រងតំបន់និងមនុស្សផ្សេងទៀត ដែលស្ថិតនៅក្រៅ ដែនសមត្ថកិច្ចរបស់ខ្លួនទេ។ វិសាលភាពនិងព្រំដែននៃអាជ្ញារបស់រដ្ឋទាមទារ ឱ្យមានការពន្យល់។<br>(ពាក្យនេះ គេប្រើក្នុងទស្សនវិជ្ជានយោបាយ និងទស្សនវិជ្ជាអំពីច្បាប់) |
| **១០៩- អាជ្ញានិយម**<br>អ. authoritarianism<br>បារ. autoritarisme (m.) | ទស្សនៈនយោបាយមួយដែលយល់ថា ប្រជាពលរដ្ឋត្រូវតែគោរពអាជ្ញាធរជា ដាច់ខាត ដោយមិនអនុញ្ញាតឱ្យសួរដេញដោលឡើយ។ ក្នុងការប្រតិបត្តិ នៅក្នុង ប្រព័ន្ធនយោបាយផ្តាច់ការមួយរដ្ឋាភិបាលមានអំណាចឥតព្រំដែន និងខ្វះការបង្គាប់ បញ្ជាត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ។ អាជ្ញាធរអាចសម្រេចចិត្តដោយមិនចាំបាច់ ពិគ្រោះយោបល់ ឬចរចាជាមួយអ្នកដែលទទួលផលប៉ះពាល់ពីការអនុវត្តសេចក្តី សម្រេចចិត្តនោះឡើយ។ សង្គមបែបនេះត្រូវបានគ្រប់គ្រង ដោយមនុស្សម្នាក់ ឬ មនុស្សមួយក្រុមជាជាងដោយច្បាប់។<br>(ពាក្យនេះ គេប្រើក្នុងទស្សនវិជ្ជានយោបាយ។) |

## ៣- បច្ចេកសព្ទស្នើដោយគណៈកម្មការសុខាភិបាល

| | |
|---|---|
| **១- កង្វាក់/អាម៉ូរ៉ូស**<br>អ. amaurosis<br>បារ. amaurose (f.) | អាការៈងងឹតមើលមិនឃើញរបស់ភ្នែក តែរចនាសម្ព័ន្ធគ្រាប់ភ្នែកនៅធម្មតា។ |
| **២- កន្លារពេទ្យ/បាសាំងពេទ្យ**<br>អ. bedpan<br>បារ. bassin de lit | បរិក្ខារវេជ្ជសាស្ត្រជាកន្លោរមានទ្រង់ទ្រាយសំប៉ែតសម្រាប់ឱ្យអ្នកជំងឺបន្ទោបង់នៅលើគ្រែ។ |
| **៣- កម្រិនអាកទែ/**<br>**អាកទែរីយ៉ូសក្លេរ៉ូស**<br>អ. arteriosclerosis<br>បារ. artériosclérose (f.) | ១- អាការៈក្រាស់រឹងនិងបាត់ភាពយឺត(élasticité)នៃអាកទែ ដែលបង្កឡើងដោយអត្រាកាល់ស្យូមឡើងខ្ពស់ក្នុងចរន្តឈាម ដែលភាគច្រើនកើតឡើងចំពោះមនុស្សវ័យចំណាស់។<br>២- អាការៈក្រាស់រឹងនៃផ្នែកណាមួយឬច្រើននៃអាកទែ ដែលបង្កឡើងដោយកំណកសារជាតុខ្លាញ់អាតេរ៉ូមស្ថិតនៅក្នុងអាកទែរយៈពេលយូរ ដែលបង្កឱ្យទៅជាអាតេរ៉ូសក្លេរ៉ូស(athérosclérose)។ |
| **៤- កាយវិភាគវិទ្យា/អាណាតូមី**<br>អ. anatomy<br>បារ. anatomie (f.) | វិទ្យាសាស្ត្រសិក្សាអំពីរចនាសម្ព័ន្ធនៃសរីរាង្គមនុស្សនិងសត្វ។ |
| **៥- ការកន្ទេក/អាប់ដុកម្ម**<br>អ. abduction<br>បារ. abduction (f.) | ចលនាសរីរាង្គដែលទាញចេញទៅខាងក្រៅខុសពីទម្រង់ដើម។ |
| **៦- ការត្រាំ**<br>អ. balneation<br>បារ. balnéation (f.) | វិធីពន្លិចសព៌ាង្គកាយមួយផ្នែក ឬទាំងមូលក្នុងទឹក ឬក្នុងសូលុយស្យុងផ្សេងៗក្នុងគោលបំណងព្យាបាល។ |
| **៧- ការត្រាំព្យាបាល**<br>អ. balneotherapy<br>បារ. balnéothérapie (f.) | វិធីព្យាបាលជំងឺដោយការត្រាំ។ |
| **៨- ការមានរដូវ**<br>អ. menorrhea<br>បារ. ménorrhée (f.) | ការហូរឈាមនិងសារជាតុផ្សេងៗពីក្នុងស្បូនរបស់ស្ត្រីនៅពេលមានរដូវ។ |

| | |
|---|---|
| **៩- ការរុំបង់**<br>អ. bandage<br>បារ. bandage ( m. ) | វិធីរុំរបួសឬដំបៅដោយប្រើបង់រុំដើម្បីទប់ឱ្យនឹងឬទប់លំហូរឈាម។ |
| **១០- ការរួបចូល/អាត់ឌុកម្ម**<br>អ. adduction<br>បារ. adduction ( f. ) | ចលនាសរីរាង្គដែលទាញពីក្រៅចូលក្នុងខុសពីទម្រង់ដើម។ |
| **១១-ការលាងរបួស/ អាប់ស្ទែស្យុង**<br>អ. abstersion<br>បារ. abstersion ( f. ) | ការសម្អាតរបួសដោយប្រើឱសថលាងរបួស( abstergent )។ |
| **១២- ការស្ងាប**<br>អ. yawning<br>បារ. bâillement ( m. ) | ការហាមាត់ដោយអចេតនាដកដង្ហើមចូលយ៉ាងខ្លាំងនិងបញ្ចេញខ្យល់បន្តិចម្តងៗមកវិញ។ សកម្មភាពនេះកើតមាននៅពេលអស់កម្លាំង ងងុយដេក ឬធុញថប់។ |
| **១៣- កោសិកាវិទ្យា**<br>អ. cytology<br>បារ. cytologie ( f. ) | វិទ្យាសាស្ត្រសិក្សាពីកោសិកា( cellules )គ្រប់ប្រភេទ។ |
| **១៤- ក្បាលបូស/គ្រាប់បូស**<br>អ. core of boil<br>បារ. bourbillon ( m. ) | ដុំសរសៃៗពណ៌សនៅក្នុងបូសដែលកើតឡើងដោយសារការប្រមូលផ្តុំនៃដាលិកាស្បែកងាប់។ |
| **១៥- ក្រិនសាច់ដុំ**<br>អ. myosclerosis<br>បារ. myosclérose ( f. ) | អាការៈក្រិន ស្វិត និងរួញតូចខុសប្រក្រតីនៃសាច់ដុំ។ |
| **១៦- គំនាំងបេះដូង/ ប្លុកបេះដូង**<br>អ. heart block<br>បារ. bloc cardiaque | វិបត្តិនៃចង្វាក់បេះដូងរហូតដល់គាំងដោយសារដាច់រលករំញោច( onde d'excitation ) បញ្ហាសាច់ដុំបេះដូង បណ្តាលមកពីការប្រើប្រាស់ឱសថខុសសារធាតុពុល ...។ |
| **១៧- គំនាំងសន្លាក់/ អង់គីឡូស**<br>អ. ankylosis/( joint ) stiffness<br>បារ. ankylose ( f. ) | អាការៈគាំងសន្លាក់ពុំអាចធ្វើចលនាសកម្ម ឬ អកម្មបានបង្កដោយសាច់ដុំ ឬពួរសាច់ដុំនៃសន្លាក់នោះក្រិនរឹង ឬ ដោយមូលហេតុរលាករលួយសន្លាក់។ |

| | |
|---|---|
| **១៨- ចូល**<br>អ. afferent<br>បារ. afférent ( adj. ) | ដែលនាំសារធាតុអ្វីមួយចូលទៅក្នុងសរីរាង្គ។ |
| **១៩- ចេញ**<br>អ. efferent<br>បារ. efférent ( adj. ) | ដែលនាំសារធាតុអ្វីមួយចេញពីសរីរាង្គទៅក្រៅ។ |
| **២០- ជាលិកាវិទ្យា**<br>អ. histology<br>បារ. histologie ( f. ) | វិទ្យាសាស្ត្រសិក្សាពីជាលិកា( tissus )គ្រប់ប្រភេទ។ |
| **២១- ជំងឺធូលីសួត/ ផ្នឺម៉ូកូនីញ៉ូស**<br>អ. pneumoconiosis<br>បារ. pneumoconiose ( f. ) | ជំងឺសួតរ៉ាំរ៉ៃម៉្យាងដែលបង្កដោយកំណកធូលី( ផង់ សារធាតុរ៉ែឬសារធាតុគីមី ... ) នៅក្នុងសួត តាមការដកដង្ហើមស្រូបចូលក្នុងរយៈពេលយូរ។ |
| **២២- ជំងឺផ្សិត/មីកូស**<br>អ. mycosis<br>បារ. mycose ( f ) | ជំងឺដែលបង្កឡើងដោយមេរោគជាពពួកផ្សិត( champignon )។ |
| **២៣- ជំងឺសាច់ដុំ**<br>អ. myopathy/myopathia<br>បារ. myopathie ( f. ) | ជំងឺគ្រប់ប្រភេទនៃប្រព័ន្ធសាច់ដុំ។ |
| **២៤- ជំនួយកម្លាំង/ អាណាឡិបស៊ី**<br>អ. analepsia /analepsis<br>បារ. analepsie ( f. ) | វិធីធ្វើឱ្យអ្នកជំងឺមានកម្លាំងពលំឡើងវិញក្រោយពេលជាសះស្បើយ។ |
| **២៥- ឈឺ**<br>អ. ache<br>បារ. mal ( m. ) | អាការៈមិនស្រួលនៃសរីរាង្គណាមួយ។ |
| **២៦- ដុំពកភ្នាស**<br>អ. epithelioma<br>បារ. épithéliome/ épithélioma ( m. ) | ដុំពកកាច( tumeur maligne ) កើតឡើងពីជាលិកាភ្នាស ( tissu d'épithélium ) មិនប្រក្រតីរបស់សរីរាង្គ ដែលជាមហារីក។ |

| | |
|---|---|
| **២៧- ដុំពកវិទ្យា/អុងកូវិទ្យា**<br>អ. oncology<br>បារ. oncologie ( f. ) | វិទ្យាសាស្ត្រសិក្សាពីដុំពក( tumeurs )នៃជាលិកា( tissus )ផ្សេងៗរបស់សរីរាង្គ។ |
| **២៨- ជំងឺជ្រុះរោម/ អាឡូប៉េស៊ី**<br>អ. alopecia<br>បារ. alopécie ( f. ) | អាការៈជ្រុះរោម សក់ ខ្លះៗឬអស់រលីងនៅផ្នែកណាមួយនៃសព៌ាង្គកាយ។ |
| **២៩- ជំងឺមានរដូវ**<br>អ. menstruation<br>បារ. menstruation ( f ) | ដំណើរហូរឈាមពីស្បូនរបស់ស្ត្រីមានរយៈពេលធម្មតាពី៣ទៅ៧ថ្ងៃ តាមវដ្តរដូវ ( cycle menstruel )។ |
| **៣០- តិរច្ឆានភាព/ បេស្យាលីតេ**<br>អ. bestiality<br>បារ. bestialité ( f. ) | ការរួមភេទរវាងមនុស្សជាមួយនឹងសត្វ។ |
| **៣១- តុល្យភាព**<br>អ. balance<br>បារ. balance ( f. ) | ស្ថានភាពលំនឹងរវាងធាតុនានានៅក្នុងភាវៈរស់ដូចជាលំនឹងអត្រាអេឡិចត្រូលីត ( électrolyte ) អាស៊ីដ-បាស( acide-base )។ |
| **៣២- តំណឹងចិត្ត/អង់ហ្គោស**<br>អ. anguish<br>បារ. angoisse ( f. ) | អាការៈទង្គឹះចិត្ត តានតឹងនិងថប់អារម្មណ៍ធ្ងន់ធ្ងរ ដែលប៉ះពាល់រហូតដល់ប្រព័ន្ធឈាមរត់ ប្រព័ន្ធផ្លូវដង្ហើម ...។ |
| **៣៣- ថង់**<br>អ. sac/bag<br>បារ. sac ( m. ) | បរិក្ខារវេជ្ជសាស្ត្រជាស្បោងម្យ៉ាងសម្រាប់ត្រងលំហូរសារធាតុរាវ ខ្ទុះ ឬ លាមក ដែលហូរចេញពីសព៌ាង្គកាយ។ |
| **៣៤- ថប់អារម្មណ៍**<br>អ. anxiety<br>បារ. anxiété ( f. ) | អាការៈតប់ប្រមល់ផ្លូវចិត្តរហូតដល់បេះដូងដើរញាប់និងបែកញើស។ |
| **៣៥- ថ្នាលវប្បកម្ម**<br>អ. culture medium<br>បារ. bouillon de culture | ប៊ូយ៉ុងសម្រាប់បណ្តុះនិងចិញ្ចឹមបាក់តេរី។ |

| | |
|---|---|
| ៣៦- ទឹកប្រមាត់<br>អ. bile<br>បារ. bile ( f. ) | វត្ថុរាវអាល់កាឡាំងពណ៌លឿងបៃតងមានរសជាតិល្វីងដែលបញ្ចេញដោយថ្លើម សម្រាប់បន្សាបអាស៊ីដក្នុងអាហារនៅដើមពោះវៀនតូច។ |
| ៣៧- បង់រុំ<br>អ. band<br>បារ. bande ( f. ) | បន្ទះស្បៃ លោហធាតុ ឬប្លាស្ទិកទន់ប្រើក្នុងវេជ្ជសាស្ត្រ សម្រាប់រុំព័ទ្ធសរីរាង្គណាមួយ។ |
| ៣៨-បន្ទប់វះកាត់/<br>សល្យសាល<br>អ. operating room/<br>operating theaters<br>បារ. bloc opératoire | បន្ទប់ស្តេរីលស្អាតមានអនាម័យត្រឹមត្រូវនៅក្នុងមន្ទីរពេទ្យ ដែលបំពាក់ដោយបរិក្ខារសម្រាប់ការវះកាត់តូចធំនិងការព្យាបាលផ្សេងៗទៀត។ |
| ៣៩- បរាសិតវិទ្យា<br>អ. parasitology<br>បារ. parasitologie ( f. ) | វិទ្យាសាស្ត្រសិក្សាពីពពួកបរាសិត( parasite )។ |
| ៤០- ប៊ីស្ទូរី<br>អ. bistoury<br>បារ. bistouri ( m. ) | ឧបករណ៍វេជ្ជសាស្ត្រដែលជាកាំបិតតូចៗមានច្រើនប្រភេទសម្រាប់ប្រើក្នុងការវះកាត់។ |
| ៤១- ប៊ូយ៉ុង<br>អ. bouillon/broth<br>បារ. bouillon ( m. ) | ទឹករម្ងាស់ជាតិសាច់ បន្លែ ... ប្រើក្នុងមីក្រុបវិទ្យាដើម្បីធ្វើជាថ្នាលវប្បកម្ម។ |
| ៤២- ប៊ូលីមី<br>អ. bulimia<br>បារ. boulimie ( f. ) | ជំងឺសរសៃប្រសាទម្យ៉ាងដែលបង្កឱ្យអ្នកជំងឺមានអាការៈឃ្លានខ្លាំងស៊ីមិនដឹងឆ្អែត។ |
| ៤៣- បារម្ភ<br>អ. worry<br>បារ. inquiétude ( f. ) | អាការៈខ្វល់ខ្វាយក្នុងចិត្តអំពីហេតុការណ៍ដែលអាចឬមិនអាចកើតមានឡើង។ |
| ៤៤- បាស៊ីុយ៍/បាស៊ី<br>អ. bacillus<br>បារ. bacille ( m. ) | ពពួកបាក់តេរីឯកកោសិកាមានរាងដូចកូនដំបង ដែលអាចរស់នៅក្នុងដី ទឹក ខ្យល់ សព៌ាង្គកាយ ...។ |

| | |
|---|---|
| ៤៥- បាស៊ីយ៍/<br>បាស៊ីយ៍ហាំងសិន<br>អ. Hansen´s bacillus<br>បារ. bacille de Hansen | បាក់តេរីម្យ៉ាងដែលបង្ករោគឃ្លង់។ បាក់តេរីនេះរកឃើញនៅគ.ស.១៨៧៣ ដោយជនជាតិន័រវែសឈ្មោះ ហាំងសិន(Gerhard Armauer Hansen)។ |
| ៤៦- បាស៊ីយ៍របេង/<br>បាស៊ីយ៍កុក<br>អ. tuberculosis bacillus<br>បារ. Bacille de la tuberculose/<br>Bacille de Koch | បាក់តេរីម្យ៉ាងដែលបង្ករោគរបេងចំពោះមនុស្សនិងសត្វ។ បាក់តេរីនេះរកឃើញនៅគ.ស.១៨៨២ ដោយជនជាតិអាល្លឺម៉ង់ឈ្មោះ រ៉ូបែរកុក(Robert Koch)។ |
| ៤៧- បេសេហ្សេ(វ៉ាក់សាំង)<br>អ. bacillus Calmette Guérin(vaccine)<br>បារ. BCG (vaccin)/ bacille bilié Calmette-Guérin (vaccin) | វ៉ាក់សាំងការពាររោគរបេងដែលរកឃើញនៅចន្លោះគ.ស.១៩០៤-១៩២៨ ដោយជនជាតិបារាំងឈ្មោះលោក អាល់ប៊ែរកាល់ម៉ែត(Albert Calmette) និងលោក កាមី(យ៍) ហ្គេរ៉ាំង(Camille Guérin)។ |
| ៤៨- បំណាក់ជាពីរ/<br>អាប់រុបស្យុង<br>អ. abruption<br>បារ. abruption (f.) | ការបាក់ទទឹងឆ្អឹងជាពីរកំណាត់ដែលមានលក្ខណៈគគ្រាតត្រង់មុខបាក់។ [ពាក្យនេះប្រើក្នុងត្រូម៉ាតូវិទ្យា (traumatologie)]។ |
| ៤៩- ផៀក<br>អ. albinism<br>បារ. albinisme (m.)/albinie (f.) | អាការៈគ្មានជាតិពណ៌ម៉េឡានីន(pigment de la mélanine)នៃស្បែក (ភ្នែក សក់ រោម ...)ពីកំណើតពេញទាំងខ្លួនឬផ្នែកណាមួយនៃសរីរាង្គកាយ។ |
| ៥០- ពកសាច់ដុំ<br>អ. myoma<br>បារ. myome (m.) | ដុំពកស្លូត(tumeur bénigne)កើតឡើងពីជាលិកាសាច់ដុំមិនប្រក្រតី។ |
| ៥១- ពេទ្យព្យាបាល<br>អ. therapist<br>បារ. thérapeute (m.) | អ្នកវេជ្ជសាស្ត្រដែលមានចំណេះជំនាញក្នុងការព្យាបាលជំងឺ។ |
| ៥២- ព័ត៌មានជំងឺ<br>អ. anamnesis<br>បារ. anamnèse (f.) | ដំណឹងស្តីពីស្ថានភាពជំងឺដែលអ្នកជំងឺឬសមាជិកគ្រួសាររៀបរាប់ភ្លាមៗប្រាប់គ្រូពេទ្យ។ |

| | |
|---|---|
| **៥៣- ភាពជូរ/អាស៊ីដភាព**<br>អ. acidity<br>បារ. acidité ( f. ) | កម្រិតជាតិអាស៊ីដឬជាតិជូរនៅក្នុងល្បាយមួយដែលមានpH ក្រោម៧។ |
| **៥៤-ភាពមិនប្រក្រតី/ អណូម៉ាលី**<br>អ. anomaly<br>បារ. anomalie ( f. ) | លក្ខណៈខុសប្លែកពីធម្មតានៃសរីរាង្គណាមួយរបស់សពាង្គកាយ។ |
| **៥៥- មនុស្សផ្សើក**<br>អ. albino<br>បារ. albinos ( m. ) | មនុស្សដែលគ្មានជាតិពណ៌ម៉េឡានីន( pigment de la mélanine )នៅស្បែក ( ភ្នែក សក់ រោម ... )ពីកំណើត។ |
| **៥៦- មរណាសន្នកាល/ អាហ្គូនី**<br>អ. agony<br>បារ. agonie ( f. ) | ដំណាក់កាលស្លួឈាមមុនស្លាប់របស់អ្នកជំងឺដោយសារកង្វះអុកស៊ីហ្សែនទៅចិញ្ចឹមខួរក្បាល។ |
| **៥៧- មហារីកវិទ្យា**<br>អ. cancerology<br>បារ. cancérologie ( f. ) | វិទ្យាសាស្ត្រសិក្សាពីជំងឺមហារីក វិធីសាស្ត្រការពារនិងព្យាបាល។ |
| **៥៨- មាត់ឆែប/ឆែបមាត់**<br>អ. cleft lip/cleft palate<br>បារ. bec-de-lièvre ( m. ) | វិរូបភាពពីកំណើតដែលបបូរមាត់និង/ឬក្រអូមមាត់ខាងលើមានសណ្ឋានជាចង្វះប្រហោ។ |
| **៥៩- មីកូវិទ្យា**<br>អ. mycology<br>បារ. mycologie ( f. ) | វិទ្យាសាស្ត្រសិក្សាពីជំងឺដែលបង្កដោយមេរោគជាពពួកផ្សិត( champignon )។ |
| **៦០- មូត្រព្យាបាល**<br>អ. urotherapy<br>បារ. urothérapie ( f. ) | វិធីវេជ្ជសាស្ត្រវិភាគនិងព្យាបាលជំងឺប្រព័ន្ធទឹកនោម។ |
| **៦១- យានសង្គ្រោះ**<br>អ. ambulance<br>បារ. ambulance ( f. ) | មធ្យោបាយដឹកជញ្ជូនដែលមានបំពាក់ឧបករណ៍វេជ្ជសាស្ត្រ ដើម្បីជួយសង្គ្រោះបន្ទាន់ដល់អ្នកជំងឺ អ្នករបួស ជនរងគ្រោះផ្សេងៗ ឬ ដឹកសាកសព។ |

| | |
|---|---|
| **៦២- របួមតូច/អត្រេស៊ី**<br>អ. atresia<br>បារ. atrésie ( f. ) | អាការៈរួមតូចនៃបំពង់ឬរន្ធរបស់សរីរាង្គ ដែលមានលក្ខណៈជាវិរូបភាពពីកំណើត ឬក្រោយកំណើត ហើយដែលធ្វើឱ្យមុខងារសរីរាង្គនោះថយចុះ ឬ បាត់បង់។ |
| **៦៣- របួស**<br>អ. injury<br>បារ. blessure ( f. ) | ភាពដាច់រហែកជាលិកានៃសរីរាង្គដែលបង្កដោយគ្រោះថ្នាក់ផ្សេងៗ។ |
| **៦៤- រេសិចស្យុង**<br>អ. resection<br>បារ. résection ( f. ) | ការកាត់ឬច្រឹបតាមវិធីវេជ្ជសាស្ត្រនូវផ្នែកសរីរាង្គខាងក្នុងណាមួយឬសរីរាង្គទាំងមូល បន្ទាប់មកត្រូវដេរភ្ជិតឬដេរតភ្ជាប់ឱ្យមានដំណើរការឡើងវិញ។ |
| **៦៥- រំហូរពីស្បូន**<br>អ. metrorrhea<br>បារ. métrorrhée ( f. ) | ការហូរសារធាតុរាវដែលអាចជាទឹករំអិល ( mucus/glaire ) ទឹកភ្លោះ ( liquide amniotique ) ឬកម្ទេចកម្ទីផ្សេងៗពីក្នុងស្បូន។ |
| **៦៦- ល្ឮ**<br>អ. audition<br>បារ. audition ( f. ) | ការស្តាប់ឮនៃសោតវិញ្ញាណ។ |
| **៦៧- វិរូបភាព**<br>អ. malformation<br>បារ. malformation ( f. ) | លក្ខណៈខុសប្រក្រតីពីកំណើតនៃសរីរាង្គណាមួយរបស់សព៌ាង្គកាយ។ |
| **៦៨- សម្អិតខះ**<br>អ. agglutination<br>បារ. agglutination ( f. ) | ការស្អិតខះជាប់គ្នារបស់កោសិកា ឬ មីក្រូសព៌ាង្គកាយដោយសារអន្តរកម្មរវាង អង់ទីហ្សែននិងអង់ទីករនៅពេលជួបគ្នា។ |
| **៦៩- សល្យកម្មសព/អូតុបស៊ី**<br>អ. autopsy<br>បារ. autopsie ( f. ) | វិធីវះកាត់សាកសពដោយអ្នកជំនាញវេជ្ជសាស្ត្រធ្វើកោសល្យវិច័យដើម្បីរកមូលហេតុនៃមរណភាពឬដើម្បីស្រាវជ្រាវវិទ្យាសាស្ត្រវេជ្ជសាស្ត្រ។ |
| **៧០- ស្ត្រុក**<br>អ. stroke/cerebrovascular accident<br>បារ. accident vasculaire cérébral ( AVC ) ( m. ) | ផលវិបាកស្រួចស្រាល់នៃខួរក្បាលបណ្តាលមកពីគ្រោះថ្នាក់ ដោយតៀ្បត ឬ ដាច់សរសៃឈាមក្នុងខួរក្បាលឬក្នុងស្រោមខួរក្បាលដែលបង្កជាកង្វះឈាមទៅចិញ្ចឹមខួរក្បាល។ |

| | |
|---|---|
| **៧១- ស្រួចស្រាល់**<br>អ. acute<br>បារ. aigu,-uë ( adj. ) | ដែលមានអាការៈឈឺទាន់ហាន់ហើយធ្ងន់ធ្ងរផ្ទុយនឹងអាការៈរ៉ាំរ៉ៃ ( chronique )។ |
| **៧២- ស្រួចស្រាល់កម្ម/ ស្រួចស្រាល់នីយកម្ម**<br>អ. acutization<br>បារ. acutisation ( f. ) | ការវិវត្តជំងឺពីរ៉ាំរ៉ៃទៅស្រួចស្រាល់។ |
| **៧៣- សំដាប់ស្ទង់**<br>អ. auscultation<br>បារ. auscultation ( f. ) | ការស្តាប់សំឡេងសរីរាង្គក្នុងសព៌ាង្គកាយ ដូចជា សួត បេះ ដូង ពោះវៀន ជាដើម ដើម្បីធ្វើរោគវិនិច្ឆ័យដោយប្រើត្រចៀកផ្ទាល់ឬដោយប្រើឧបករណ៍ វេជ្ជសាស្ត្រ។ |
| **៧៤- អកាឌីយ៉ាក់**<br>អ. acardiac<br>បារ. acardiaque ( m. ) | វិរូបភាពគ្មានបេះដូងពីកំណើត។ |
| **៧៥- អកាល់គុយលី**<br>អ. acalculia<br>បារ. acalculie ( f. ) | អសមត្ថភាពរបស់បុគ្គលក្នុងការគិតលេខ ដូចជា បូក ដក គុណ ចែក ជាដើម។ |
| **៧៦- អកីរ៉ូប៉ូឌី**<br>អ. acheiropodia<br>បារ. acheiropodie ( f. ) | វិរូបភាពគ្មានប្រអប់ដៃនិងប្រអប់ជើងម្ខាងឬទាំងសងខាងពីកំណើត។ |
| **៧៧- អកីរី**<br>អ. acheiria<br>បារ. acheirie ( f. ) | វិរូបភាពគ្មានប្រអប់ដៃម្ខាងឬទាំងសងខាងពីកំណើត។ |
| **៧៨- អកូរី**<br>អ. acoria<br>បារ. acorée/acorie ( f. ) | វិរូបភាពគ្មានរន្ធប្រស្រីភ្នែកពីកំណើត។ |
| **៧៩- អកូលី**<br>អ. acholia<br>បារ. acholie ( f. ) | អាការៈមិនប្រក្រតីរបស់ថ្លើមដែលគ្មានការបញ្ចេញទឹកប្រមាត់។ |
| **៨០- អកូលូរី**<br>អ. acholuria<br>បារ. acholurie ( f. ) | អាការៈមិនប្រក្រតីដោយគ្មានទឹកប្រមាត់ក្នុងទឹកមូត្រ។ |

| | |
|---|---|
| **៨១- អកេលី**<br>អ. acheilia<br>បារ. acheillie/achélie/<br>achilie (f.) | វិរូបភាពគ្មានបបូរមាត់មួយផ្នែកឬទាំងមូលពីកំណើត។ |
| **៨២- អក្រូម៉ាតុបស៊ី**<br>អ. achromatopsia<br>បារ. achromatopsie (f.) | អាការៈមិនប្រក្រតីរបស់ភ្នែកដែលមិនអាចញែកពណ៌បាន។ |
| **៨៣- អក្រូម៉ាស៊ី**<br>អ. achromasia<br>បារ. achromasie (f.) | អាការៈមិនប្រក្រតីរបស់ស្បែកដែលបាត់ជាតិពណ៌។ |
| **៨៤- អក្រូមី**<br>អ. achromia<br>បារ. achromie(f.) | ការថយចុះឬការបាត់ជាតិពណ៌របស់ស្បែក។ |
| **៨៥- អក្លរីឌ្រី**<br>អ. achlorhydria<br>បារ. achlorhydrie/<br>anachlorhydrie (f.) | អាការៈមិនប្រក្រតីដោយគ្មានអាស៊ីដក្លរីឌ្រិកក្នុងរសក្រពះ។ |
| **៨៦- អគីលី**<br>អ. achylia<br>បារ. achylie (f.) | អវត្តមានអាស៊ីដក្លរីឌ្រិកក្នុងរសក្រពះ។ |
| **៨៧- អង់ដូមេទ្រីយ៉ូម**<br>អ. endometrioma<br>បារ. endométriome (m.) | ដុំពកស្លូត (tumeur bénigne) នៃភ្នាសក្នុងស្បូន(endomètre)ដែលមានរាងមូលៗមានស្រោមដូចណ្ឌូឌុល(nodule)។ |
| **៨៨- អង់ដូមេទ្រីយ៉ូស**<br>អ. endometriosis<br>បារ. endométriose (f.) | វត្តមានជាលិកាភ្នាសក្នុងស្បូន(endomètre) នៅទីតាំងខុសប្រក្រតី ដូចជានៅក្នុងដៃស្បូន(trompe de Fallope) សាច់ដុំស្បូន(myomètre) ឬនៅក្រៅស្បូនជាដើម។ |
| **៨៩- អង់ហ្ស៊ីន**<br>អ. angina<br>បារ. angine (f.) | អាការៈឈឺចាប់ខ្លាំងភ្លាបណ្ដាលមកពីការកន្ត្រាក់សាច់ដុំ(spasme)នៅត្រង់ចំណុចណាមួយនៃសរីរាង្គ។ |

| | |
|---|---|
| **៩០- អចលនា**<br>អ. akinesia<br>បារ. acinésie ( f. )/<br>akinésie ( f. ) | អាការៈមិនប្រក្រតីដែលសាច់ដុំពុំអាចកន្ត្រាក់បាន។ |
| **៩១- អប្រាស៊ី**<br>អ. abrachia<br>បារ. abrachie ( f. ) | វិរូបភាពគ្មានដៃពីកំណើត។ |
| **៩២- អប្រាស្យ៉ូសេហ្វាលី**<br>អ. abrachiocephalia<br>បារ. brachiocéphalie ( f. ) | វិរូបភាពចម្លែកដោយគ្មានដៃនិងគ្មានក្បាលពីកំណើត។ |
| **៩៣- អមូត្រ**<br>អ. anuria<br>បារ. anurie ( f. ) | អាការៈគ្មានទឹកនោមក្នុងប្លោកនោម។ |
| **៩៤- អវត្តមាន/អាប់សង់**<br>អ. absence<br>បារ. absence ( f. ) | អាការៈបាត់ការចងចាំនិងអាចឈានដល់ការបាត់ស្មារតីមួយរយៈពេលខ្លី ដោយសារកង្វះឈាមទៅចិញ្ចឹមខួរក្បាល។<br>( ពាក្យនេះប្រើក្នុងជំនាញជំងឺផ្លូវចិត្ត )។ |
| **៩៥- ឱសថជំនួយកម្លាំង/ អាណាឡិបទិក**<br>អ. analeptic<br>បារ. analeptique ( m ) | សារជាតុឱសថឬចំណីអាហារពិសេសដែលធ្វើឱ្យមានកម្លាំងឡើងវិញនិងធ្វើឱ្យមានរំញោចប្រព័ន្ធប្រសាទកណ្តាលឬសរីរាង្គដទៃទៀតរបស់សព៌ាង្គកាយ។ |
| **៩៦- ឱសថលាងរបួស/ អាប់ស្ទែហ្សង់**<br>អ. abstergent<br>បារ. abstergent ( m. ) | សារជាតុថ្នាំផ្សេងៗប្រើសម្រាប់លាងសម្អាតរបួស។ |
| **៩៧- អសេហ្វាលី**<br>អ. acephalia<br>បារ. acéphalie ( f. ) | វិរូបភាពគ្មានក្បាលមួយចំណែកឬទាំងមូលពីកំណើត។ |
| **៩៨- អាកត្រូស**<br>អ. arthrosis<br>បារ. arthrose ( f. ) | អាការៈខូចសន្លាក់ពុំរ៉ៃដោយគ្មានរោគសញ្ញារលាកដែលបង្កឱ្យសន្លាក់នោះ ចុះខ្សោយឬគាំង។ ជាទូទៅ អាការៈនេះច្រើនកើតនៅសន្លាក់ជង្គង់ ឬ សន្លាក់ត្រគាកចំពោះមនុស្សមានវ័យលើសពី៥០ឆ្នាំឡើងទៅ។ |

| | |
|---|---|
| **៩៩- អាក្រូឌីនី**<br>អ. acrodynia<br>បារ. acrodynie (f.) | អាការៈឈឺចុកចាប់នៅប្រអប់ដៃនិងប្រអប់ជើងនៃកុមារ ដែលមានអាយុពី៦ ទៅ៨ឆ្នាំ។ |
| **១០០- អាក្រូប៉ាតូវិទ្យា**<br>អ. acropathology<br>បារ. acropathologie (f.) | វិទ្យាសាស្ត្រសិក្សាពីជំងឺនៅផ្នែកចុងនៃសព៌ាង្គកាយ (extrémité de l'organisme)។ |
| **១០១- អាក្រូប៉ាទី**<br>អ. acropathy<br>បារ. acropathie (f.) | ជំងឺដែលកើតមាននៅតែខាងចុងដៃ ចុងជើងនិងក្បាល។ |
| **១០២- អាក្រូប៉ូស្ទីត**<br>អ. acroposthitis<br>បារ. acroposthite (f.) | អាការៈរលាកផ្នែកខាងចុងស្បែកគ្របក្បាលលិង្គ។ |
| **១០៣- អាក្រូមីគ្រី**<br>អ. acromicria<br>បារ. acromicrie (f.) | អាការៈរួមតូចខុសប្រក្រតីនៃក្បាល ចុងដៃនិងចុងជើងពីកំណើត។ |
| **១០៤- អាក្រូមេលី**<br>អ. acromelia<br>បារ. acromélie (f.) | ផ្នែកខាងចុងដៃនិងជើង។ |
| **១០៥- អាក្រូមេហ្គាលី**<br>អ. acromegaly<br>បារ. acromégalie (f.) | អាការៈរីកធំខុសធម្មតានៃក្បាល ច្រមុះ ត្រចៀក អណ្តាត ព្រមទាំងឆ្អឹងចុងដៃ ចុងជើង និងមានគមកញ្ចឹងកធ្វើឱ្យឆ្អឹងទ្រូងរុញមកមុខ (cyphose cervico-dorsale avec saillie du sternum)។ |
| **១០៦- អាក្រូសក្លេរ៉ូស**<br>អ. acrosclerosis<br>បារ. acrosclérose (f.) | អាការៈក្រិនស្បែកផ្នែកខាងចុងដៃ ចុងជើងនិងក្បាល។ |
| **១០៧- អាក្រូសាំងដាក់ទីលី**<br>អ. acrosyndactyly<br>បារ. acrosyndactylie (f.) | វិរូបភាពដែលចុងម្រាមដៃឬចុងម្រាមជើងស្អិតជាប់គ្នាពីកំណើត។ |

| | |
|---|---|
| **១០៨- អាក្រូសេហ្វាលី**<br>អ. acrocephalia<br>បារ. acrocéphalie/<br>hypsocéphalie ( f. ) | វិរូបភាពនៃឆ្អឹងលលាដ៍ក្បាលដោយផ្នែកខាងមុខ និង សងខាងមិនលូតលាស់ ធ្វើឱ្យទ្រង់ទ្រាយក្បាលមានរាងសំប៉ែត ហើយឆ្អឹងលលាដ៍ខាងក្រោយវិវត្តពយ ទៅក្រោយនិងទៅលើ។ |
| **១០៩- អាក្រូស្យាណូស**<br>អ. acrocyanosis<br>បារ. acrocyanose ( f. ) | អាការៈមិនប្រក្រតីរបស់ស្បែកដោយចុងដៃចុងជើងឡើងពណ៌ខៀវស្លេកជាប្រចាំ។ អាការៈនេះកម្រកើតមាននៅច្រមុះ ត្រចៀក ថ្ពាល់ និងផ្នែកខាងក្រោយនៃដើមដៃ។ |
| **១១០- អាក់ទីណូព្យាបាល**<br>អ. actinotherapy<br>បារ. actinothérapie ( f. ) | វិធីព្យាបាលជំងឺដោយប្រើកាំរស្មីស្វាយអ៊ុលត្រា ( ultraviolet ) កាំរស្មីក្រហម អាំងហ្វ្រា ( infrarouge )...។ |
| **១១១- អាក់ទីណូមហារីក**<br>អ. actinocancer<br>បារ. actinocancer ( m. ) | ជំងឺមហារីកស្បែកដែលបង្កឡើងដោយរំភាយរស្មីព្រះអាទិត្យ។ |
| **១១២- អាក់ទីណូវិទ្យា**<br>អ. actinology<br>បារ. actinologie ( f. ) | វិទ្យាសាស្ត្រសិក្សាអំពីផលប៉ះពាល់នៃរំភាយរស្មី ជាពិសេសកាំរស្មីស្វាយអ៊ុលត្រា ( ultraviolet ) ក្រហមអាំងហ្វ្រា ( infr-arouge )...នៃព្រះអាទិត្យៈក្នុងផ្នែកជីវវេជ្ជសាស្ត្រ។ |
| **១១៣- អាក់ទីនីត**<br>អ. actinitis<br>បារ. actinite ( f. ) | អាការៈរលាកស្បែកដែលបង្កឡើងដោយរំភាយរស្មីព្រះអាទិត្យ។ |
| **១១៤- អាក់ទីវ៉ាទ័រ**<br>អ. activator<br>បារ. activateur ( m. ) | វត្ថុជាតុរូបឬគីមី ( élément pysique ou chimique ) ដែលជួយពន្លឿនជីវប្រតិកម្ម ( réaction biologique )។ |
| **១១៥- អាក់ទីវ៉ាស្យុង**<br>អ. activation<br>បារ. activation ( f. ) | ការពន្លឿនជីវប្រតិកម្មដោយប្រើអាក់ទីវ៉ាទ័រ។ |
| **១១៦- អាក់សែ**<br>អ. access<br>បារ. accès ( m. ) | អាការៈជំងឺកើតឡើងយ៉ាងទាន់ហន់ខ្លាំងក្លាដែលមានរយៈពេលខ្លីជាបន្តបន្ទាប់ និងទៀងទាត់។ |

| | |
|---|---|
| **១១៧- អាគូម៉ែត្រ**<br>អ. acoumeter<br>បារ. acoumètre ( m. ) | ឧបករណ៍វេជ្ជសាស្ត្រសម្រាប់វាស់សំឡេងដែលត្រចៀកអាចស្តាប់ឮ។ |
| **១១៨- អាគូមេទ្រី**<br>អ. acoumetry<br>បារ. acoumétrie ( f. ) | ការវាស់សំឡេងដែលត្រចៀកអាចស្តាប់ឮដោយប្រើអាគូម៉ែត្រ។ |
| **១១៩- អាគូស្ទិក**<br>អ. acoustic<br>បារ. acoustique ( adj. ) | ដែលជាប្រព័ន្ធសរសៃប្រសាទដែលទាក់ទងគ្នារវាងត្រចៀកនិងខួរក្បាល។ |
| **១២០- អាគូស្មាតាញ៉ូស៊ី**<br>អ. acousmatagnosis<br>បារ. acousmatagnosie ( f. ) | ជំងឺថ្លង់ម្យ៉ាងដែលបណ្តាលមកពីប្រព័ន្ធសរសៃប្រសាទកណ្តាលមិនអាចចាប់ ឬដឹងសំឡេងអ្វីមួយបានច្បាស់។ |
| **១២១- អាគូហ្វែន**<br>អ. tinnitus<br>បារ. acouphène ( m. ) | អាការៈមិនប្រក្រតីរបស់ត្រចៀកដែលហ៊ឹងហើយឮសំឡេងប្លែកៗខុសពីសំឡេងរំញោចពីខាងក្រៅ។ |
| **១២២- អាគ្វីតេ**<br>អ. acuteness /acuity<br>បារ. acuité ( f. ) | សមត្ថភាពនៃវិញ្ញាណដែលអាចវិនិច្ឆ័យអ្វីៗដែលតូចឬតិចបំផុត។ |
| **១២៣- អាគ្វីតេគំហើញ**<br>អ. visual acuity<br>បារ. acuité visuelle | សមត្ថភាពនៃចក្ខុវិញ្ញាណដែលអាចមើលឃើញរូបភាពតូចបំផុតបាន។ |
| **១២៤- អាគ្វីតេល្បឺ**<br>អ. auditory acuity<br>បារ. acuité auditive | សមត្ថភាពនៃសោតវិញ្ញាណដែលអាចទទួលសំឡេងតិចបំផុតបាន។ |
| **១២៥- អាណាហ្វីឡាស៊ី**<br>អ. anaphylaxis<br>បារ. anaphylaxie ( f. ) | ប្រតិកម្មនៃសរីរាង្គទៅនឹងសារធាតុពីក្រៅតាមការលេប ការចាក់ ការហិត ឬការប៉ះពាល់ដែលបង្កជារោគសញ្ញាផ្សេងៗដូចជា ឡើងកន្ទួលរមាស់លើស្បែក កណ្តាស់ ឬអាចបណ្តាលឱ្យស្តុក(choc) និង/ឬរហូតដល់ស្លាប់ក៏មាន។ |

| | |
|---|---|
| **១២៦- អាណេវ្រីស**<br>អ. aneurysm<br>បារ. anévrisme/<br>anévrysme ( m ) | អាការៈរីកប៉ោងភ្នាសសរសៃឈាមដែលបង្កឱ្យកើតមានជាអាតេរ៉ូម។ |
| **១២៧- អាតេរ៉ូម**<br>អ. atheroma<br>បារ. athérome ( m. ) | ១-គីស្ត ( kyste ) កើតឡើងដោយសារកំណកខ្ទុះនៃមុន ( acné )។<br>២-កំណកសារជាតុខ្លាញ់នៅភ្នាសក្នុងនៃអាកទែដែលបង្កឱ្យឡើងសម្ពាធឈាម។ |
| **១២៨- អាប់រេអាក់ស្យុង**<br>អ. abreaction<br>បារ. abréaction ( f. ) | សភាពចិត្តរបស់អ្នកមានវិបត្តិផ្លូវចិត្តដែលកើតឡើងវិញនូវស្មារតីចង់ចាំចំពោះហេតុការណ៍ដែលបានភ្លេចបាត់ពីពេលកន្លងមក។ |
| **១២៩- អាមីប**<br>អ. amoeba<br>បារ. amibe ( f. ) | បរាសិតឯកកោសិកាមានក្បាល ដងខ្លួន និង កន្ទុយអាចធ្វើចលនាបានយ៉ាងរហ័ស ដែលជាភ្នាក់ងារបង្កជំងឺមួលឈាម ( dysentérie amibienne )។ |
| **១៣០- អាយុ**<br>អ. age<br>បារ. âge ( m. ) | រយៈពេលនៃជីវិតរស់នៅរបស់បុគ្គលណាមួយចាប់ពីថ្ងៃកើតដល់ពេលណាមួយ ឬដល់ថ្ងៃស្លាប់។ |
| **១៣១- អាស៊ីដូស**<br>អ. acidosis<br>បារ. acidose ( f. ) | អាការៈមិនប្រក្រតីដោយមានអតុល្យភាពអាស៊ីដ-បាសនៃប្លាស្មាក្នុងឈាម ដែលកម្រិត pH តូចជាង៧,៤០។ |
| **១៣២- អាស៊ីដ្យូរី**<br>អ. aciduria<br>បារ. acidurie ( f. ) | វត្តមានអាស៊ីដច្រើនលើសលប់ក្នុងទឹកមូត្រ។ |
| **១៣៣- អាស៊ីដេមី**<br>អ. acidaemia<br>បារ. acidémie ( f. ) | ភាពចុះទាបជាងធម្មតានៃកម្រិតpH( ៧,៤០ )របស់ឈាម។ |
| **១៣៤- អាសេតូន**<br>អ. acetone ( ketone )<br>បារ. acétone ( f. ) | សារជាតុអាស៊ីដសរីរាង្គកើតឡើងដោយសារអុកស៊ីដកម្មអាស៊ីដខ្លាញ់ក្នុងសព៌ាង្គកាយដែលជាធម្មតាមានបរិមាណតិចតួចនៅក្នុងឈាមនិងទឹកមូត្រ។ |

| | |
|---|---|
| **១៣៥- អាសេតូនូរី**<br>អ. acetonuria<br>បារ. acétonurie (f.) | វត្តមានអាសេតូននៅក្នុងទឹកមូត្រ។ |
| **១៣៦- អាសេតូនេមី**<br>អ. acetonaemia<br>បារ. acétonémie (f.) | វត្តមានអាសេតូននៅក្នុងឈាម។ |
| **១៣៧- អាស្បេស្តូស**<br>អ. asbestosis<br>បារ. asbestose (f.) | ជំងឺធូលីសួតម្យ៉ាងបង្កឡើងដោយការដកដង្ហើមស្រូបចូលផង់អាម៉្យង់(amiante) ផង់ម៉ាញេស្យូមស៊ីលីកាត(silicate de magnésium)ផង់ដែកអុកស៊ីដ (oxyde de fer) ... ដែលប្រើក្នុងឧស្សាហកម្ម។ |
| **១៣៨- អូតូក្លាវ**<br>អ. autoclave<br>បារ. autoclave (m.) | ទូ ឬ ធ្នាំងពិសេសសម្រាប់ធ្វើស្តេរីលកម្មសម្ភារៈវេជ្ជសាស្ត្រ ឬ សម្ភារៈផ្សេងៗ ដោយប្រើចំហាយទឹកដែលមានកម្តៅនិងសម្ពាធខ្ពស់។ |
| **១៣៩- អំពូតាស្យុង**<br>អ. amputatin<br>បារ. amputation (f.) | ការកាត់ចោលតាមវិធីវេជ្ជសាស្ត្រនូវផ្នែកណាមួយនៃអវយវៈឬសរីរាង្គខាងក្រៅ។ |

# ៤- សិក្ខាសាលាស្ដីពី «បញ្ហាយុគលពិន្ទុប្រើក្នុងពាក្យកម្ចីភាសាបាលី-សំស្ក្រឹត»




កាលពីថ្ងៃសុក្រ ១០កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជាបានរៀបចំសិក្ខាសាលាមួយស្ដីពីបញ្ហាយុគលពិន្ទុប្រើក្នុងពាក្យកម្ចីពីភាសាបាលី-សំស្ក្រឹត។

សមាសភាពដែលបានអញ្ជើញចូលរួមក្នុងសិក្ខាសាលានេះ ជាសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា វិទ្យាស្ថានជាតិអប់រំ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ និងក្រុមការងារវចនានុក្រមខ្មែរនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ សរុបចំនួន១២០នាក់។

នៅក្នុងសិក្ខាសាលានេះមានវាគ្មិនជាព្រះសង្ឃចំនួន៣អង្គគឺ **ភិក្ខុ ឈុម ទីរ៍, ភិក្ខុ ផល សុភឿន និង ភិក្ខុ ស៊ឹម សោន** និង វាគ្មិនគ្រហស្ថ១នាក់ គឺឯកឧត្ដម **សូ មុយឃៀង** ប្រធានគណៈកម្មការអក្ខរាវិរុទ្ធនិងអំណាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ។

អត្ថបទពិស្ដាររបស់វាគ្មិនទាំងអស់មាននៅទំព័រខាងក្រោយ ៖

# «បញ្ញាយុគលពិន្ទុប្រើក្នុងពាក្យកម្ចីពីបាលី-សំស្ក្រឹត»

## ដោយ : ឯកឧត្តម សូ មុយឃៀង ប្រធានគណៈកម្មការអក្ខរាវិរុទ្ធនិងអំណាន

យុគលពិន្ទុជាសញ្ញាវណ្ណយុត្តិមួយប្រភេទដែលដូនតាខ្មែរបានបង្កើតឡើងដើម្បីកត់ត្រាសូរ[អាក់]ឬ[អ៊ាក់] នៅខាងក្នុងឬនៅខាងចុងពាក្យដែលខ្ចីពីភាសាបាលីសំស្ក្រឹតមកប្រើក្នុងភាសាខ្មែរ ដូចជា គណៈកម្មាធិការ គណៈសង្ឃ លក្ខណៈពិសេស លក្ខណៈចិត្ត ខេមរៈ ធុរៈ ភារៈ មរណៈ លក្ខណៈ សក្ការៈ ស្រៈ អក្ខរៈ មិទ្ធៈ យុត្តៈ វគ្គន្តៈ ជាដើម។

នៅក្នុងការប្រើប្រាស់កន្លងមកជាពិសេស នៅក្នុងវចនានុក្រមខ្មែរ យើងសង្កេតឃើញមានរបៀបសរសេរ និងរបៀបអានមួយចំនួនគួរឱ្យកត់សម្គាល់។

### ក- ការបង្ហាញ

**១- ពាក្យទោល** (ការសរសេរនិងការអានពាក្យទោលដែលមានឬគ្មានយុគលពិន្ទុ)

ពាក្យកម្ចីពីភាសាបាលីសំស្ក្រឹតខ្លះមានប្រើយុគលពិន្ទុនៅខាងចុងខ្លះពុំមានប្រើយុគលពិន្ទុនៅខាងចុងទេ ប៉ុន្តែអំណានពាក្យទាំងនោះមានការប្រែប្រួលដែលអាចបង្ហាញបានដូចខាងក្រោម៖

**១.១- ពាក្យដែលសរសេរបានតែមួយបែប អានបានតែមួយបែប**

១.១.១- ពាក្យខ្លះសរសេរដោយមានយុគលពិន្ទុនៅខាងចុង ហើយអានដោយមានសូរ[អាក់]ឬ[អ៊ាក់]នៅខាងចុងដូចជា៖

| **ពាក្យ** | **សូរអាន** | **ពាក្យ** | **សូរអាន** |
|---|---|---|---|
| ខណៈ | [ខៈណៈ ] | មុទ្ធជៈ | [មុត-ធៈជៈ] |
| គណៈ | [គៈណៈ] | ឆន្ទៈ | [ឆ័ន-ទៈ] |
| មោហៈ | [មោហៈ] | មិទ្ធៈ | [មិត-ធៈ] |
| ខត្តិយៈ | [ខាត់-តិ-យៈ] | វគ្គន្តៈ | [វ៉ក-គ័ន-តៈ] |
| គន្ថៈ | [គ័ន-ថៈ] | វង្កៈ | [វ៉ង-កៈ] |
| យុត្តៈ | [យុត-តៈ] | វិត្តៈ | [វិត-តៈ] |

១.១.២- ពាក្យខ្លះសរសេរដោយគ្មានយុគលពិន្ទុនៅខាងចុង ហើយអានដោយមានសូរ[អាក់]ឬ[អ៊ាក់] នៅខាងចុងដូចជា៖

| **ពាក្យ** | **សូរអាន** | **ពាក្យ** | **សូរអាន** |
|---|---|---|---|
| ធម្ម | [ធ័ម-មៈ] | បុញ្ញ | [បុញ-ញ៉ៈ] |
| បុព្វ | [បុប-ពៈ] | វត្ត | [វ័ត-តៈ] |
| លញ្ច | [ល៊ុញ-ចៈ] | លទ្ធ | [ល៊ុត-ធៈ] |

១.១.៣- ពាក្យខ្លះសរសេរដោយគ្មានយុគលពិន្ទុនៅខាងចុង ហើយអានដោយមានព្យាង្គបិទនឹង ព្យញ្ជនៈខាងចុង( ព្យាង្គទម្រង់[ពសព] ) ដូចជា៖

| ពាក្យ | សូរអាន | ពាក្យ | សូរអាន |
|---|---|---|---|
| នាយក | [នាយក់] | យាចក | [យាចក់] |
| ទារក | [ទារក់] | សមាជិក | [សម៉ាជិក] |
| រាគ | [រាក] | រោគ | [រោក] |
| កណ្ឋ | [កាន់] | កប្ប | [កាប់] |
| កម្ម | [កាំ] | កល្ប | [កាល់] |
| គោត្ត | [គោត] | កាព្យ | [កាប] |

១.១.៤- ពាក្យខ្លះសរសេរដោយមានព្យញ្ជនៈ «ករ» នៅខាងចុង( គ្មានយុគលពិន្ទុនៅខាងចុងទេ ) ហើយអានដោយមានសូរព្យាង្គ[ក]នៅខាងចុង ដូចជា៖

| ពាក្យ | សូរអាន | ពាក្យ | សូរអាន |
|---|---|---|---|
| កម្មករ | [កាំ-មៈ-ក] | សិប្បករ | [សិប-ប៉ៈ-ក] |
| កសិករ | [ក-សិ-ក] | សិល្បករ | [សិល-បៈ-ក] |
| ពាណិជ្ជករ | [ពា-និច-ជៈ-ក] | តន្ត្រីករ | [ដន់-ត្រី-ក] |

១.១.៥- ពាក្យខ្លះសរសេរដោយមានសញ្ញាបដិសេធនៅលើព្យញ្ជនៈខាងចុង ហើយអានដោយមានព្យាង្គបិទនឹងព្យញ្ជនៈខាងឆ្វេងបន្ទាប់ពីព្យញ្ជនៈមានសញ្ញាបដិសេធនោះ( ព្យាង្គទម្រង់[ពសព] )ដូចជា៖

| ពាក្យ | សូរអាន | ពាក្យ | សូរអាន |
|---|---|---|---|
| គមនាគមន៍ | [គៈ មៈ នា គំ] | ពិសោធន៍ | [ពិសោត] |
| ប្រយោជន៍ | [ប្រយ៉ោច] | ភាជន៍ | [ភាច] |

**១.២- ពាក្យដែលសរសេរបានតែមួយបែប អានបានពីរបែប**

ពាក្យខ្លះសរសេរបានតែមួយបែបដោយគ្មានយុគលពិន្ទុ ហើយអានបានពីរបែប ដូចជា៖

- **ករណីទី១**

| ពាក្យ | សូរអាន | |
|---|---|---|
| កត្តុវាចក | [កាត់-តុ-វា-ចក់] | [កាត់-តុ-វា-ចៈកៈ] |
| កម្ពុជ | [ក័ម-ពុច] | [ក័ម-ពុ-ជៈ] |
| ការុណិក | [កា រ៉ុ ណិក] | [កា រ៉ុ ណិ កៈ] |
| កន្តារ | [កន់-តា] | [កន់-តារៈ] |
| កុសុម | [កុសុំ] | [កុ សុ មៈ] |
| គជ | [គច់] | [គៈជៈ] |
| គោតម | [គោដំ] | [គោ តៈ ម៉ៈ] |

- **ករណីទី២**

| ពាក្យ | សូរអាន | |
|---|---|---|
| នាដក | [នា ដ: ក:] | [នា ដ:-ក] |

### ១.៣- ពាក្យដែលសរសេរបានពីរបែប អានបានមួយបែប

ពាក្យខ្លះសរសេរបានពីរបែបដោយមានឬគ្មានយុគលពិន្ទុនៅខាងចុង ហើយអានបានតែមួយបែបដូចជា៖

| ពាក្យ | | សូរអាន | ពាក្យ | | សូរអាន |
|---|---|---|---|---|---|
| តក្ក | តក្ក: | [ត័ក-ក:] | ទស្សន | ទស្សន: | [ទ័ស សៈន៉ៈ] |
| ទីឃ | ទីឃ: | [ទី឴ ឃៈ] | បាជិទេសនីយ | បាជិទេសនីយ: | [ប៉ា ជិ ទេសៈ នី យ៉ៈ] |
| បាឋ | បាឋ: | [ប៉ា ឋៈ] | ប្រសាធន | ប្រសាធន: | [ប្រ សា ធៈនៈ] |
| មតក | មតក: | [មៈតៈកៈ] | ពហុវចន | ពហុវចន: | [ពៈ ហ៊ុ វៈ ចៈ ន៉ៈ] |

### ១.៤- ពាក្យដែលសរសេរបានពីរបែប អានបានពីរបែប

ពាក្យខ្លះសរសេរបានពីរបែបដោយមានឬគ្មានយុគលពិន្ទុនៅខាងចុង ហើយអានបានពីរបែប ដូចជា៖

| ពាក្យ | | សូរអាន | |
|---|---|---|---|
| ចរាចរក | ចរាចរក: | [ចៈរ៉ា ចៈរ៉ក់] | [ចៈរ៉ា ចៈរ៉ៈកៈ] |
| ឧបត្ថម្ភក | ឧបត្ថម្ភក: | [អ៊ុប៉ុត-ថ័ម-ភក់] | [អ៊ុប៉ុត-ថ័ម ភៈកៈ] |
| ទុក្គត | ទុក្គត: | [ទុក-គត់] | [ទុក-គៈតៈ] |
| ភណ្ឌ | ភណ្ឌ: | [ភ័ន] | [ភ័ន-ឌៈ] |
| ភទន្ត | ភទន្ត: | [ភៈទ័ន] | [ភៈទ័ន-តៈ] |
| ភេសជ្ជ | ភេសជ្ជ: | [ភេស័ច] | [ភេស័ច-ជៈ] |

**២-ពាក្យផ្សំ** (ការសរសេរនិងការអានពាក្យផ្សំដែលមានឬគ្មានយុគលពិន្ទុនៅចន្លោះពាក្យ)

នៅក្នុងការប្រើប្រាស់កន្លងមក ជាពិសេសក្នុងវចនានុក្រមខ្មែរ យើងកត់សម្គាល់ឃើញថា៖

**២.១- ក្នុងពាក្យផ្សំ(ពាក្យផ្សំ < ពាក្យទី១ + ពាក្យទី២)ខ្លះ មានយុគលពិន្ទុនៅខាងចុងពាក្យទី១ ហើយ មានសូរ [អាក់]ឬ[អ៊ាក់]នៅខាងចុងពាក្យទី១នោះ ដូចជា៖**

| **ពាក្យទី១ +ពាក្យទី២ > ពាក្យផ្សំ** | | | | |
|---|---|---|---|---|
| គណ: | + | កម្មការ | > | គណ:កម្មការ |
| គណ: | + | សង្ឃ | > | គណ:សង្ឃ |
| លក្ខណ: | + | ពិសេស | > | លក្ខណ:ពិសេស |
| លក្ខណ: | + | ចិត្ត | > | លក្ខណ:ចិត្ត |
| លក្ខន្តិក: | + | សមាគម | > | លក្ខន្តិក:សមាគម |
| សក្ការ: | + | ជូនតា | > | សក្ការ:ជូនតា |
| សក្ការ: | + | សព | > | សក្ការ:សព |

២.២- ក្នុងពាក្យផ្សំ( ពាក្យផ្សំ < ពាក្យទី១ + ពាក្យទី២ )ខ្លះ មិនមានយុគលពិន្ទុនៅខាងចុងពាក្យទី១ទេ តែក៏មានសូរអាក់ឬអ៊ាក់នៅខាងចុងពាក្យទី១នោះដែរ ដូចជា៖

| ពាក្យទី១ | + | ពាក្យទី២ | > | ពាក្យផ្សំ |
|---|---|---|---|---|
| គណៈ | + | បក្ស | > | គណបក្ស |
| លក្ខណៈ | + | សម្បត្តិ | > | លក្ខណសម្បត្តិ |
| លក្ខណៈ | + | វិបត្តិ | > | លក្ខណវិបត្តិ |
| ផលិតៈ | + | កម្ម | > | ផលិតកម្ម |
| តថៈ | + | ភាព | > | តថភាព |
| សច្ចៈ | + | ធម៌ | > | សច្ចធម៌ |
| អន្តរៈ | + | ក្រសួង | > | អន្តរក្រសួង |
| រាជៈ | + | វាំង | > | រាជវាំង |

## ខ- ការវិភាគ

### ១- ពាក្យគោល

ចំណុច ១.១ ខាងលើ(លើកលែងតែចំណុច ១.១.២) បង្ហាញភាពងាយស្រួល ទាំងក្នុងការសរសេរ ទាំងក្នុងការអាន។

*ចំណុច ១.១.២ (ធម្ម [ធ័ម-មៈ])ខាងលើបង្ហាញភាពលំបាកទាំងក្នុងការសរសេរទាំងក្នុងការអានព្រោះចំណុចនេះប្រឈមនឹងចំណុច ១.១.១ (គន្ថៈ [គ័ន-ថៈ]) និងចំណុច ១.១.៣(កណ្ឋ [កាន់])។

*ចំណុច ១.២ ពាក្យបែប«កត្តុវាចក»ខាងលើបង្ហាញភាពលំបាក ទាំងក្នុងការសរសេរ ទាំងក្នុងការអាន ព្រោះចំណុចនេះប្រឈមនឹងចំណុច ១.១.១(ខណៈ [ខៈណៈ] តែស្របនឹងចំណុច ១.១.៣ (នាយក [នាយក់])។

*ចំណុច ១.២ ពាក្យ«នាដក»ខាងលើបង្ហាញភាពលំបាក ទាំងក្នុងការសរសេរ ទាំងក្នុងការអាន ព្រោះចំណុចនេះ ប្រឈមនឹងចំណុច ១.១.១(ខណៈ [ខៈណៈ]) ចំណុច ១.១.៣ (នាយក [នាយក់]) និងចំណុច ១.១.៤ (កម្មករ [កាំ-ម៉ៈ-ក])។

*ចំណុច១.៣ (តក្ក ឬ តក្កៈ [ត័ក-កៈ])ខាងលើបង្ហាញភាពលំបាកទាំងក្នុងការសរសេរទាំងក្នុងការអាន ព្រោះចំណុចនេះប្រឈមនឹងចំណុច ១.១.៣(កណ្ឋ [កាន់]) តែស្របនឹងចំណុច ១.១.១ (គន្ថៈ [គ័ន-ថៈ]) ...។

ចំណុច ១.៤ («ចរាចរក ឬ ចរាចរកៈ» [ចៈរ៉ា ចៈរ៉ក់ ឬ ចៈរ៉ា ចរ៉ៈកៈ])បង្ហាញភាពងាយស្រួលទាំងក្នុងការសរសេរទាំងក្នុងការអាន ព្រោះចំណុចនេះស្របនឹងចំណុច ១.១.៣ (នាយក[នាយក់])និងចំណុច ១.១.១ (ខណៈ[ខៈណៈ ])...។

### ២- ពាក្យផ្សំ

ក្នុងពាក្យផ្សំ( ពាក្យផ្សំ < ពាក្យទី១ + ពាក្យទី២) ទោះបីពាក្យទី១មានឬគ្មានយុគលពិន្ទុនៅខាងចុងពាក្យទី១ នោះត្រូវតែមានសូរអាក់ឬអ៊ាក់នៅខាងចុង ដូចជា សារៈសំខាន់ សារប្រយោជន៍ ជាដើម។ នេះបង្ហាញភាពលំបាកទាំងក្នុងការសរសេរទាំងក្នុងការអាន។

**គ- ការដោះស្រាយ**

**១- ពាក្យទោល**

(១)- ពាក្យដែលសរសេរដោយមានយុគលពិន្ទុនៅខាងចុង ត្រូវអានដោយមានសូរ[អាក់] ឬ [អ៊ាក់] នៅខាងចុងដូចជា ខណៈ [ខៈណៈ ] ខត្តិយៈ [ខាត់-តិ-យៈ] គណៈ [គៈណៈ] មុទ្ធជៈ [មុត-ធៈជៈ]...។

(២)- ពាក្យដែលសរសេរដោយគ្មានយុគលពិន្ទុនៅខាងចុង( ត្រូវអានដោយគ្មានសូរ[អាក់] ឬ [អ៊ាក់] នៅខាងចុង ) ត្រូវអានដោយមានព្យាង្គបិទនឹងព្យញ្ជនៈខាងចុង( ព្យាង្គទម្រង់[ពសព] ) ដូចជា នាយក [នាយក់] ទារក [ទារក់] យាចក [យាចក់] រោគ [រោក] សមាជិក [សម៉ាជិក] កណ្ហ [កាន់] កប្ប [កាប់] កម្ម [កាំ] កល្ប [កាល់] កាព្យ [កាប] គោត្ត [គោត]...។

(៣)- ពាក្យដែលសរសេរដោយមានសញ្ញាបដិសេធនៅខាងលើព្យញ្ជនៈខាងចុង ត្រូវអានដោយមានព្យាង្គបិទនឹងព្យញ្ជនៈខាងឆ្វេង បន្ទាប់ពីព្យញ្ជនៈមានសញ្ញាបដិសេធនោះ ( ព្យាង្គទម្រង់[ពសព] ) ដូចជា ទស្សន៍ [ទស់] ប្រយោជន៍ [ប្រយ៉ោច]  ពិសោធន៍ [ពិសោត]  ភាជន៍ [ភាច]  គមនាគមន៍ [គៈ មៈ នា គំ]...។

(៤)- ពាក្យដែលសរសេរដោយមានព្យញ្ជនៈ «ករ» នៅខាងចុង( គ្មានយុគលពិន្ទុនៅខាងចុងទេ )ត្រូវអានដោយមានសូរព្យាង្គ[ក]នៅខាងចុង ដូចជា កម្មករ [កាំ-ម៉ៈ-ក]  សិប្បករ [សិប-ប៉ៈ-ក] សិល្បករ [សិល-ប៉ៈ-ក]...។

**២- ពាក្យផ្សំ**

**២.១- ការសរសេរពាក្យផ្សំដោយមិនផ្អែកលើន័យរបស់ពាក្យ**

(១)- ការសរសេរពាក្យផ្សំត្រូវមានយុគលពិន្ទុត្រង់ចន្លោះពាក្យទី១និងពាក្យទី២  បើពាក្យទី១មានយុគលពិន្ទុ នៅខាងចុង ដូចជា «លក្ខណៈពិសេស, លក្ខណៈវិភាគ, លក្ខណៈរូប,...»។

(២)- ការសរសេរពាក្យផ្សំមិនត្រូវមានយុគលពិន្ទុត្រង់ចន្លោះពាក្យទី១និងពាក្យទី២ទេ ទោះបីពាក្យទី១មានយុគលពិន្ទុនៅខាងចុងក៏ដោយ ដូចជា «លក្ខណសម្បត្តិ, លក្ខណវិបត្តិ, សក្ការភាជន៍,...»។

**២.២- ការសរសេរពាក្យផ្សំដោយផ្អែកលើន័យរបស់ពាក្យ**

ការសរសេរពាក្យផ្សំណាមួយដោយមានឬគ្មានយុគលពិន្ទុនៅខាងចុងពាក្យទី១អាស្រ័យលើការពន្យល់ពាក្យផ្សំនោះ។

(១)- បើការពន្យល់ពាក្យផ្សំផ្ដើមចេញពីពាក្យទី១ ត្រូវសរសេរដោយមានយុគលពិន្ទុនៅខាងចុងពាក្យទី១នោះ ដូចជា៖

| ពាក្យ | ន័យ | ពាក្យ | ន័យ |
|---|---|---|---|
| គណៈសង្ឃ | ក្រុមនៃភិក្ខុសង្ឃ | លក្ខណៈពិសេស | លក្ខណៈដែលប្លែក |
| លក្ខណៈចិត្ត | លក្ខណៈនៃចិត្ត | លក្ខន្តិកៈសមាគម | លក្ខន្តិកៈនៃសមាគម |
| សក្ការៈសព | សក្ការៈចំពោះសព | សារៈសំខាន់ | សារៈឬខ្លឹមដែលសំខាន់ គួរយកជាគំរូ |

(២)- បើការពន្យល់ពាក្យផ្សំផ្ដើមចេញពីពាក្យទី២ ត្រូវសរសេរដោយគ្មានយុគលពិន្ទុនៅខាងចុងពាក្យទី១ទេ ដូចជា ៖

| ពាក្យ | ន័យ | ពាក្យ | ន័យ |
|---|---|---|---|
| គណបក្ស | បក្សនៃក្រុមណាមួយ | លក្ខណសម្បត្តិ | ការគ្រប់ព្រមដោយលក្ខណៈ |
| លក្ខណវិបត្តិ | ការខូចលក្ខណៈ | លក្ខន្តិកសញ្ញា | សញ្ញាតាមរបៀបច្បាប់លក្ខន្តិកៈ |
| សក្ការភាជន៍ | ភាជន៍ដាក់គ្រឿងសក្ការៈ | សារប្រយោជន៍ | ប្រយោជន៍ដ៏ប្រសើរ |

## សង្កេត

នៅក្នុងវចនានុក្រមខ្មែរដែលបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ត្រង់ពាក្យ យុគលពិន្ទុ មានសរសេរថា «យុគលពិន្ទុ យុគៈលៈពិន-ទុ សំ. បា. ( ន. ) (យុគល "គូ" + វិន្ទុ ឬ ពិន្ទុ "តំណក់; ចំណុច") ចំណុចមួយគូ ឬ ចំណុចពីរទន្ទឹមគ្នា (ម. ព. ពិន្ទុ ផង)។ ពាក្យសន្មតឱ្យជាឈ្មោះវណ្ណយុត្តមួយយ៉ាង (:) ដូចគ្នានឹង ដឺពង់ក៍ (Deux points) របស់បារាំងសែស, សម្រាប់ប្រើចុចពីខាងមុខអក្សរដែលមានសំឡេងជា អៈ, អាៈ, អេៈ, ជាដើម ដូចជា ខេមរៈ, ធុរៈ, ភារៈ, មរណៈ, លក្ខណៈ, សក្ការៈ, ស្រៈ, អក្ខរៈ, អ៊ីថាៈ, អេៈអុៗ, រអេះរអុ ជាដើម; ប៉ុន្តែ ពាក្យដែលជាសមាសនាម មានដើមថា កម្ពុជរដ្ឋ, ខេមរជាតិ, មគធភាសា, មរណភាព, រាជបុត្រ, សក្ការបូជា, អក្ខរវិធី (ក័ម-ពុជៈរ័ក, ខេម៉ៈរ៉ៈជាត, មៈគៈធៈភាសា, មៈរៈណៈភាប, រាជៈបុត, ស័កការ៉ៈបូជា, អ័កខៈរ៉ៈវិធី)នេះ កុំចុចអក្សរកណ្ដាលជា កម្ពុជៈរដ្ឋ, ខេមរៈជាតិ, មគធៈភាសា, មរណៈភាព, រាជៈបុត្រ, សក្ការៈបូជា, អក្ខរៈវិធី ដូច្នេះឡើយ» ។

## ឯកសារពិគ្រោះ

- *វចនានុក្រមខ្មែរ ភាគទី ១ ភាគទី ២* (១៩៦៧) ភ្នំពេញ : ពុទ្ធសាសនបណ្ឌិត្យ ។

អត្ថបទនេះជាទស្សនៈរបស់ម្ចាស់អត្ថបទ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរទេ

# «បញ្ហាសូរ[អាក់]និង[អ័ក់]ក្នុងភាសាបាលី-សំស្ក្រឹត»
## ដោយ : ភិក្ខុ ឈុម ទីរ៍, ភិក្ខុ ផល សុភឿន និង ភិក្ខុ ស៊ឹម សោន

យុគលពិន្ទុជាសញ្ញាវណ្ណយុត្តមួយប្រភេទដែលខ្មែរបង្កើតឡើងដើម្បីសម្រួលដល់ការប្រកបសូរក្នុងពាក្យកម្ចីពីបាលីសំស្ក្រឹត។ ក្នុងអត្ថបទនេះ យើងសិក្សាអំពីយុគលពិន្ទុព្រមទាំងប្រៀបធៀបវាជាមួយនឹងវណ្ណយុត្តដែលជាប់ពាក់ព័ន្ធខ្លះៗប៉ុណ្ណោះ។

**១- វណ្ណយុត្តជាអ្វី?**

ជាទូទៅ អ្នកសិក្សាភាសាខ្មែរតែងតែស្គាល់ និងហៅ យុគលពិន្ទុ ឬចំណុចពីរ ឬក៏ចុចពីរ (:) ថា វណ្ណយុត្ត ឬ វណ្ណយុត្តិ។ ដូច្នេះតើអ្វីទៅជាវណ្ណយុត្ត? វណ្ណយុត្តនេះ ក្នុងវចនានុក្រមខ្មែរមានអក្ខរាវិរុទ្ធ២យ៉ាងគឺ វណ្ណយុត្ត១, និង វណ្ណយុត្តិ១។ *វណ្ណ* ឬ *វណ៌* ជាពាក្យខ្ចីដោយត្រង់ពីបាលី-សំស្ក្រឹត. នៅក្នុងទីនេះចុះក្នុងអត្ថថា "រូប, សណ្ឋាន, ទ្រង់ទ្រាយ, អក្ខរៈ ឬ អក្សរ" < វណ្ណិ. ឬ វណ៌. ធាតុ + អ. បច្ច័យ, វិគ្រោះថា វណ្ណិតព្វាតិ = វណ្ណោ (សញ្ញា) "(សញ្ញា) ដែលជនគប្បីពោល, –ពណ៌នា = អក្សរ", កម្ម.កម្ម.។

- យុត្ត ប្រែថា "ប្រកបហើយ" < យុជិ.ធាតុ "ប្រកប, ផ្សំ" + ត.បច្ច័យ, រីឯ យុត្តិ ប្រែថា "(សញ្ញា) ជាគ្រឿងប្រកប, ការប្រកប" < យុជិ.ធាតុ "ប្រកប, ផ្សំ" + តិ.បច្ច័យ។

- វណ្ណយុត្ត < វណ្ណ + យុត្ត "(សញ្ញា) ដែលគេប្រកបហើយដោយ (ជាមួយនឹង) វណ្ណៈ (អក្សរ)" មានវិគ្រោះថា វណ្ណេន យុត្តា = វណ្ណយុត្តា[១] (សញ្ញា), ត.តប្បុ.។

- វណ្ណយុត្តិ < វណ្ណ + យុត្តិ "(សញ្ញា) ជាគ្រឿងប្រកបដោយ (ជាមួយនឹង) វណ្ណៈ (អក្សរ)" វិ. វណ្ណេ-ន យុត្តិ= វណ្ណយុត្តិ,ត.តប្បុ. មាន កម្ម.កម្ម. ជាផ្ទៃ (អ៊ុម គយ *ធាតុសង្គ្រោះ* ១៩៦៦ និង ព្រះពុទ្ធវង្ស សេខ នាង *បាលីវេយ្យាករណ៍* ២៥១២-១៩៦៨ : សមាសនិទ្ទេស និង កិតកនិទ្ទេស)។

សរុបសេចក្ដីមក *វណ្ណយុត្ត* ក្ដី, *វណ្ណយុត្តិ* ក្ដី ទាំងពីរនេះឱ្យប្រែថា "សញ្ញាប្រើប្រកបផ្សំនឹងអក្សរ" ដូចគ្នា បើទុកណាជាវាជានិយមន័យតាមជាតិសព្ទបាលីដោយត្រង់ក៏ដោយចុះ ក៏យើងអាចយកន័យនេះទៅអនុវត្តជាក់ស្ដែងលើភាសាមួយចំនួនដែលមានប្រើវណ្ណយុត្ត តើគេប្រើវាដើម្បីប្រកបសូរដូចស្រៈ ឬ លំអៀងសូរដូចក្នុងភាសាខ្មែរ ឬក៏ដើម្បីជាអលង្ការឱ្យល្អ?

វណ្ណយុត្ត ឬ –យុត្តិ (វ័ន-ណៈយុត) ន. (បា. ស.; សំ. *វណ៌យុក្ត* ឬ *–យុក្តិ*) គ្រឿងប្រដាប់សម្រាប់ប្រើផ្សំជាមួយនឹងអក្សរ; វណ្ណយុត្តសម្រាប់ប្រើក្នុងភាសាខ្មែរមាន ១៨ យ៉ាងគឺ *១. វិសជ៌នី* ឬ *វិសគ៌ៈ* ឬក៏ *រះមុខ* (ះ); *២. មូសិកទន្ត* ឬ *ធ្មេញកណ្ដុរ* ( ៉ ); *៣. ត្រីសព្ទ* ( ៊ ); *៤-. ទណ្ឌឃាត* ឬ *បដិសេធ* ( ៍ ); *៥. របាទ* ឬ *រេផៈ* ( ៌ ); *៦. រស្សសញ្ញា* ឬ *បន្តក់* ( ់ ); *៧. សំយោគសញ្ញា* ( ័ ); *៨. លេខទោ* ឬ *អាមេណ្ឌិតសញ្ញា* ( ៗ ); *៩. លេខអស្ដា* ( ៏ ); *១០. កាកបាទ* ឬ *ជើងក្អែក* ( + ); *១១. កុក្កុដនេត្រ* ឬ *ភ្នែកមាន់* ( ◎ ); *១២. របះ* ( ។ ); *១៣.*

---

[១] - បា. *វណ្ណយុត្តា* ឬ *វណ្ណយុត្តិ*; សំ. *វណ៌យុក្តា* ឬ *វណ៌យុក្តិ* (ចុះ *ត.* ឬ *តិ.* បច្ច័យដូចគ្នា)។ *វណ្ណយុត្តា* នេះ លោកធ្វើខ្មែរនីយកម្មលើ រូបសព្ទជា វណ្ណយុត្ត, រីឯ *វណ្ណយុត្តិ* នេះ ទុករូបដូចដើម, ហើយធ្វើខ្មែរនីយកម្មលើសូរសព្ទជា វ័ន-ណៈយុត ដូចគ្នា (តែនិយមថា វ៉ាន់-ណៈ យុត ជាង) ។

*បេះចប់* ឬ *បេះបរិយោសាន* ( ៕ ); *១៤. គោមូត្រ* ( ៚ ); *១៥. វ៉ាត់* ឬ *គាប* ( { } ); ១៦. *វង្កសញ្ញា* ( - ); *១៧. មច្ឆណ្ឌសញ្ញា* ឬ ពងត្រី ( ... ); *១៨. បេយ្យាល* ( ។ បេ ។ ) ឬ ( ។ល។ ); ជា ១៩ យ៉ាងនឹង *យុគលពិន្ទុ* នេះ ( : ) ដែលទើបនឹងបង្កើតថ្មី សម្រាប់ប្រើចុចសម្រួលពាក្យឱ្យងាយថា, ដូចជា *ធុរ:, ការ:, ព្យូហ:, លក្ខណ:* ជាដើម។ ក្នុងវចនានុក្រមនេះ មានប្រើវណ្ណយុត្តរបស់អឺរ៉ុបផង គឺ . , ; : ? ! = < > " " ( ) សម្រួលតាមសម័យនិយម (ដែលក្នុងសម័យបច្ចុប្បន្នបានឱ្យឈ្មោះថា សំ. បា. ឬជាខ្មែរអស់ហើយ) (សម្ដេចព្រះមហាសង្ឃរាជ ជួន ណាត (ជោតញ្ញាណោ) *វចនានុក្រមខ្មែរ* គ្រាទី ៥ ២៥១២-១៩៦៨:១១៥៧, ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ)។

សញ្ញាដែលបន្ថែមលើតួអក្ខរៈ ដើម្បីនឹងលំអៀងស័ព្ទវែងជាស័ព្ទខ្លី ឬ លំអៀងស័ព្ទឱ្យប្លែកពីស័ព្ទដើមឬកាត់ពាក្យក្នុងប្រយោគជាសង្កាត់ដើម្បីឱ្យលះសេចក្ដី ហៅថា *វណ្ណយុត្តិ*។ វណ្ណយុត្តិទាំងឡាយគឺ បន្តក់( ់ ), *មូសិកទន្ត* ( ៉ ), *ត្រីស័ព្ទ* ( ៊ ), *សំយោគសញ្ញា* ( ័ ), *របាទ* ( ៌ ), *អស្ដារ* ( ៏ ), *ទណ្ឌឃាត* ( ៍ ), *វិសជ្ជនីយ* (ះ), *កុក្កុដនេត្រ* ( ៙ ), *កាកបាទ* ( + ), *វង់ក្រចក* ( ... ), *អព្ភន្តរ* "..." , លះ ( ។ល។ ) (មកពីពាក្យ *បេយ្យាលៈ* គេយកតែ អក្សរ *ល* ខាងចុង), *គោមូត្រ* ឬ *បរិយោសាន* ( ៚ ), *ខណ្ឌ* ( ។ ) (ពូវ អ៊ុម, *វេយ្យាករណ៍ខ្មែរ* ថ្នាក់មជ្ឈិមដ្ឋាន និងឧត្តមដ្ឋាន ២៥១៥-១៩៧២:៥-៦ បណ្ណាគារ គីម សេង, ភ្នំពេញ) ។

នៅក្នុងភាសាអង់គ្លេសពាក្យ Punctuation មាននិយមន័យដូចជា៖

1 **:** the act of punctuating **:** the state of being punctuated

2 **:** the act or practice of inserting standardized marks or signs in written matter to clarify the meaning and separate structural units also **:** a system of punctuation

3 **:** something that contrasts or accentuates ( From: https://www.merriam-webster.com )

## ១.១- វណ្ណយុត្តគួរចែកជា[២] ៖

ដោយសង្កេតតាមលក្ខណៈនៃបម្រើបម្រាស់ជាក់ស្ដែង យើងអាចចែកវណ្ណយុត្តជាពួកៗដូច្នេះ ៖

១- វណ្ណយុត្តបង្រាស់សូរ ឬ លំអៀងសូរៈ ( ់ ), ( ័ ), ( ៏ ), ( ៌ ), ( ៎ ), (ះ), ( : )

២- វណ្ណយុត្តសម្រួលសូរ ( ៊ )

៣- វណ្ណយុត្តសម្លាប់សូរ ( ៉ )

៤- វណ្ណយុត្តបំបិទសូរ ( ៍ )

៥- វណ្ណយុត្តសញ្ញា ឬ អលង្ការវណ្ណយុត្ត ៙ ៚ ។ ៕ [] {} . , ; : ? ! = < > " " ( ) ... - / //

- យុគលពិន្ទុ ( : ) ប្រើនឹងបាលី ដូច នរ:, សុខ:, ពល:
- វិសជ្ជនី (ះ) ប្រើនឹងសំស្ក្រឹត (ជួសសូរ ស និង ហ) ដូច ព្រះ, តេជះ, គ្រឹះ, ចន្ទគ្រាះ, មានះ, ព្យុះ,
- វិសជ្ជនី (ះ) ប្រើនឹងខ្មែរ ដូច កែះ, អំពែះ, ចេះ, ចុះ, ជិះ, កោះ, ចង្កឹះ, គន្លឹះ, (ប្រហែលបែបនេះហើយបានជាក្នុងវចនានុក្រមខ្មែរគ្រាទី ៥ ពុំឃើញមានស្រៈ េះ, ុះ, ោះ និង ស្រះផ្សំ ែះ, ិះ, ឹះ ? )។

[២] ពុំទាន់ឃើញមានការសិក្សាណាមួយបែងចែកវណ្ណយុត្តទៅតាមលក្ខណៈនៃការប្រើប្រាស់របស់វានៅឡើយ។ ក្នុងទីនេះ យើងទើបសាកល្បងបែងចែកវា ដើម្បីងាយដល់ការសិក្សាសិន។

## ១.២- ការប្រើវណ្ណយុត្ត

យើងមើលឃើញថា ការយល់ថាវណ្ណយុត្តមានការប្រកបសូរ គឺជារឿងដោយឡែកអំពីអ្នកសិក្សាជាន់មុន។ អ្វីដែលគួរឱ្យឆ្ងល់នោះគឺថា បើយល់ថាវណ្ណយុត្តមានការប្រកបសូរមែន វាមិនច្រឡំគ្នានឹងស្រៈទៅហើយឬ? ដ្បិតស្រៈទើបមានការប្រកបសូរ។ មួយវិញទៀត វណ្ណយុត្តខ្មែរដូច (ំ), (័), (៏), (៎), និងវណ្ណយុត្ត ក្លាយពីសំស្រ្កឹត (៌)ជាដើមនេះ ក៏នឹងមានសូរផ្ទាល់ខ្លួនរបស់វាដែរហើយ តែវាមិនដូច្នោះឯណា វាគ្រាន់តែដាក់ផ្សំមកដើម្បីជួយបង្រាស់សូរ ឬ លំអៀងសូរឱ្យព្យញ្ជនៈទេតើ។ ដូចគ្នានេះដែរ (៉), (៊) ក៏ពុំមានសូរដែរ, យើងប្រើ(៉) ដើម្បីសម្លាប់សូរព្យញ្ជនៈ; ប្រើ (៊)ដើម្បីសម្រួលសូរ ព្យញ្ជនៈ ៤ តួគឺ ប, ស, ហ, អ ឱ្យទៅជា ប៊, ស៊, ហ៊, អ៊ ចំណែក (៍) យើងប្រើដើម្បីបំបិទសូរព្យញ្ជនៈ (មិនអានដល់ ឬ មិនយកជាតួប្រកប)។ វណ្ណយុត្តខ្មែរខ្លះ កម្ចីពីបរទេសខ្លះ ក្រៅនេះគឺ ៙ ៚ ។ ៕ [] {} . , ; : ? ! = < > " ″ ( ) … - / // _ យើងប្រើដើម្បីជួយខណ្ឌឬលះសេចក្តីក្នុងប្រយោគជាដើម ។

## ២- យុគលពិន្ទុ

យុគលពិន្ទុ អាន យុ. គល់. លៈ. ពិន-ទុ។ *យុគល*ប្រែថា គូ; *ពិន្ទុ* ប្រែថា តំណក់ ចំណុច រង់តូច ដូច និគ្គហិត ឬដូចជាលេខសូន្យក៏បាន។ យុគលពិន្ទុ គឺចំណុចមួយគូ។ ប្រើសំរាប់ញ៉ាំងស្រៈ *អ* ខ្មែរ ឱ្យបញ្ចេញសំឡេងខ្លី តាមបាឡីសំស្រ្កឹត។ លោកតែងប្រើនឹងស្រៈ *អ* នៅចុងពាក្យដែលមកពីភាសាទាំងពីរនេះ ដើម្បីឱ្យងាយអាន ឧ. *ឧបការៈ ទីឃៈ ខេមរៈ*។

យុគលពិន្ទុ ជាគ្រឿងសម្គាល់ទើបនឹងកើតថ្មីដោយព្រះតេជព្រះគុណ លោកគ្រូព្រះពោធិវង្ស ជួន ណាត ជាអ្នកបង្កើតសញ្ញានេះឡើង (អៀវ កើស, *ភាសាខ្មែរ* ១៩៦៧:៥៣[៣]) ។

យុគលពិន្ទុ (យុគៈលៈពិន-ទុ) ន. (សំ. បា. *យុគល* "គូ" + *វិន្ទុ* ឬ *ពិន្ទុ* "តំណក់; ចំណុច") ចំណុចមួយគូ ឬចំណុចពីរទន្ទឹមគ្នា (ម. ព. *ពិន្ទុ* ផង)។ ពាក្យសន្មតឱ្យជាឈ្មោះវណ្ណយុត្តមួយយ៉ាង (ៈ) ដូចគ្នានឹង ដឺពង់ត៍ (Deux points) របស់បារាំងសែសសម្រាប់ប្រើចុចពីខាងមុខអក្សរ ដែលមានសំឡេង ជា*អៈ, អាៈ, អេៈ* ជាដើម ដូចជា *ខេមរៈ, ធុរៈ, ភារៈ, មរណៈ, លក្ខណៈ, សក្ការៈ, ស្រៈ, អក្ខរៈ, អ៊ីហ៊ៈ, អេៈអុៗ, រអេះរអុ* ជាដើម; ប៉ុន្តែ ពាក្យដែលជា សមាសនាម មានដើមថា *កម្ពុជរដ្ឋ, ខេមរជាតិ, មគធភាសា, មរណភាព, រាជបុត្រ, សក្ការបូជា, អក្ខរវិធី* (ក័មពុជៈរ័ត, ខេម៉ៈរ៉ៈជាត, មៈគៈធៈភាសា, មៈរៈណៈភាប, រាជៈបុត, ស័កការ៉ៈបូជា, អ័កខៈរ៉ៈវិធី) នេះ កុំចុចអក្សរកណ្តាលជា *កម្ពុជៈរដ្ឋ, ខេមរៈជាតិ, មគធៈភាសា, មរណៈភាព, រាជៈបុត្រ, សក្ការៈបូជា, អក្ខរៈវិធី* ដូច្នេះឡើយ។ មួយទៀត យុគលពិន្ទុនេះមិនមានសំឡេងទេ សម្រាប់ប្រើជាគ្រឿងសម្គាល់ការចង្អុលពាក្យឬសេចក្តីខាងមុខ ដែលជាឧទាហរណ៍ឬជាព័ស្តុតាងជាដើម, ដូចជា ម្តាយនិយាយ ថា : *កូន, ឯងខំប្រឹងរៀនសូត្រទៅ ទាន់ខ្លួននៅក្មេង !* (ម. ព. *វណ្ណយុត្ត* ផង) (សម្តេចព្រះមហាសង្ឃរាជ ជួន ណាត (ជោតញ្ញាណោ) *វចនានុក្រមខ្មែរ* គ្រាទី ៥ ២៥១២-១៩៦៨:៩៥២, ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ)។

---

[៣] សៀវភៅនេះដដែល ទំព័រទី ៩១ ថា រហូតមកដល់ផុតសម័យអង្គរ (ចុងស.វ.ទី ១៤) យើងប្រើវណ្ណយុត្តិតែ ២ គឺ វិរាមៈ (៑) និង របាទ (៌), លុះដល់ចុងសម័យលង្វែក (ស.វ.ទី ១៦) យើងលើកប្រើ (៑) ទៅ។ សំយោគសញ្ញា (័) ប្រើនៅភាគខាងដើមស.វ.ទី ១៧ ។ [...] ឯវណ្ណយុត្តិដែលកើតក្រោយគេបំផុតនោះគឺយុគលពិន្ទុ (:) ។

យុគលពិន្ទុជាវណ្ណយុត្តមួយបែបមានសណ្ឋានជាចំណុចពីរទន្ទឹមគ្នាយ៉ាងនេះ (:) ដូចគ្នានឹងដឺពង់ត៍ (Deux points) បារាំង សម្រាប់ប្រើចុចពីខាងមុខពាក្យបាលី ឬសំស្ក្រឹតដែលមានសំឡេងលើកពីស្រៈ "អ"ឱ្យមានសំឡេងនៅពេញមាត្រាជាបាលីឬសំស្ក្រឹតដដែល(កុំឱ្យច្រឡំនឹងពាក្យបាលីឬសំស្ក្រឹតក្លាយដែលមានចោលស្រៈ "អៈ" មិនពេញមាត្រា) : *ខេមរៈ, គារវៈ, ឃោសៈ, ឆន្ទៈ, ជីវៈ, តបៈ, ថាវរៈ,...* ។ល។ (ពូវ អ៊ុម, *វេយ្យាករណ៍ខ្មែរពិស្ដារ* ២៥១១-១៩៦៨:១១៣ រោងពុម្ពខេមរដ្ឋ, ភ្នំពេញ) ។

ក្នុងក្របខណ្ឌទ្រឹស្ដីអន្តរកម្មនិយម សាស្ត្រាចារ្យ បណ្ឌិត ច័ន្ទ សំណព្វ បានឱ្យនិយមន័យ យុគលពិន្ទុដូច្នេះ "*យុគលពិន្ទុ* ជាសញ្ញាវណ្ណយុត្តមួយប្រភេទដែលខ្មែរបង្កើតឡើងសម្រាប់បំពេញសេចក្ដីត្រូវការក្នុងការសរសេរពាក្យមួយចំនួនដែលខ្ចីមកពីបាលីហើយដែលខ្មែរអានសូរ អោក់ ឬ អ៊ាក់ នៅខាងចុង។ វាត្រូវបានតាងដោយសញ្ញាចុចពីរ។ អាស្រ័យដោយហេតុនេះហើយ បានជាខ្មែរយើងហៅវាថា *សញ្ញាចុចពីរ* (ច័ន្ទ សំណព្វ *យុគលពិន្ទុឬសញ្ញាចុចពីរ* ២០១០:៥) ។

## **តើយុគលពិន្ទុមានសូរឬទេ?**

សូមសង្កេតពាក្យខាងក្រោម ៖

- រយៈ ន. សង្កាត់, ថ្នាក់, ភាគ, កម្រិត : រយៈកាល, រយៈផ្លូវ, រយៈវេលា, រយៈពាក្យ (សំ. បា. *រយ* "សន្ទុះ, ល្បឿន, ដំណើររួសរាន់, ឆាប់, រហ័ស") ។

- បដិយៈ (ប៉ៈ–) ន. (បា.; សំ. *បដិយ; ប្រតិយ*) សេចក្ដីចង្អៀតចិត្ត, សេចក្ដីក្ដាញ់, ដំណើរប៉ះទង្គិចចិត្តដោយសេចក្ដីក្រោធ : *កើតមានបដិយៈ, រំងាប់បដិយៈ* ។ រ. ស. កិ. *ទ្រង់ព្រះបដិយៈ គឺទ្រង់ក្ដាញ់* ។ *បដិយចិត្ត* ចិត្តដែលមានបដិយៈ, ចិត្តក្ដាញ់ ។

- *គេសជ្ជៈ, នរៈ, ទីឃៈ, ភារៈ, កុម្ភៈ, គារវៈ, គណៈ, ព្យញ្ជនៈ, សន្តវៈ, សភាវៈ,...* ។ល។ និងពាក្យ *សារៈសំខាន់* (សារ៉ៈ–), *មរណៈ, សាធារណៈ, សិល្បៈ, អាការៈ, លក្ខណៈ,...* ។ល។

- ព្រះ ន.(បា.សំ.*វរ*ប្រើជា *គុ.*"ប្រសើរ,ខ្ពង់ខ្ពស់,លើសលន់;ជាចម្បង;ដែលគួរប្រាថ្នា,គួរចង់បាន";ប្រើជា *ន.*ក៏បាន "ពរ; ស្វាមី; កូនប្រសាប្រុស; សេចក្ដីប្រាថ្នា...") ពាក្យនេះខ្មែរប្រើក្លាយមកដោយយក *វ > ព + រ + ៈ > ព្រះ*; សម្រាប់ហៅឋានន្តរមន្ត្រីស័ក្តិ ៦ហ៊ូពាន់ចុះបន្ទាប់ពីទី ឧកញ៉ាមក : មន្ត្រីទីព្រះ ។ សម្រាប់ប្រើនាំមុខនាមនាមឯទៀត បានច្រើនយ៉ាងជាអនេក : *ព្រះសម្មាសម្ពុទ្ធ; ព្រះឥន្ទ្រ, ព្រះព្រហ្ម; ព្រះមហាក្សត្រ, ព្រះរាជា, ព្រះករុណាជាម្ចាស់ជីវិត; ព្រះរាជបុត្រ; ព្រះធម៌; ព្រះសង្ឃ; ព្រះអាទិត្យ; ព្រះចន្ទ្រ; ព្រះពាយ; ព្រះបាទ; ព្រះកេសា; ព្រះអរហន្ត* ។ល។

- តេជះ (តេ– ឬ ដេ–) ន. (បា.; សំ. *តេជ; តេជស៑ > តេជះ*) មានសេចក្ដីដូចគ្នានឹង *តេជ* (ម ព. នោះ) : *ដោយតេជះគុណបុណ្យជួយឱ្យបានសេចក្ដីសុខ ។ សូមព្រះតេជះតម្កល់លើត្បូង !* ពាក្យសម្រាប់ប្រើក្នុងសេចក្ដីផ្ដើមក្រាបបង្គំទូលព្រះមហាក្សត្រទ្រង់រាជ្យ : *សូមព្រះតេជះតម្កល់លើត្បូង* ! សូមព្រះរាជទានទូលព្រះបង្គំជាខ្ញុំ ឧកញ៉ា... សូមក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទនៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង សូមទ្រង់ជ្រាប ។ល។

- សង្គ្រោះ ន. (សំ.; បា. សំ*គ្រហ* ឬ *សង្គ្រហ, ហ > (ះ) ;* បា. *សង្គហ*) ការទំនុកបម្រុង, ការជួយឱ្យ

បានសុខស្រួល : *បិញ្ចឹមរក្សាដោយសង្គ្រោះ, ឱ្យប្រាក់ដោយសង្គ្រោះ* ។ ខ្មែរច្រើនប្រើជា *កិ.* "ទំនុកបម្រុង, ផ្គុងផ្គើម, ស្រោចស្រង់, ជួយឱ្យបានសុខស្រួល" : *មាតាបិតាសង្គ្រោះបុត្រធីតា, អ្នកធំសង្គ្រោះអ្នកតូច* ។ រាប់បញ្ចូល, រួមចូល : *ធម៌នេះសង្គ្រោះចូលក្នុងព្រះអភិធម្ម* (កុំសរសេរ *សង្គ្រោះហ៍* ព្រោះ *ហ* > ះ ហើយ) ។

តាមលំនាំសិក្សាទាំងប៉ុន្មានដែលយើងបានលើកយកមកបង្ហាញក្នុងខាងលើនេះ បើមើលតែមួយភ្លែតទៅវា (យុគលពិន្ទុ) មានរូបសណ្ឋានស្រៀងគ្នានឹងស្រៈ (ះ) ដែរ, ហើយយើងគង់នឹងយល់ច្រឡំថា វាមានសូរ[៤] (អៈ/អិៈ) មិនលែងឡើយ។ ក្នុងន័យនេះយើងចង់និយាយថា, ដោយត្រង់នោះ វាមិនមានសូរទេ ដ្បិតវាជា វណ្ណយុត្ត, ហើយវណ្ណយុត្ត[៥] លោកប្រើគ្រាន់តែដើម្បីជួយបង្រាស់សូរ ឬ លំអៀងសូរនៃពាក្យកម្ចីពីបាលី-សំស្ក្រឹតឱ្យមានភាពរួសតាមធម្មជាតិសូរសម្តីក្នុងភាសាខ្មែរប៉ុណ្ណោះ វាពុំមានអំណាចញុំាងព្យញ្ជនៈឱ្យលាន់ឮសូរ (មិនអាចប្រកបសូរនឹងព្យញ្ជនៈ) ដូចស្រៈទាំងពួងបានឡើយ(គឺដូចដែលលោក អៀវ កើស *ភាសាខ្មែរ*, ពូរ អ៊ុម *វេយ្យាករណ៍ខ្មែរ,* និងសម្តេចព្រះមហាសង្ឃរាជ ជួន ណាត *វចនានុក្រមខ្មែរ* បានពន្យល់ទុកមកស្រាប់)។

ក្នុងប្រព័ន្ធវេយ្យាករណ៍បាលី បានពន្យល់និយមន័យ និង បង្ហាញលក្ខណៈរបស់ស្រៈថា "ស្រៈគឺជា អក្ខរៈញុំាងព្យញ្ជនៈឱ្យឮក( ឱ្យលាន់ឮសូរ/ឱ្យមានសូរ)"ដូចអ្វីដែលព្រះសាសនសោភ័ណ ជួន ណាត(ជោតញ្ញាណោ) *កច្ចាយនូបត្ថម្ភក ១*, ២៤៩៣-១៩៥០:៦/១២ សរសេរទុកមកថា ៖

[២] សរ ប្រែថា "ឮក" ឬថា "បញ្ចេញសំឡេង" គឺអក្ខរដែលនាំព្យញ្ជនៈឱ្យចេញសូរលាន់ឮផង បញ្ចេញសូរលាន់ឮតាមរំពងរបស់ព្យញ្ជនផង ហៅថា សរ (ស្រ) ។

[...] ឯស្រ ពិតជាចេញសំឡេងតាមទំនើងខ្លួនឯងបានមែន ប៉ុន្តែអាចនឹងធ្វើសេចក្តីឱ្យច្បាស់លាស់ថា ជាអ្វីដោយខ្លួនឯងទាំងអស់នោះពុំបានឡើយ ដូចភាសាបាឡីថា "វិហារេ" ឬដូចភាសាខ្មែរយើងថា "ទៅណា" បើប្រសិនជាសរសេរសុទ្ធតែស្រថា "ិ ា េ" ឬថា "ៅ ា" ដូច្នេះ នឹងយកសេចក្តីថាជាអ្វីក៏ពុំបាន, លុះតែដាក់ព្យញ្ជនរួមចូលជាមួយផង នោះទើបជាក់ប្រាកដថា "វិហារេ" ថា "ទៅណា" ដូច្នេះឡើងបាន ។

សរៈ ប្រែថា "(អក្ខរៈ) ញុំាងព្យញ្ជនៈឱ្យឮក, ឱ្យផ្សាយចេញ, ឱ្យលាន់ឮ" ឬថា "(អក្ខរៈ) ឮកនូវព្យញ្ជនៈ" វិគ្រោះថា ព្យញ្ជនានិ សរាបេន្តីតិ = សរា (អក្ខរា) ។ ព្យញ្ជនានិ សរន្តីតិ វា = សរា (អក្ខរា) (ព្រះ ពុទ្ធវង្ស សេខ នាង (សារញ្ញាណោ), *បាលីវេយ្យាករណ៍* ២៥១២១៩៦៨:០១) ។

## ២.១. ពាក្យតែមួយមាន (:) ខាងចុង

ក្នុងពាក្យ *សម័យ, វិស័យ, ភ័យ,...* យើងប្រើ ( ័ ) ផ្ទុំនឹងតួ *យ* ដើម្បីបង្រាស់សូរ (លម្អៀងសូរ) ពី *សៈ-ម៉ៈយ៉ៈ, វិ-សៈយៈ,* និង *ភៈ-យៈ* ឱ្យស្រួលមាត់ថាជា *សៈ-ម៉ៃ, វិ-សៃ, ភៃ* ។ ក្នុងអធិការនេះយើងឃើញថា

---

[៤] យើងលងធ្វើសន្និដ្ឋានជាដំបូងដូច្នេះ "ក្នុងពាក្យ *មរណៈ, អាការៈ* និង *រយៈ, ភេសជ្ជៈ* មាន សូរអៈ/អិៈ ចុងព្យាង្គពិតមែន, ប៉ុន្តែ សូរអៈ/អិៈ នេះ មិនមែនជាសូររបស់យុគលពិន្ទុឡើយ វាជាសូររបស់ *ស្រៈកប់តួអ* នៃព្យញ្ជនៈចុងព្យាង្គ ដែលកើតឡើងមក ពីបាតុភូតទំនាញសូរតាមរយៈ *មូលភេទអ/អិ"* ។

[៥] ក្នុងទីនេះ សំដៅយកវណ្ណយុត្តិបង្រាស់សូរទាំងអស់ លើកតែវណ្ណយុត្តសម្លាប់សូរ ២ គឺ ៌ និង ៍ ប៉ុណ្ណោះ ។

វណ្ណយុត្ត ( ៉ ) គ្មានសូរទេ ទាំងការកត់សូរថា *ស:ម៉:យ៉:, វិស៉:យ:, ភយ:* និង *ស:ម៉ែ* នេះសោត ក៏ពុំបានក្លាយ ទៅជាអក្ខរាវិរុទ្ធ (មេពាក្យ/កូនពាក្យ) នៅក្នុងវចនានុក្រម ឬក្នុងសំណេរទូទៅដែរ។

ក្នុងពាក្យ *សរៈ (ស្រៈ), លក្ខណៈ, ឆន្ទៈ, ភាទៈ,...* យើងប្រើ (:) ផ្សំរួមនឹងតួ *រ (្រ), ណ, ្ទ,* និង *ទ* ដើម្បីបង្រាស់សូរ (លម្អៀងសូរ) ពី *ស:រ៉: (ស្រ:), ល័ក-ខ: ណ:, ឆ័ន-ទ:* និង *ភាទ:* ឱ្យស្រួលមាត់ថាជា *សរៈ (ស្រៈ), ល័ក-ខ: ណ:, ឆ័ន-ទ:* និង *ភាទ:* ។ ក្នុងអធិការនេះយើងឃើញថា វណ្ណយុត្ត (:) គ្មានសូរទេ ប៉ុន្តែ ការកត់សូរថា *សរៈ (ស្រៈ)* នៃពាក្យ *សរៈ (ស្រៈ),* និងការកត់សូរ *ភាទ:* នៃពាក្យថា *ភាទ* នេះ វាបានក្លាយ ឃ្លាតមកជាសំណេរអក្ខរាវិរុទ្ធថា *សរៈ (ស្រៈ)* និង *ភាទ:,* ខណៈដែលការកត់សូរថា *ល័ក-ខ: ណ:,* និង *ឆ័ន-ទ:* ទាំងពីរនេះ ក៏ពុំបានឃ្លាតក្លាយទៅជាអក្ខរាវិរុទ្ធឡើយ គឺវានៅត្រឹមតែជាការកត់សូរឱ្យពាក្យ(មេពាក្យ/កូនពាក្យ)ដដែល ។

យើងឃើញថាពាក្យ *សម័យ, វិស័យ, ភ័យ,* និង *សរៈ (ស្រៈ), លក្ខណៈ, ឆន្ទៈ, ភាទៈ,...* ជាពាក្យទោល, វាគ្មានពាក្យជាគម្រប់ពីរណាមួយមកជាធាតុផ្សំឱ្យវាឡើយ។ ទាំងសូរ អោក់ ឬ អ៊ោក់ នៃព្យញ្ជនៈចុងព្យាង្គរបស់វាទៀតសោត ក៏ពុំបានតម្រូវថាត្រូវតែមាន (:) នេះ ដើម្បីកត់សូរ អោក់ ឬ អ៊ោក់ ឱ្យវាដែរ (តាមពិត *សរៈ, លក្ខណៈ, ភាទៈ* ជាដើមនេះ ក្លាយជាសំណេរអក្ខរាវិរុទ្ធមកពីការកត់សូរ *សរ, ភាទ, លក្ខណ*) ហើយតាមរយៈ អំណះអំណាងនេះ យើងនៅតែមើលឃើញថា *វណ្ណយុត្ត ពុំមាននាទីប្រកបសូរដូចស្រៈ*ដដែល គឺវានៅតែរក្សាអត្ថន័យជាវណ្ណយុត្តរបស់វាមិនបំពានដល់អត្ថន័យរបស់ស្រៈឡើយ។ នេះឯងហើយជាលក្ខណៈផ្សេងទីទៃពីគ្នា រវាងវណ្ណយុត្តនិងស្រៈ[៦] ។

## ២.២- ពាក្យផ្សំ

ក្នុងពាក្យផ្សំបាលីនិងបាលី វេលាយើងធ្វើ**ខ្មែរនីយកម្មលើសំណេរ**ក៏វាមិនប្រាដកថាត្រូវតែប្រើយុគលពិន្ទុហេតុនោះទេ ដូចជា *ជាតូបការ, សារមន្ទីរ, មនសិការ, វិប្បដិសារី, សារបណ្ណ, កាលបរិច្ឆេទ, កច្ចាយនូបត្ថម្ភក, កត្តុវាចក, បរិនាយក,...* ពាក្យទាំងនេះបើធ្វើ**ខ្មែរនីយកម្មសូរ** ឱ្យអានថា *ជាតូ ប៉:កា, សារ៉: មន់ទី, ម:ន:សិកា, (រ ជាមូគព្យញ្ជនៈ "ព្យញ្ជនៈគ" មិនប្រើជាតួប្រកបទេ), វិបប៉:ដិ-សារី, សារ៉:-ប័ណ, កាល៉: បរិចឆែត, ក័តតុ-វាចុក, ប៉រិ-នាយក់,* តែបើដាក់យុគលពិន្ទុជា *ជាតូបការ:, មនសិការ:, វិប្បដិសារ:, កាលបរិ-ច្ឆេទ:, កច្ចាយនូបត្ថម្ភក:, កត្តុវាចក:, បរិនាយក:,...ឱ្យអានថា ជាតូ ប៉:ការ៉:, ម:ន:សិការ៉:, វិបប៉:ដិសារ៉:, កាល: បរិចឆេទ:, ក័តតុ-វាច:ក:, ប៉:រិ-នាយ:ក:* ។

លោកសាស្ត្រាចារ្យ បណ្ឌិត ច័ន្ទ សំណព្វ (*ដំណកឃ្លាក្នុងភាសាខ្មែរ* ២០១១ : ២៣) ចាត់ *យុគលពិន្ទុ* ថាជា *វណ្ណយុត្ត* វាមានការប្រកបសូរ (មានសូរ?) ឯវណ្ណយុត្តផ្សេងពីនេះ ដូច ៗ ? ! , ៖ និង - ជាដើម មិនមែនជាវណ្ណយុត្តទេ វាគឺជា វណ្ណវាទ ដ្បិតវាពុំមានការប្រកបសូរឡើយ ដូចលោកបានធ្វើនយលក្ខណ៍ពន្យល់ពីភាពផ្សេងគ្នារវាង *វណ្ណវាទ* និង *វណ្ណយុត្ត* ដូច្នេះថា "*វណ្ណវាទ* ជាប្រភេទមួយនៃសិប្បសញ្ញា ហើយមានលក្ខណៈខុសពី *វណ្ណយុត្ត* ព្រោះ *វណ្ណយុត្ត* មានតួនាទីក្នុងការប្រកបសូរ ឯ *វណ្ណវាទ* វិញ គ្មានតួនាទីក្នុងការប្រកបសូរទេ តែ មានវិសាលកម្មក្នុងផ្នែកវាទកម្ម" ។

---

[៦] លក្ខណៈនេះ យើងអាចយកមកអនុវត្តបានលើសំណេរទូទៅនៃភាសាទាំងឡាយណាដែលមានវណ្ណយុត្ត, ឧ. ខ្ញុំមិនយល់ទេ! តើអ្នកចង់និយាយថាម៉េច? I do not understand. What do you mean? ! និង ? គឺជាវណ្ណយុត្ត ។

ដើម្បីឱ្យបញ្ហា "វណ្ណយុត្តមានសូរឬទេ?" នេះកាន់តែប្រចក្សឡើង យើងសូមលើកយកវណ្ណយុត្តមួយទៀត គឺ *វិសគ៌ៈ* ឬ *វិសជ្ជនី* ឬក៏ *រះមុខ* (ះ) មកសិក្សាធៀបគ្នា ដូចខាងក្រោម ៖

វិសគ៌ៈ ឬ វិសជ៌នី (–ស័រ-គៈ ឬ –ស័រ-ជៈនី) ន. (សំ.; បា. ធៀបនឹង សំ. ជា *វិសគ្គ, វិសជ្ជនីយ*) ឈ្មោះវណ្ណយុត្តមួយប្រភេទ (ះ) នេះ (ហៅ *រះមុខ* ក៏បាន); ខាងអក្សរទេវនាគរី (សម្រាប់សំស្រ្កឹត) ប្រើជាចំណុចមួយគូលើក្រោម ដូចយុគលពិន្ទុ (:), មានសូរសំឡេងស្រដៀងនឹងខ្យល់អក្សរ *ស* ដែលជាតួប្រកប ប៉ុន្តែមិនចេញសូរសម្លស្សតាមប្រទល់ធ្មេញដូចតួ *ស* ទេ, ដូចជា *កន្លះ, ពោះ* សូរខុសគ្នានឹង *កន្លាស់, ពស់* ។ ពាក្យសំស្រ្កឹតដែលមានតួ *ហ* នៅខាងចុង បើផ្លាស់ *ហ* ជា *វិសគ៌ៈ* (ះ) ហើយមិនត្រូវប្រើតួ ហ ថែមទៀតទេ, ដូចជា *គួហ, ចន្ទ្រគ្រាហ, សំគ្រហ, អនុគ្រហ ទៅជា គួះ ឬ គ្រឹះ, ចន្ទ្រគ្រាះ, សង្គ្រោះ, អនុគ្រោះ;* កុំប្រើជា *គ្រឹះហ៍, ចន្ទ្រគ្រាះហ៍, សង្គ្រោះហ៍, អនុគ្រោះហ៍* ដូច្នេះឡើយ។

ឥឡូវយើងឃើញថា ទាំងយុគលពិន្ទុ និងវិសជ្ជនី គឺជាវណ្ណយុត្តដូចគ្នា។ យុគលពិន្ទុ ប្រើលំអៀងសូរ លើពាក្យកម្ចីពីបាលី, ចំណែកឯ វិសជ្ជនី ប្រើជំនួស/តាងឱ្យសូរ *ស* ឬ *ហ* ក្នុងពាក្យកម្ចី ឬ អក្ខរប្បដិមរូប (Transcription) ពីសំស្រ្កឹត ។ ហើយវាទាំងពីរ សឹងពុំមានសូរដូចគ្នាដែរ ។

ផ្ទុយពីអ្នកសិក្សាជាន់មុន លោកសាស្រ្តាចារ្យ បណ្ឌិត ច័ន្ទ សំណព្វ បានពន្យល់ពីសូររបស់យុគលពិន្ទុដូចលោកបានយោងសេចក្តីក្នុងទំព័រទី ៥ នៃសៀវភៅ *យុគលពិន្ទុឬសញ្ញាចុចពីរ* ដូច្នេះ "សូមកុំច្រឡំសូរ ।អាក់। ឬ ।អ៊ាក់। នៃព្យាង្គចុងពាក្យមួយទៅនឹងសូរ ।អាក់। ឬ ।អ៊ាក់। នៃជាតុផ្សំរបស់ពាក្យ។ នៅក្នុងសំណេរពាក្យ សូរ ।អាក់। ឬ ।អ៊ាក់। នៃព្យាង្គចុងរបស់ពាក្យ ត្រូវបានកត់ត្រាដោយយុគលពិន្ទុ រីឯសូរ ।អាក់। ឬ ।អ៊ាក់। នៃជាតុផ្សំ របស់ពាក្យវិញ ត្រូវបានឬមិនបានកត់ត្រាដោយយុគលពិន្ទុឬសញ្ញាចុចពីរ ហើយប្រការនេះគឺអាស្រ័យដោយ លក្ខណៈរបស់ជាតុនោះ" ។

លោកលើកឡើងបន្ថែមទៀតថា "ជាទូទៅ យុគលពិន្ទុឬសញ្ញាចុចពីរមានតួនាទីក្នុងការប្រកបសូរជាមួយព្យញ្ជនៈចុងព្យាង្គនៃពាក្យខ្ចីពីភាសាបាលី ។

*ឧទាហរណ៍* គេប្រើយុគលពិន្ទុឬសញ្ញាចុចពីរនៅចុងពាក្យដូចជា *វណ្ណៈ ខណៈ គណៈ ទោសៈ សុខៈ លក្ខណៈ អាសនៈ ព្យញ្ជនៈ ពលៈ វយៈ ភោគៈ* ។ល។ប៉ុន្តែ នៅពេលគេធ្វើសន្ធិភ្ជាប់នាមសព្ទ *ពលៈ* ទៅនឹង *កម្ម* ដើម្បីបង្កើតពាក្យ *ពលកម្ម* គេត្រូវលុបយុគលពិន្ទុចេញពី *ពលៈ* ។ ការលុបនេះអាស្រ័យដោយ ពលៈ ក្លាយ ទៅជាជាតុបន្សំដែលមានមុខងារជាគុណបទ បើធៀបទៅនឹងជាតុស្នូល *កម្ម*។ ក្នុងបរិបទនេះ *ពលកម្ម* មានន័យ ថា *ការធ្វើអំពើដោយកម្លាំង* តែមិនមែនមានន័យថា *កម្លាំងនៃអំពើ* ឬ *កម្លាំងផងការប្រអំពើផង* នោះទេ" ។

តាមន័យនេះ យើងឃើញថា *វណ្ណៈ ខណៈ គណៈ,...* ដែលសរសេរដូច្នេះ គឺជាសំណេរក្លាយពីការកត់សូរ ពាក្យ *វណ្ណ ខណ គណ* របស់បាលី ដូច្នេះវាមិនមែនបាលីទេ។ ក្នុងការបង្កើតពាក្យផ្សំបាលី (សន្ធិ, សមាស, តទ្ធិត, ក្រិតក៍,...) គេមិនដែលសរសេរ *ពលៈ + កម្មៈ = ពលកម្ម* ដូច្នេះទេ (បើទុកជាវាពាក្យខ្ចីពីបាលីក៏ដោយ) តែគេសរសេរថា *ពល + កម្ម = ពលកម្ម* (សន្ធិ), *ពលេន កម្មំ = ពលកម្មំ* "អំពើដោយកម្លាំង" ត.តប្បុ.។ ដូច្នេះ ការដែលប្រកាន់ថា *ពលកម្ម* មកពី *ពលៈ + កម្មៈ* នេះ ក្នុងស្មារតីមួយថា ពាក្យខ្ចីពីបាលីមានការប្រកបសូរ [អាក់]ឬ[អ៊ាក់] របស់យុគលពិន្ទុជាមួយនឹងព្យញ្ជនៈចុងព្យាង្គនេះ គឺជាការយល់ឃើញមួយទៀតដោយឡែកពីវេយ្យាករណ៍បាលីក្នុងការបង្កើតពាក្យផ្សំ។

លោក យូ ជិន ( *វិធីសម្ពន្ធខ្មែរ* ១៩៥៩:១៣១-១៣៣ បណ្ណាគារ ឌុច ឈីន) សរសេរថា "យុគលពិន្ទុនេះសម្រាប់ ចុចត្រង់ទីបំផុតសព្ទ តែសព្ទនេះបានតែបាលីទេ។ តាមការសង្កេតរបស់លោកថា អ្នកប្រើ "យុគលពិន្ទុ" ច្រើនតែច្រឡំ ចេះតែចុចដោយសារមិនដឹងសណ្ឋានរបស់សព្ទ គឺបើសព្ទណាជា "បទសមាស" ត្រង់កណ្តាល គេមិនចុចទេ, គេប្រើសម្រាប់ចុចតែខាងចុងសព្ទនោះៗ។ ប្រើបានតែនឹងតួស្រៈ"អ"ខាងចុងមួយទេ គឺមិនមែនទូទៅទាំងអស់ឡើយ។

**ឱ.បទសមាសមិនត្រូវចុចយុគលពិន្ទុ**

*អត្ថប្រយោជន៍, សាធារណការ, បច្ចេកទេស, បញ្ចសីលា, អនាមិកជន, ឧត្តមបុរស, វិបុលសុខ, ឯកទេស, ឧបសគ្គ, មូលធននិយម, ឧបយុវរាជ, ធរមានភាព, ទាសភាព, ហីនភាព, កាលវិភាគ, សាកលលោក, កាលទាន, វិកលចរិត, ឧត្តមគតិបុរស,...* ។ល។

របៀបប្រើខាងលើនេះ គឺត្រូវត្រឹមតាមវេយ្យាករណ៍ពិតប្រាកដ។ អ្នកខ្លះប្រើច្រឡំទៅជាចុចខុសបែបមាត្រាវេយ្យាករណ៍ និងយុគលពិន្ទុទៅវិញ ។

**ឱ.បទសមាសមិនត្រូវចុចយុគលពន្ទុ បែរជាចុចទៅវិញនាំឱ្យខុស**

*អត្ថៈប្រយោជន៍, សាធារណៈការ, បច្ចេកៈទេស, បញ្ចៈសីលា, អនាមិកៈជន, ឧត្តមៈបុរស, វិបុ-លៈសុខ, ឯកៈទេស, ឧបៈសគ្គ, មូលធនៈនិយម, ឧបយុវៈរាជ, ធរមានៈភាព, ទាសៈភាព, ហីនៈភាព, កាលៈវិភាគ, វិកលៈចរិត, សាកលៈលោក, កាលៈទាន, ឧត្តមៈគតិបុរស,...* ។ល។

ពាក្យដែលគេត្រូវចុច ឧទាហរណ៍ដូចជា *ឋានៈ, កាលៈ, វៈ, ឧត្តមៈ, ធនៈ, សាកលៈ, តាលៈ, ហត្ថៈ, សត្ថៈ* ។ល។ បើសិនជាយើងមិនប្រើចុចនៅទីបំផុតសព្ទនេះទេ យើងអានតែមួយព្យាង្គក៏បានហើយ។ តែក្នុងទីខ្លះ អ្នកប្រាជ្ញលោកនិយមថាមិនចុចយុគលពិន្ទុក៏បាន តែវេលាអានក៏ហាក់បីដូចថា សំឡេងចុច ។

មានសព្ទខ្លះដូចជា *គណៈសព្ទ* វេលាដែលប្រើរួមជាមួយនឹងបទណា គេត្រូវនិយមចុចយុគលពិន្ទុ ដូចជា *គណៈរដ្ឋមន្ត្រី, គណៈកម្មការ, គណៈសង្គមនិយម,គណៈប្រតិភូនៃអង្គការសហប្រជាជាតិ* ក្រៅពីនេះ គឺចុចមិនបានជាដាច់ខាត។ បានជាលោកហ៊ានចុចនេះ គឺលោកអាងវេយ្យាករណ៍មួយបែបថា សមាសខ្មែរ[៧] ដែលប្រែថា "នៃ"ឬយកយុគលពិន្ទុមកជំនួសពាក្យថា"នៃ"នេះឯង ដូច្នោះពាក្យនេះវេលាយើងប្រើគប្បីចុចទៅចុះឥតមាន ការទាស់ខុសអ្វីទេ។

**ការសិក្សាពាក្យមាន (:) ចំកណ្តាលប្រភេទនេះហៅថា សមាសប្រាសជើង ៖**

វិ. កម្មការានំ គណោ = **គណកម្មការោ** "ពួក/ក្រុមនៃកម្មការ (អ្នកធ្វើការ)" ធ.តប្បុ. ខ្មែរនីយកម្មជា *គណៈកម្មការ* (គណៈ ជាធាតុស្នូល, កម្មការ ជាធាតុផ្សំ) ។

វិ. រដ្ឋមន្តីនំ គណោ = **គណរដ្ឋមន្តិ** "ពួក/បក្សនៃមន្ត្រីរបស់រដ្ឋ" ធ.តប្បុ. មាន ធ.តប្បុ.ជាផ្ទៃ ខ្មែរនីយកម្ម ជា *គណៈរដ្ឋមន្ត្រី* ។

វិ. ខេត្តស្ស គណោ = **គណខេត្តំ** "ពួកនៃខេត្ត" ធ.តប្បុ. ខ្មែរនីយកម្មជា *គណៈខេត្ត* ។

វិ. សភាយ អាសនំ = **អាសនសភា** "អាសនៈនៃសភា" ធ.តប្បុ. ខ្មែរនីយកម្មជា *អាសនៈសភា* ។

វិ. បុរិសស្ស ឧត្តមគតិ = **បុរិសុត្តមគតិ** "ឧត្តមគតិនៃបុរស" ធ.តប្បុ. ខ្មែរនីយកម្មជា *ឧត្តមគតិបុរស* (អ៊ុដដំមៈគតិ បុរ៉ស់) ។

**ពាក្យសមាសមាន (:) នៅខាងចុងហៅថា សមាសស្រប ៖**

វិ. គណស្ស បក្ខោ = **គណបក្ខោ** "ពួក/បក្សនៃគណៈ (ក្រុម)" ធ.តប្បុ. ខ្មែរនីយកម្មជា *គណបក្ខ* ។

---

[៧] តាមពិត ខ្មែរពុំមានសមាសទេ មានតែបាលីសំស្ក្រឹតប៉ុណ្ណោះដែលមានសមាស ។

វិ. លក្ខណេន សម្បត្តិ = **លក្ខណសម្បត្តិ** "សេចក្ដីដល់ព្រមដោយលក្ខណៈ" ត.តប្បុ. ខ្មែរនីយកម្មជា *លក្ខណសម្បត្តិ*។

វិ. សារំ បយោជនំ = **សារប្បយោជនំ** "ប្រយោជន៍ដ៏មានសារៈ" វិ.បុ.កម្ម. ខ្មែរនីយកម្មជា *សារ-ប្រយោជន៍*។

វិ. សារោ វត្តមានា = **សារវត្តមានា** (បវត្តិ) "(ដំណឹង)ដ៏មានសារៈ" វិ.បុ.កម្ម. ខ្មែរនីយកម្មជា *សារ-ព័ត៌មាន*។ តែ សារៈ + សំខាន់ = *សារៈសំខាន់* (ពាក្យផ្សំខ្មែរសុទ្ធ)។

វិ. សារំ បណ្ណំ = **សារបណ្ណំ** "បណ្ណ/សន្លឹកដ៏មាននៃខ្លឹមសារ" វិ.បុ.កម្ម. ខ្មែរនីយកម្មជា *សារបណ្ណ* ឬ *សារបាន*។

វិ. សារស្ស បណ្ណំ = **សារបណ្ណំ** "បណ្ណ/សន្លឹកនៃខ្លឹមសារ" ឆ.តប្បុ. ខ្មែរនីយកម្មជា *សារបណ្ណ* ឬ *សារ-បាន*។

វិ. អត្ថំ បយោជនំ = **អត្ថប្បយោជនំ** "ប្រយោជន៍ដ៏មានខ្លឹមសារ" វិ.បុ.កម្ម. ខ្មែរនីយកម្មជា *អត្ថប្រ-យោជន៍*។

វិ. តីរស្ស (បិតំ) វិថិយំ/វីថិយំ = **តីរវិថិ/តីរវីថិ** "វិថី (បិតនៅហើយ) ជាប់ឆ្នេរ" ឆ.តប្បុ. ខ្មែរនីយកម្មជា *តីរវិថី*។

វិ. មោទនស្ស ភាវោ = **មោទនភាវោ** "ភាព/ភាវៈនៃសេចក្ដីរីករាយ" ឆ.តប្បុ. ខ្មែរនីយកម្មជា *មោទ-នភាព*។

វិ. រតនំ យស្ស អត្ថីតិ = រតនោ (គិរិ) "(ភ្នំ) មានរតនៈ" អត្ថិតទ្ធិត ។ រតនោ គិរិ = **រតនគិរិ** "ភ្នំមានរតនៈ/ត្បូង" ខ្មែរនីយកម្មជា *រតនគិរី*។

## លក្ខណៈចំណាំយុគលពិន្ទុ

យុគលពិន្ទុមានសញ្ញាឱ្យចំណាំគឺ (:) *វៈ, ឋានៈ, កាលៈ*។ ជួនកាលខ្លះអ្នកសរសេរច្រើនតែច្រឡំនឹងវិសជ្ជនីយ (ះ) រះមុខអក្សរខ្មែរដូចជា *ខ្លះ, បះបោរ, ចេះ, នេះ, នោះ*។ ហេតុនេះអក្សរខ្មែរទៅជាវិបត្តិបាត់បែបវិធីទទេ ទៅជាយកខុសធ្វើជាច្បាប់ យកត្រូវទៅជាបោះចោលទៅវិញ ។

**ទម្រង់សម្ព័ន្ធនៃការប្រើយុគលពិន្ទុ (ប. ច័ន្ទ សំណព្វ យុគលពិន្ទុឬសញ្ញាចុចពីរ)**

ការសិក្សាយុគលពិន្ទុឬសញ្ញាចុចពីរបានបង្ហាញនូវលក្ខណៈដូចតទៅ ៖

យុគលពិន្ទុឬសញ្ញាចុចពីរត្រូវប្រើដាក់នៅជាប់នឹងព្យញ្ជនៈដែលប្រកបសូរនឹងវាមិនត្រូវដាក់ដំណកឃ្លានៅចន្លោះព្យញ្ជនៈនិងយុគលពិន្ទុឬសញ្ញាចុចពីរទេ ព្រោះវាប្រាសចាកពីសំណេរតាមការប្រកបសូរដែលតាមធម្មតាមិនតម្រូវឱ្យមានដំណកឃ្លានៅចន្លោះព្យញ្ជនៈនិងស្រៈ ឬ វណ្ណយុត្តដែលត្រូវប្រកបសូរនោះឡើយ។ ម្យ៉ាងទៀតវានឹងនាំឱ្យច្រឡំនឹងសញ្ញាសូរអានរបស់ធាតុទាំងពីរនេះក៏មិនដូចគ្នាដែរ។

ជាទូទៅ យុគលពិន្ទុឬសញ្ញាចុចពីរមានសូរពោលគឺមានសូរខ្យល់ *ក* នៅខាងចុង ចំណែកឯស្រៈ អាស់(ះ) និងវិសជ៌នីដែលអាចទាញសូរជាអ៊ាស់នោះវិញ មានសូរខ្យល់ *ហ* នៅខាងចុង។

## ៣- ទិដ្ឋភាពនានានៃការប្រើនិងមិនប្រើយុគលពិន្ទុ (:)

### ក. ពាក្យមាន (:) (ត្រូវតែមាន) ៖

ពាក្យកម្ចីពីបាលី-សំស្ក្រឹតប្រភេទនេះ ត្រូវប្រើយុគលពិន្ទុជាចាំបាច់ ទោះជាពាក្យទោលក្ដី ផ្សំក្ដី ដូចជា *សិល្បៈអមតៈ, កាលៈទេសៈ, ក្រឡាតបៈ, កច្ចាយនូបត្ថម្ភកៈ, សារៈសំខាន់,*

### ខ. ពាក្យគ្មាន (:) តែមាន រ ជាមូគព្យញ្ជនៈចុងព្យាង្គ ៖

ពាក្យក្រុមនេះ មាន (:)ក៏បាន គ្មាន (:)ក៏បាន។ បើមាន ត្រូវអានចេញសូរ អាក់ ឬ អ៊ាក់, បើគ្មានអានធម្មតា ដូចៈ *ជាតូបការ, សារមន្ទីរ, ឧបការ, អាការ, ករ, ការ, កតូបការ, ចរាចរ,...*

### គ. ពាក្យគ្មាន (:) តែមានព្យញ្ជនៈចុងព្យាង្គជាតួប្រកប ៖

ពាក្យក្រុមនេះ មិននិយមប្រើ (:) ទេ ដូចៈ *សម្ភព, ពិភព, មាណព, កាលបរិច្ឆេទ, ប្រេត, ជន, កុសល, កមល, មណ្ឌល, មេគណា...* ៖

**ឃ. ពាក្យគ្មាន (:) ហើយមានព្យញ្ជនៈសំយោគចុងព្យាង្គ៖**

ព្រាហ្មណ៍, កម្ម, បណ្ណ, បត្រ, ឆត្រ, ខន្ធ, ពន្ធ, ព័ន្ធ,

**ង. ពាក្យគ្មាន (:) តែប្រើ ៍ សម្លាប់សូរចុងព្យាង្គ៖**

ការណ៍, អនុសាសន៍, ឧបករណ៍, អនុស្សរណ៍, ព្រាហ្មណ៍, បដិសេធន៍, ចរាចរណ៍,

**ច. ពាក្យមាន (:) ក៏បាន គ្មាន (:) ក៏បាន (អាស្រ័យលើការអាន)៖**

ជាតូបការៈ, ឧបការៈ, អាការៈ, កតូបការៈ, ពិន្ទុកប្បៈ, សម្ភារៈឬសំភារៈ, កប្បៈ, កម្មៈ, ព្រហ្មៈ, ខន្ធៈ

**ឆ. ពាក្យមាន (:) ក៏បាន គ្មាន (:) ក៏បាន (អាស្រ័យលើការអាននិងន័យ)៖**

បុណ្យសម្ភារ (បុញ្ញំ សម្ភារំ = បុញ្ញសម្ភារំ "បុណ្យជាសម្ភារៈ" វិសេសនុ.កម្ម. ។

បុណ្យសម្ភារ (បុញ្ញំ ឯវ សម្ភារោ = បុញ្ញសម្ភារោ "សម្ភារៈគឺបុណ្យ" អវ.បុ.កម្ម. ។

**ជ. ពាក្យមាន ( : ) ក៏បាន គ្មាន ( : ) ក៏បាន ហើយអានបាន ២ បែប៖**

កត្តុវាចក, កម្ពុជ, កន្តារ, កតូបការ, ពិន្ទុកប្ប,

## ពាក្យដែលស្រាវជ្រាវចេញពីវចនានុក្រមខ្មែរ ពុទ្ធសាសនបណ្ឌិត្យ បញ្ហាយុគលពិន្ទុ

១- ពាក្យមានយុគលពិន្ទុ អានសូរ អៈ/អ៊ៈ

ឧទាហរណ៍៖ កច្ចាយនៈ កតូបការៈ បច្ចវេក្ខណៈ

២- ពាក្យសរសេរជាពីរបែប អានបានពីរបែប គឺអានដោយគ្មានការប្រកបសូរ និង មានការប្រកបសូរ

ឧទាហរណ៍៖ ភណ្ឌ ឬ ភណ្ឌៈ យម ឬ យមៈ

៣- ពាក្យសរសេរបានពីរបែប អានបានទាំងពីរបែប

ឧទាហរណ៍៖ តក្ក ឬ តក្កៈ ទីឃ ឬ ទីឃៈ បាឋ ឬ បាឋៈ ភាណវារ ឬ ភាណវារៈ វដ្ត ឬ វដ្តៈ

៤- ពាក្យសរសេរបានតែម្យ៉ាង មិនប្រើយុគលពិន្ទុ និង មិនបានសូរ

ឧទាហរណ៍៖ វិភាគ វិយោគ វិរាម

៥- ពាក្យសរសេរបានតែម្យ៉ាង គ្មានយុគលពិន្ទុ អាចអានបានសូរពីរ

ឧទាហរណ៍៖ កុសុម គោតម កម្ពុជ

៦- ពាក្យសរសេរមានព្យញ្ជនៈសំយោគនៅខាងចុង គ្មានយុគលពិន្ទុ

ឧទាហរណ៍៖ កប្ប កម្ម កល្ប គោត្ត

៧- ពាក្យសរសេរបានតែមួយបែប មានព្យញ្ជនៈសំយោគនៅខាងចុងគ្មានយុគលពិន្ទុ តែអានបានសូរពីរ

ឧទាហរណ៍៖ ជង្ឃ តុល្យ យុទ្ធ បាមោជ្ជ

៨- ពាក្យសរសេរមានព្យញ្ជនៈសំយោគនៅខាងចុង គ្មានយុគលពិន្ទុ តែអានសូរ អៈ/អ៊ៈ

ឧទាហរណ៍៖ ធម្ម បុញ្ញ បុព្វ វត្ត

៩- ពាក្យសរសេរមានព្យញ្ជនៈសំយោគនៅខាងចុង មានយុគលពិន្ទុ មានសូរអាន អៈ/អិៈ

ឧទាហរណ៍៖ គន្លៈ ឆន្ទៈ វង្គៈ អត្ថៈ

១០- ពាក្យសរសេរបានពីរបែប មានព្យញ្ជនៈសំយោគនៅខាងចុង មួយមានយុគលពិន្ទុ មួយគ្មានយុគលពិន្ទុ អានបានសូរពីរ

ឧទាហរណ៍៖ ទណ្ឌ/ទណ្ឌៈ យញ្ញ/យញ្ញៈ សច្ច/សច្ចៈ

១១- ពាក្យសរសេរបានតែមួយបែប គ្មានយុគលពិន្ទុមានសូរអាន អៈ/អិៈ

ឧទាហរណ៍៖ កក្កដ ទេវ យោធ លេខ។

## ឯកសារពិគ្រោះ


- ព្រះសាសនសោភ័ណ ជួន ណាត (ជោតញ្ញាណោ) *កច្ចាយនូបត្ថម្ភក ១* (២៤៩៣-១៩៥០) ភ្នំពេញ : សាលាបរិយត្តិជាន់ខ្ពស់ក្រុងភ្នំពេញ ។
- សម្តេចព្រះមហាសង្ឃរាជ ជួន ណាត (ជោតញ្ញាណោ) *វចនានុក្រមខ្មែរ ភាគទី ១ ភាគទី ២* (២៥១២-១៩៦៧) ភ្នំពេញ : ពុទ្ធសាសនបណ្ឌិត្យ ។
- អៀវ កើស *ភាសាខ្មែរ* (២៥០៩-១៩៦៧) ភ្នំពេញ : បណ្ណាគារមិត្តសេរី ។
- ព្រះពុទ្ធវង្ស សេខ នាង (សារញ្ញាណោ), *បាលីវេយ្យាករណ៍* (២៥១២-១៩៦៨) ភ្នំពេញ : ពុទ្ធសាសនបណ្ឌិត្យ ។
- ព្រះធម្មឃោសាចារ្យ សេខ នាង (សារញ្ញាណោ), *អធិប្បាយបាលីវេយ្យាករណ៍* (២៥១៨-១៩៧៤)ភ្នំពេញ : ពុទ្ធសាសនបណ្ឌិត្យ ។
- ឃឹន សុខ *វេយ្យាករណ៍ភាសាខ្មែរ* (២០០៧) ភ្នំពេញ : រាជបណ្ឌិតសភាកម្ពុជា ។
- ក្រសួងអប់រំ *វេយ្យាករណ៍ថ្នាក់ទី ៥* (១៩៨៣) ភ្នំពេញ : មជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា ។
- ក្រសួងអប់រំ *វេយ្យាករណ៍ថ្នាក់ទី ៨* (១៩៨៦) ភ្នំពេញ : មជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា ។
- ច័ន្ទ សំណព្វ យុគលពិន្ទុឬសញ្ញាចុចពីរ (កក្កដា ២០១០) ភ្នំពេញ : រាជបណ្ឌិត្យសភាកម្ពុជា ។
- សម្តេចព្រះមហាសង្ឃរាជ ជួន ណាត *បទសម្ភាសន៍នាទីអក្សរសាស្ត្រ* (២០០២) ភ្នំពេញ : រាជបណ្ឌិត្យសភាកម្ពុជា ។


**អត្ថបទនេះជាទស្សនៈរបស់ម្ចាស់អត្ថបទ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរទេ**